# វគ្គបណ្តុះបណ្តាលស្តីពី

# ឧស្សនទានស្តីពីការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ពីការបាត់បង់ និងរេចរឹលព្រៃឈើ REDD+

**កម្មវិធីUN-REDD ថ្នាក់ជាតិ**

UNDP PROJECT No. 00078446

អគារលេខ ៤០ វិថីព្រះនរោត្តម ខ័ណ្ឌ ដូនពេញ ព្រះរាជាណាចក្រកម្ពុជា

# មាតិកា

សារតា ................................................................ 2
ការប្រែប្រួលអាកាសធាតុ និងឥទ្ធិពល ................................................................ 4
តួនាទីព្រៃឈើក្នុងការកាត់បន្ថយការប្រែប្រួលអាកាសធាតុ ................................................................ 10
កត្តាដែលធ្វើឲ្យ បាត់បង់ព្រៃឈើ និងរេចរឹលព្រៃឈើ ................................................................ 16
សេចក្តីផ្តើមនៃ REDD និង REDD+ ................................................................ 20
គំនិតផ្តួចផ្តើមពីរេដបូកនៅកម្ពុជា ................................................................ 31
តម្រូវការជាមូលដ្ឋាន និងលកខ័ណ្ឌបច្ចេកទេសសម្រាប់រេដបូក ................................................................ 57
ការធានាសុវត្ថិភាពសេដ្ឋកិច្ច សង្គមក្នុងការអនុវត្ត REDD ................................................................ 67

## សារាង

ការប្រែប្រួលអាកាសធាតុគឺជាបញ្ហាប្រឈមមួយដ៏ស្មុគស្មាញដែលមនុស្សជួបប្រទះនាពេលបច្ចុប្បន្ន ។ មានការព្យាករណ៍ថា ការកើនឡើងនូវសីតុណ្ហភាព ការប្រែប្រួលអាកាសធាតុនឹងធ្វើអោយមានខ្យល់ព្យុះ ទឹកជំនន់ ភាពរាំងស្ងួត និងស្ថានភាពដែលមានសីតុណ្ហភាពខុសធម្មតា (ក្តៅខ្លាំង និងត្រជាក់ខ្លាំង) ព្រមទាំងការប្រែប្រួល នូវវដ្ត រដូវកាល របស់រុក្ខជាតិ និងសត្វ។ ដូចនេះការប្រែប្រួលអាកាសធាតុនឹងមានផលប៉ះពាល់ដល់វិស័យសេដ្ឋកិច្ចសង្គម ដែលមាន ឥទ្ធិពលលើសន្តិសុខស្បៀង ធនធានទឹក សុខាភិបាល ការចិញ្ចឹមជីវភាព និងហេដ្ឋារចនាសម្ព័ន្ធ ។

ការកើនឡើងជាមធ្យមនៃសីតុណ្ហាភាពពិភពលោក គឺត្រូវបានបង្កឡើងដោយការបំភាយឧស្ម័នផ្ទះកញ្ចក់ពីសកម្មភាពឧស្សាហកម្ម វិស័យថាមពលនិងការដឹកជញ្ជូន សកម្មភាពកសិកម្ម និងការកាប់បំផ្លាញព្រៃឈើនិងការរេចរឹលព្រៃឈើ។ មានតួរលេខខុសៗគ្នាត្រូវបានផ្តល់ស្តីពីការបំភាយឧស្ម័នកាបូនិច ពីការកាប់បាត់បង់ និងរេចរិលព្រៃឈើ តែបើផ្អែកលើរបាយការណ៍ ឆ្នាំ២០១៣ នៃគម្រោង Global Carbon Project ចំនួននេះមាន ៨%។ ដូច្នេះការកាត់បន្ថយការបំភាយឧស្ម័នពីការបាត់បង់ និងការរេចរិលគឺជាជម្រើសមួយដែលត្រូវបានស្នើឡើង ដោយ សហគមន៍អន្តរជាតិដើម្បីកាត់បន្ថយការប្រែប្រួលអាកាសធាតុ។

ការកាត់បន្ថយការបំភាយឧស្ម័នពីការបាត់បង់ និងការរេរិល REDD គឺជាការផ្តួចផ្តើមបង្កើតនូវតម្លៃនៃ ហិរញ្ញប្បទានពីការរក្សាទុកនូវកាបោនព្រៃឈើ ផ្តល់នូវការលើកទឹកចិត្តដល់ប្រទេសកំពុងអភិវឌ្ឍន៍នានាក្នុងការកាត់ បន្ថយនូវការបំភាយឧស្ម័នពីដីព្រៃឈើនានា ។ កាត់បន្ថយការបំភាយឧស្ម័នពីការបាត់បង់ និងការរេចរឹល REDD មិនគ្រាន់តែគិតគូរពីការបាត់បង់ និងរេចរិលព្រៃឈើប៉ុណ្ណោះទេ ប៉ុន្តែរួមបញ្ចូលទាំងតួនាទីនៃការអភិរក្ស និងនិរន្តភាព នៃការគ្រប់គ្រងព្រៃឈើ និងបង្កើននូវការស្តុកកាបូនព្រៃឈើផងដែរ ។

រាជរដ្ឋាភិបាលកម្ពុជា (RGC) បានទទួលស្គាល់ REDD+ ជាយន្តការមួយសម្រាប់ការពារព្រៃឈើធម្មជាតិនៅក្នុងប្រទេសកម្ពុជាតាមរយៈការអភិវឌ្ឍរ៉េដ Roadmap/ការរៀបចំការអភិវឌ្ឍ ការត្រៀមខ្លួនជាស្រេច (R-PP) ។ យន្តការនាពេលអនាគតរបស់ REDD+ ផ្តល់នូវឱកាសសម្រាប់ប្រទេសកម្ពុជាដើម្បីអាចទទួលបាននូវហិរញ្ញប្បទានពីការអភិរក្សព្រៃឈើ, ការការពារ និងការគ្រប់គ្រងប្រកបដោយនិរន្តភាព។

ទោះជាយ៉ាងណា ខណៈពេលដែលផែនការនេះមាននូវការសន្យាជាច្រើន, យន្តការនៃការអនុវត្ត REDD+ មិនទាន់ត្រូវបានយល់ដឹងអោយបានច្បាស់លាស់នៅឡើយ ដោយមាននូវបញ្ហាជាច្រើនដែលត្រូវដោះស្រាយ ។ លើសពីនេះទៀត មានទិដ្ឋភាពបច្ចេកទេសជាច្រើន និងលក្ខខ័ណ្ឌនានា សំខាន់ៗសម្រាប់ការទទួលបានភាពជោគជ័យ នៃការអនុវត្តរ៉េដបូក ដែលរួមមាន តម្រូវការសម្រាប់បង្កើននូវការយល់ដឹង ការធ្វើឱ្យប្រសើរឡើងនូវចំណេះដឹង និងសមត្ថភាពនៃអ្នកពាក់ព័ន្ធទាំងអស់របស់រ៉េដបូក ។ ដូច្នេះ តាមរយៈការគាំទ្ររបស់អង្គការសហប្រជាជាតិនៅកម្ពុជា - កម្មវិធី REDD+

ថ្នាក់ជាតិ មជ្ឈមណ្ឌលសម្រាប់មនុស្ស និង ព្រៃឈើ ( RECOFTC ) នឹង រៀបចំវគ្គបណ្តុះបណ្តាលស្តីពី "**ទស្សនទានស្តីពី ការកាត់បន្ថយការបញ្ចេញឧស្ម័នពីការបាត់បង់ និងរេចរិលព្រៃឈើ** REDD" ដែលកម្មវិធីបណ្តុះបណ្តាលនេះ គឺរៀបចំឡើងដើម្បីគាំទ្រដល់ការអនុវត្ត REDD+ Roadmap និងជាពិសេសដើម្បីជួយគាំទ្រដល់ការអភិវឌ្ឍ សមត្ថភាព ឆ្ពោះទៅរកការអភិវឌ្ឍនូវយុទ្ធសាស្ត្រ REDD+ និងក្របខ័ណ្ឌនានានៃការអនុវត្ត REDD+ ។ គោលបំណងរួមនៃវគ្គបណ្តុះ បណ្តាលនេះគឺដើម្បីបង្កើនចំណេះដឹង និងការយល់ដឹងនៃ REDD+ក្នុងចំណោមក្រុមអ្នកពាក់ព័ន្ធនានា ដើម្បីជួយសម្រួលដល់ការចូលរួមរបស់ពួកគេនាពេលអនាគតក្នុងការពិគ្រោះយោបល់ និងដំណើរការនៃការសម្រេចចិត្ត ដែលទាក់ទងទៅនឹង REDD+ នៅកម្ពុជា ។

# ការប្រែប្រួលអាកាសធាតុ និងឥទ្ធិពល

## អ្វីទៅជាការប្រែប្រួលអាកាសធាតុ? ការសង្កេតទូទៅទាក់ទៅនឹងការប្រែប្រួលអាកាសធាតុ

- មិនមានភ្លៀងតាមពេលវេលា ឬមានភ្លៀងធ្លាក់នៅពេលដែលរដូវភ្លៀងបានកន្លងហួសទៅហើយ
- នៅកន្លែងខ្លះ មានភ្លៀងធ្លាក់ខ្លាំងពេក ហើយនៅកន្លែងខ្លះជួបគ្រោះរាំងស្ងួត
- ពូជស្រូវមួយចំនួនមិនធន់នៅកន្លែងដែលខ្វះទឹក និងកន្លែងដែលមានទឹកច្រើន ជារឿយៗមានទឹកជំនន់ និងរាំងស្ងួត ដែលធ្វើអោយប៉ះពាល់ដល់ទ្រព្យសម្បត្តិរបស់ប្រជាជន សត្វពាហនៈ បរិស្ថាន និងប្រជាជនឮ
- មានការកើនឡើងនូវភ្លើងឆេះព្រៃ បាត់បង់ប្រភេទសត្វ និងរុក្ខជាតិ

អ្នកជំនាញការជឿថា ប្រការខាងលើនេះគឺជាបញ្ហានៃការប្រែប្រួលអាកាសធាតុ ។

ការប្រែប្រួលអាកាសធាតុគឺជាការផ្លាស់ប្តូរទម្រង់នៃកត្តាអាកាសធាតុជាមធ្យមក្នុងរយៈវែង ។

គេអាចនិយាយបានថា ការប្រែប្រួលអាកាសធាតុគឺ ជាការផ្លាស់ប្តូរយៈពេលវែងនៅក្នុងមធ្យមភាគនៃធាតុអាកាស។

អ្នកវិទ្យាសាស្ត្រពិចារណាលើកត្តាដែលបានកត់សំគាល់ជាច្រើននៃការប្រែប្រួលអាកាសធាតុ ដូចជា ៖ ការប្រែប្រួលនូវរបបទឹកភ្លៀង រួមមាន ភ្លៀងធ្លាក់ខ្លាំង និងការហួតហែង ការកើនឡើង ឬថយចុះនូវល្បឿនខ្យល់ជាមធ្យម កំណើនសីតុណ្ហភាព និងអាកាសធាតុដែលមិនអាចទស្សន៍ទាយបាន។

បើយើងធ្វើការប្រៀបធៀបពីពេលវេលា ១៥០ទៅ ២០០ឆ្នាំកន្លងមក នាពេលបច្ចុប្បន្នអត្រានៃការប្រែប្រួលអាកាសធាតុមានការកើតឡើងយ៉ាងឆាប់រហ័ស ធ្វើអោយមានការ កើតឡើងនូវកំដៅលើផែនដី ប្រភេទសត្វ និង រុក្ខជាតិជាច្រើនមិនអាចរស់នៅបានជាមួយនឹងការប្រែប្រួលនូវនេះ ។ សុចនាករនានានៃ ការប្រែប្រួលអាកាសធាតុត្រូវបានគេកត់សំគាល់រួចមកហើយ ដោយសារតែការកើនឡើង សីតុណ្ហភាពនៅក្នុងបរិយាកាស ។ ការកើន ឡើងនូវឧស្ម័នផ្ទះកញ្ចក់នៅលើផែនដីគឺជា លទ្ធផលនសការកើនឡើងនូវសីតុណ្ហភាព។




រូបភាពទី ១៖ ផលផ្ទះកញ្ចក់

### ឧស្ម័នផ្ទះកញ្ចក់ និងឥទ្ធិពល

នៅក្នុងធម្មជាតិ ស្រទាប់បរិយាកាស ផ្សំឡើងដោយឧស្ម័នផ្សេងៗគ្នាជាច្រើន រួមមាន អាសូត ៧៨% អុកស៊ីសែន ២១% ហើយឧស្ម័នផ្សេងទៀតមាន ១% ។ កាំរស្មី និងថាមពលពីពន្លឺព្រះអាទិត្យ (Solar) ដែល បានប៉ះផែនដីផ្នែកខាងលើតាមរយៈបរិយាកាសមានតែ៧០ភាគរយ ដែលបានចាំងចុះមកដល់ផែនដីដោយផ្ទាល់ ចំណែកឯ ៣០ភាគរយទៀត ត្រូវបានភាយត្រឡប់វិញ ឬបាត់បង់តាមផ្លូវ ។ នៅក្នុងចំណោម ៧០% នៃ ថាមពល ពន្លឺព្រះអាទិត្យ ត្រូវបានស្រូបដោយផ្នែកខាងលើនៃផែនដី ផ្នែកខ្លះត្រូវបានស្រូបដោយសមុទ្រ និងខ្លះត្រូវបាន ចាំងត្រឡប់ទៅវិញដែលឧស្ម័នមួយចំនួននៅក្នុងបរិយាកាសបានស្រូបយក។

ឧស្ម័នដែលចាប់យកកំដៅ ចាំងត្រឡប់ពីផែនដី គឺជាឧស្ម័នផ្ទះកញ្ចក់ (GHGs) ដែលកើត ដោយ ធម្មជាតិក្នុងបរិយាកាសហើយគឺជាផ្នែកមួយសំខាន់នៃជីវិតលើផែនដី ឧស្ម័នទាំងនោះមានជាអាទិ៍គឺ ឧស្ម័នកាបូនិក ចំហាយទឹក មេតាន ហាឡូកាបោន និងអូសូន។

**ឧស្ម័នផ្ទះកញ្ចក់**

ឧស្ម័នកាបូនិក ($CO_2$),
មេតាន ($CH_4$),
ឌីអាសូតម៉ូណូអុកស៊ីត ($NO_2$),
អូហ្សូន ($O_3$),
ហាឡូកាបោនHalocarboons (HC) និង ឧស្ម័នភ្លុយអ័រូកាបោន Perfluorocarbon, អ៊ីដ្រូភ្លុយអរ៉ូកាបោន HFCs និងចំហាយទឹក

នៅពេលពុំមានឧស្ម័នផ្ទះកញ្ចក់ សីតុណ្ហភាពនៅផ្នែកខាងលើ នៃផែនដីអាចនឹងរក្សានូវសីតុណ្ហភាព -១៨ អង្សាសេ ហើយនៅ ក្នុង ស្ថានភាពនេះ ផែនដីនឹងមិនមាន ភាពសមស្របសម្រាប់ការរស់នៅរបស់ មនុស្ស សត្វ និងរុក្ខជាតិនោះទេ ។

ទោះយ៉ាងណាក៏ដោយ បច្ចុប្បន្ននេះ ដោយសារតែសកម្មភាពរបស់មនុស្ស ធ្វើអោយឧស្ម័នផ្ទះកញ្ចក់នៅក្នុងស្រទាប់បរិយាកាស មាន ការកើនឡើងយ៉ាងឆាប់រហ័ស ដែលឧស្ម័ននេះជាអ្នកស្រូបយកនូវកំដៅហើយធ្វើអោយសីតុណ្ហភាពសាកលមានការកើនឡើង ។

ឧស្ម័នផ្ទះកញ្ចក់ដោយសារតែសកម្មភាពរបស់មនុស្សរួមមាន ៖

- ចំហាយទឹក
- កាបោនឌីអុកស៊ីត
- មេតាន
- នីត្រូអុកស៊ីត
- អូសូន

ការសាយភាយនូវឧស្ម័នផ្ទះកញ្ចក់មានការកើនឡើង គឺដោយសារតែកត្តាមួយចំនួន ដែលក្នុងនោះរួមមាន ការដុតឧស្ម័នប្រេងឥន្ធនៈនានា (ការដុតឥន្ធនៈផូស៊ីល ប្រេងនិងឧស្ម័នធម្មជាតិ) ការពង្រីក វិស័យឧស្សាហកម្ម ការពង្រីកមធ្យោបាយនានាក្នុងវិស័យដឹកជញ្ជូន ការប្រើប្រាស់ម៉ូតូ ឡានច្រើន ការប្រើប្រាស់នូវថាមពលច្រើន ហួស កម្រិត ការ

បាត់បង់ព្រៃឈើ ទំនើបកម្មនៃវិស័យកសិកម្ម (វាលស្រែ ជាពសាស្ត្រ និងការប្រើប្រាស់នូវថ្នាំគីមីសំលាប់សត្វ) ការប្រែប្រួលលើការប្រើប្រាស់ដី ។ ក្នុងចំណោមកត្តាទាំងនេះ ការកើនឡើងជាបន្តនៃចំនួនប្រជាជនត្រូវបានគេរំពឹង ថានឹងបង្កើននូវតម្រូវការថាមពល អាហារ និងសម្ភារៈនានា ដែលបានបង្កឱ្យមានការបំភាយឧស្ម័នផ្ទះកញ្ចក់បន្ថែមទៀត និងការដាក់សម្ពាធបន្ថែមទៀតលើធនធានដីរួមទាំងព្រៃឈើផងដែរ ។ នេះបើយោងតាមរបាយការណ៍ចុងក្រោយរបស់អង្គការសហប្រជាជាតិដែលបានចេញផ្សាយកាលពីខែមិថុនាឆ្នាំ២០១៣បានបង្ហាញថា ចំនួនប្រជាជនពិភពលោកនាពេលបច្ចុប្បន្ននេះគឺមានរហូតដល់ ៧.២ ពាន់លាននាក់ ដែលត្រូវបានគេរំពឹងថានឹងមានការកើនឡើងរហូតដល់ ១ ពាន់លាននាក់នាឆ្នាំ ២០២៥ នងអាចកើតដល់ ៩,៦ ពាន់លាននាក់នៅត្រឹមឆ្នាំ ២០៥០ ។

បើយោងតាមរបាយការណ៍ថ្មីៗរបស់អង្គការ អន្តរជាតិ និងវិទ្យាស្ថាន Wood Hole Research Institute ទាក់ទងនឹងការសាយភាយឧស្ម័នផ្ទះកញ្ចក់ពីការបាត់បង់ព្រៃឈើលើសាកលលោករបស់គម្រោង Global Carbon Project (2013) បានធ្វើការប៉ាន់ប្រមាណថា បរិមាណនៃការបំភាយ ឧស្ម័នដោយសារការបាត់បង់ព្រៃឈើមាន ប្រមាណ ៣ Gt នៃ Co2/ឆ្នាំ ហើយការបំភាយដោយសារតែការរេចរឹលព្រៃឈើ និងដីមានប្រមាណ 2.6 Gt នៃ Co2/ឆ្នាំ ក្នុងកំឡុងឆ្នាំ ២០០០ដល់ ២០១០។ បរិមាណនេះប្រហាក់ប្រហែលនឹង ១២ភាគរយនៃការបំភាយឧស្ម័ន ផ្ទះកញ្ចក់ លើសាកលលោក ។

**ផលប៉ះពាល់ដោយសារតែការប្រែប្រួលអាកាសធាតុ**

យើងអាចយល់បានអំពីឥទ្ធិពលនានាដែលមានការពាក់ព័ន្ធទៅនឹងការប្រែប្រួលអាកាសធាតុដោយការសិក្សាអំពីទំនាក់ទំនងរវាងប្រព័ន្ធអេកូស៊ីស្តែម និងប្រព័ន្ធនៃការអភិវឌ្ឍរបស់មនុស្ស ។ ក្នុងប្រព័ន្ធធម្មជាតិ កម្រិតទឹកភ្លៀង កំនើននីវ៉ូទឹកសមុទ្រ និងការកើនឡើងនូវគ្រោះធម្មជាតិជារឿយៗ ត្រូវបានចាត់ទុកថាជាសូចនាករនៃការប្រែប្រួល អាកាសធាតុ ។ ដូចគ្នានេះដែរ ការអនុវត្តសកម្មភាពសេដ្ឋកិច្ច សង្គម សម្រាប់ការបន្សាំ និងធ្វើអោយ ឥទ្ធិពល នៃការអភិវឌ្ឍរបស់មនុស្សកាន់តែតិចតួចនឹងជួយអោយកាត់បន្ថយនូវឥទ្ធិពលនៃការប្រែប្រួលអាកាសធាតុ ។

ធនធានទឹក កសិកម្ម ព្រៃឈើ និងជីវៈចម្រុះគឺជាធនធានដែលរងគ្រោះខ្លាំងដោយសារតែការប្រែប្រួលអាកាសធាតុ ដោយសារតែឥទ្ធិពលទាំងនេះកើតឡើងដោយសារតែការប្រែប្រួលអាកាសធាតុព្រោះតែកំនើនសីតុណ្ហភាព ។ ជារួមសីតុណ្ហភាព បរិមាណទឹកភ្លៀង រំញោចផែនដី គឺទទួលរងនូវឥទ្ធិពលដោយសារតែការប្រែប្រួលអាកាសធាតុ ។ នៅកន្លែងខ្លះ កម្រិតទឹកភ្លៀងជាធម្មជាតិមានការប្រែប្រួល ហើយដែលនៅកន្លែងផ្សេងទៀត មានការកើនឡើង ឬថយ ចុះនូវបរិមាណទឹកភ្លៀង ។ ជាមួយគ្នានេះដែរ នៅតាមតំបន់មួយចំនួននៅលើពិភពលោក នៅតំបន់ដែលធ្លាប់ តែមាន ធ្លាក់ទឹកកកពីមុនមក ។ ព្រឹត្តិការណ៍នៃព្យុះនានា និងកម្រិតទឹកភ្លៀងខ្លាំងបានកើនឡើង ។ ភាពរាំងស្ងួតកើត មានឡើង ក្នុងរយៈពេលវែងជាងមុន ដែលតាមរយៈរូបភាពខាងក្រោម អាចបញ្ជាក់អំពីឥទ្ធិពលនានានៃការប្រែប្រួលអាកាសធាតុ ។

## ធនធានទឹក

ការប្រែប្រួលអាកាសធាតុមានការប៉ះពាល់យ៉ាងធ្ងន់ធ្ងរចំពោះធនធានទឹកនៃប្រទេសកម្ពុជា។ កំណកអាកាសនឹងកើនឡើងនៅកន្លែងខ្លះ តែថយចុះនៅតំបន់ផ្សេងទៀត ។ នៅក្នុងតំបន់អាកាសធាតុក្តៅល្មម បាតុភូតទឹកជំនន់ និងរាំងស្ងួតទំនងជាកើតមានជាញឹកញាប់ ។ ការកើនឡើងនូវគ្រោះរាំងស្ងួតនៅក្នុងតំបន់ បានបណ្តាលអោយមាន កង្វះទឹកសម្រាប់ធ្វើកសិកម្ម និងប្រើប្រាស់ប្រចាំថ្ងៃ ។ ផ្ទុយទៅវិញកំនើនទឹកភ្លៀងអាចនាំអោយកាន់តែសំបូរទឹកសម្រាប់ ប្រើប្រាស់នៅកន្លែងខ្លះ ប៉ុន្តែជាមួយគ្នានេះដែរ ក៏អាចបង្កអោយ ទឹកជំនន់ផងដែរ ហើយបញ្ហានៃការហូរបាត់ដី កំកកដី និងមានដីកំណកថ្មហូរចូលតំបន់កសិកម្ម មានការកើនឡើងផងដែរ ។ គ្រោះទឹកជំនន់ និងគ្រោះរាំង ស្ងួតញឹក ញាប់នឹងបង្កអោយមានផលប៉ះពាល់ដល់គុណភាព និងបរិមាណទឹក ។

## កសិកម្ម

ការប្រែប្រួលអាកាសធាតុមានផលប៉ះពាល់ចំពោះធនធានទឹក ក៏មានឥទ្ធិពលខ្លាំងក្លាផងដែរលើ វិស័យកសិកម្ម ។ ដោយសារតែកំនើនសីតុណ្ហភាព នឹងធ្វើអោយ ប្រព័ន្ធអេកូស៊ីស្តែមមានការផ្លាស់ប្តូរ និងធ្វើអោយ ប្រព័ន្ធធារាសាស្ត្រមានការខូចខាត និងផលិតផលដំណាំមានការថយចុះ ។ ការដាំដុះដំណាំនានាដូចជា ពោត ដំឡូង និងដំណាំរួមផ្សំនានាមានទិន្នផលទាប ។ ដោយសារតែមានការកើនឡើងនូវសីតុណ្ហភាព ធ្វើ អោយមានកង្វះខាតទឹក ដូចដែលយើងឃើញមានឧទាហរណ៍ជាច្រើនមកហើយដូចជាការកើនឡើងនូវសត្វល្អិត និងជំងឺឆ្លងដែលធ្វើអោយ ដំណាំមិនអាចទទួលបានផលគ្រប់គ្រាន់។ គោ ក្របី និងសត្វនានាជួបនូវបញ្ហា និងមានជំងឺដោយសារតែខ្វះស្មៅ និងចំណីអាហារផ្សេងៗ ។

## ជីវៈចម្រុះ

ការប្រែប្រួលអាកាសធាតុនឹងមានឥទ្ធិពលចំពោះជីវៈចម្រុះ ។ ប្រសិនបើបរិមាណនៃឧស្ម័នកាបូនិកក្នុងបរិយាកាសកើនឡើងពីរដង មានការទស្សន៍ទាយថាវានឹងមានឥទ្ធិពលដល់ប្រភេទរុក្ខជាតិផ្សេងៗ ដែលប្រភេទរុក្ខជាតិមួយចំនួនអាចនឹងមានការបាត់បង់ទាំងស្រុងតែម្តង ។ ប្រភេទសត្វមួយចំនួនអាចនឹងធ្វើការផ្លាស់ប្តូរទៅរងទីតាំងដែលមានសីតុណ្ហភាពសមស្រប និងត្រជាក់ជាង ។

នៅក្នុងករណីខ្លះ ប្រភេទសត្វមួយចំនួនដែលមិនអាចផ្លាស់ប្តូរទៅរកទីតាំងដែលមានរយៈកំពស់ផ្សេងគ្នា ឬបរិស្ថានសមរម្យ ដូចជាសត្វល្អិតនៅក្រោមដី និងប្រភេទផ្លែឈើធំៗនានានឹងស្ថិតនៅក្រោមការគំរាមកំហែងដ៏ធ្ងន់ធ្ងរ ។ នៅក្នុងបរិបទនៃប្រទេសកម្ពុជា សមាសភាពនៃជីវៈចម្រុះនៃប្រទេសកម្ពុជាអាចមានការប្រែប្រួលធាប់ជាងការរំពឹងទុក ដោយសារតែកម្ពុជាត្រូវបានចាត់ទុកថា ជាប្រទេសមួយក្នុងចំណោមប្រទេសនានាដែលងាយរងគ្រោះបំផុតដោយសារតែការប្រែប្រួលអាកាសធាតុ។ នៅក្នុងព្រះរាជាណាចក្រកម្ពុជា មានអាកាសធាតុពីរសំខាន់ ប៉ុន្តែ ប្រសិនបើអាកាស ធាតុ

មានការប្រែប្រួលខ្លាំង ហើយមានការបញ្ចេញឧស្ម័នកាបូនិកខ្លាំងទៅក្នុងបរិយាកាសអាចនឹងធ្វើអោយប្រភេទ និង រុក្ខជាតិមួយចំនួនបាត់បង់ និងទទួលរងគ្រោះខ្លាំង ។

កម្រិតទឹកនៅតំបន់ដីសើមអាចនឹងធ្វើអោយមានផលប៉ះពាល់ខ្លាំងដល់ជីវៈចម្រុះដោយសារតែកំនើនសីតុណ្ហភាព ទឹកជំនន់ ការហូរបាត់ដី ការហូរច្រោះ និងប្រភពទឹកចុះខ្សោយ អាចនឹងធ្វើអោយមានផលប៉ះពាល់លើទំហំ និងគុណភាពនៃតំបន់ដីសើម ដែលជាលទ្ធផលអាចធ្វើអោយប៉ះពាល់ដល់ជីវៈចម្រុះនៃតំបន់ដីសើម ។ ដីសើម ភាគ ច្រើនគឺជាប្រភពនៃធនធានទឹក ហើយដែលការថយចុះនូវបរិមាណទឹកអាចនឹងធ្វើអោយមានការថយចុះនូវបរិមាណ ទឹកដែលអាចមាននៅក្នុងប្រព័ន្ធចែកចាយទឹក

## សុខាភិបាល

មានផលប៉ះពាល់ទាំងផ្ទាល់ និងប្រយោលចំពោះសុខភាពរបស់មនុស្សដោយសារតែការប្រែប្រួលអាកាសធាតុ។ ដោយសារតែមានការបំពុលទឹក និងខ្យល់ធ្វើអោយប្រជាជនជួបប្រទះនូវជំងឺមួយចំនួនដូចជា ជំងឺអាសន្នរោគ ជំងឺ រាគរូស ជំងឺគ្រុនចាញ់ និងជំងឺគ្រុនឈាមជាដើម ។

## ប៉ះពាល់ដល់ការចិញ្ចឹមជីវិត

នៅទីបញ្ចប់ការប្រែប្រួលអាកាសធាតុនឹងប៉ះពាល់ដោយផ្ទាល់ចំពោះការចិញ្ចឹមជីវិតរបស់មនុស្ស ។ ប្រជាជន ក្រីក្រដែលមកពីមូលដ្ឋាននឹងទទួលរងនូវផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរ ដោយសារតែផលិតផលដំណាំមិន សូវទទួលបាន ផល និងមិនអាចបំពេញតម្រូវការនៃការហូបចុកអោយបានគ្រប់គ្រាន់ ។ ដោយសារតែទឹកនៅក្បែរភូមិកាន់តែរីង ប្រជាជនបានចំណាយពេលវេលាយ៉ាងច្រើនសម្រាប់ការទៅដងទឹក ដែលធ្វើអោយពួកគាត់មិនមានពេលវេលាគ្រប់ គ្រាន់សម្រាប់ការងារបង្កបង្កើនផល ។ លើសពីនេះទៀត កង្វះខាតទឹក ចំណីអាហារ និងការកើនឡើងនូវសីតុណ្ហភាព អាចនឹងនាំអោយមានបញ្ហាកង្វះខាតនូវជីវជាតិ និងមានជំងឺកើនឡើង ដែលអាចនឹងនាំអោយមានបញ្ហាដល់រាងកាយ ដែលអាចធ្វើអោយមានការប៉ះពាល់ដល់ការសិក្សា ។ ជាទូទៅ ផលប៉ះពាល់ដោយផ្ទាល់ដល់ការចិញ្ចឹមជីវិតដោយសារតែ ការប្រែប្រួលអាកាសធាតុអាចប៉ះពាល់ធ្ងន់ធ្ងរដល់ប្រជាជនកម្ពុជា ។

## ការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ

មានវិធីពីរយ៉ាងក្នុងការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ ៖

**ការកាត់បន្ថយ ៖** អន្តរាគមន៍ ឬគោលនយោបាយនានាដើម្បីកាត់បន្ថយឧស្ម័ននានា និងបង្កើនការស្តុកឧស្ម័នផ្ទះកញ្ចក់។

**ការបន្សាំ ៖** មានវិធីជាច្រើនប្រភេទដើម្បីឆ្លើយតបចំពោះការប្រែប្រួលអាកាសធាតុ (ឧ. ការសម្រួលក្នុងខ្លួនមនុស្ស) និងគោលនយោបាយនានាដើម្បីកាត់បន្ថយផលប៉ះពាល់ដែលបានព្យាករណ៍ដោយការប្រែប្រួលអាកាសធាតុ (ដូចជា រៀបចំនូវការការពារតំបន់ឆ្នេរអោយបានប្រសើរជាងមុន) ។

ជាការចាំបាច់ដែលត្រូវចងចាំថា មិនមែនមានតែវិធីសាស្ត្រទាំងនោះទេ គឺមានការរួមបញ្ចូលនូវវិធីទាំងពីរ ខាងលើដោយប្រើប្រាស់ព្រៃឈើសម្រាប់ជាការកាត់បន្ថយ និងបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ ។ ឧទាហរណ៍ ព្រៃដែលមានសុខភាពល្អមិនគ្រាន់តែអាចស្តុកកាបោនប៉ុណ្ណោះទេ ប៉ុន្តែអាចរួមចំណែកដល់ការ ផ្តល់នូវភាពចម្រុះនៃ ការចិញ្ចឹមជីវិត និងជម្រើសនានាសម្រាប់ការរកចំណូលជាបុគ្គល និងសម្រាប់សហគមន៍ ជាពិសេសនៅពេលដែលមានព្រឹត្តិការណ៍នៃការប្រែប្រួលអាកាសធាតុដូចជា ទឹកជំនន់ និងរាំងស្ងួតដែលធ្វើអោយផលិតផលកសិកម្ម មិនអាច ទទួលបានផល ។

អនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ(UNFCCC) គឺជាអនុសញ្ញាអន្តរជាតិ ដែលប្រទេសនានាធ្វើការចរចារលើបញ្ហានានាទាក់ទងនឹងការប្រែប្រួលអាកាសធាតុ ដូចជា ការកាត់បន្ថយ ការបន្សាំ ហិរញ្ញវត្ថុ ការបញ្ជូននូវបច្ចេកទេស ។ល។

ការបន្សាំ៖

ជាការសម្របនៃប្រព័ន្ធធម្មជាតិ ឬមនុស្សទៅនឹងបរិស្ថានថ្មី ឬដែលប្រែប្រួល ។ ការបន្សាំនឹងការប្រែប្រួលអាកាស ធាតុសំដៅលើការសម្របនៃប្រព័ន្ធធម្មជាតិ ឬមនុស្ស ជាការឆ្លើយតបទៅនឹងកត្តា ឬឥទ្ធិពលអាកាសធាតុដែល ឡើង កើតឡើងជាក់ស្តែង ឬដែលរំពឹងថាកើតឡើង ដែលបន្ធូរបន្ថយគ្រោះថ្នាក់ ឬទាញយកផលប្រយោជន៍ពីឱកាសដែលមាន។

**ឯកសារយោង៖**

IPCC, (2007). Summary for Policymakers: A report of Working Group I of the Intergovernmental Panel on Climate Change. Available online: **http://www.ipcc.ch/ipccreports/tar/vol4/english/pdf/wg1spm.pdf** (last accessed 11th October 2011).

Just a Lot of Hot Air? The Panos Institute, 2000. Longdon, UK\\

The Department of Climate Change, 2013. Understanding Climate Change: A reference guidbook for Secondary School.

# តួនាទីព្រៃឈើក្នុងការកាត់បន្ថយការប្រែប្រួលអាកាសធាតុ

តាមរយៈ ព័ត៌មានវិទ្យាសាស្ត្រពីការកើនឡើងកំដៅនៃផែនដី ដែលមានកន្លងមក ការប្រែប្រួល អាកាសធាតុអាចជាភាពប្រឈមផ្នែកបរិស្ថានដែលចំបងជាងគេនៅសតវត្សទី២១។ លើសពីនេះទៀត គឺភាពគំរាមកំហែង នានា ដូចជា ភាពអត់ឃ្លាន ភាពក្រីក្រ កំនើនប្រជាជន ការបំពុលខ្យល់ ឱនភាពដីធ្លី ការបាត់បង់ព្រៃឈើ និងរហោដ្ឋានកម្ម។ ភាពគំរាមកំហែងទាំងនេះទាក់ទងទៅវិញទៅមកដល់ការប្រែប្រួលអាកាសធាតុ ដែលទាមទារឲ្យមានយន្ត ការសាកល មួយសម្រាប់ដោះស្រាយ។ សំពាធនៃភាពប្រឈមនេះទាមទារនូវកិច្ចសហការរវាងជាតិសាសន៍នានា និងការគាំទ្រពី អង្គការអន្តរជាតិដែលពាក់ព័ន្ធ។ ធាតុសំខាន់ៗនៃកិច្ចសហការនេះអាចរួមមាន ប្រភពនៃការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ អ្នករងគ្រោះដោយការប្រែប្រួលអាកាសធាតុ និងវិធានការកាត់បន្ថយឥទ្ធិពលនៃការប្រែប្រួលអាកាសធាតុ តាមរយៈការ បង្កើនអាងស្តុក និងអាងស្រូបកាបោន ។

ព្រៃឈើមានតួនាទី ៤សំខាន់ទាក់ទងនឹងការប្រែប្រួលអាកាសធាតុ។ ដូចដែលបានបង្ហាញខាងលើ ព្រៃឈើបានរួមចំណែកក្នុងការបំភាយឧស្ម័ន ៨ ទៅ ១០% នៃការបំភាយឧស្ម័នកាបូនិកជាសាកល នៅពេលដែលព្រៃ ឈើ ត្រូវបានកាប់បំផ្លាញ ឬដុត ការប្រើប្រាស់ហួសកំណត់ ។ ព្រៃឈើមាន ប្រតិកម្មខ្លាំងចំពោះការប្រែប្រួលអាកាសធាតុ ព្រៃឈើបានផ្តល់ជាឈើថាមពល ដែលជាជម្រើសមួយក្នុងការប្រើប្រាស់ជំនួសអោយថាមពលប្រេងឥន្ធនៈនៅពេល ដែលព្រៃឈើបានគ្រប់គ្រងដោយនិរន្តភាព ។

មុនពេលយើងធ្វើការពិភាក្សាអំពីតួនាទីរបស់ព្រៃឈើក្នុងការប្រែប្រួលអាកាសធាតុ យើងត្រូវធ្វើ ការស្វែងយល់ពីទស្សនទាន និងពាក្យគន្លឹះមួយចំនួនជាមុនសិន ដែលជារឿយៗត្រូវបានគេប្រើប្រាស់ទាក់ទងនឹងការប្រែប្រួល អាកាសធាតុ និងកិច្ចសន្ទនាទាក់ទងនឹងព្រៃឈើ ។

**ការបាត់បង់ព្រៃឈើ** Deforestation

**ការបាត់បង់ព្រៃឈើ ត្រូវបានគេអោយនិយមន័យថា** “ ជាការផ្លាស់ប្តូរប្រភេទដីព្រៃទៅជាដីគ្មានព្រៃ ដែលមានលក្ខណៈយូរអង្វែង ឬជាអចិន្ត្រៃយ៍ ” ។

**ការរេចរឹលព្រៃឈើ**

ការរេចរឹលព្រៃឈើត្រូវបានគេអោយនិយមន័យថា ជាការកាត់បន្ថយនូវសមត្ថភាពនៃការផ្តល់សេវាកម្ម និងសម្ភារៈនានាពីព្រៃឈើ ។ នៅក្នុងបរិបទនៃការប្រែប្រួលអាកាសធាតុ ការរេចរឹលព្រៃឈើត្រូវបានគេយល់ថាជាការបាត់បង់នូវកាបោនព្រៃឈើដែលបានបន្តទៅតាមពេលវេលា។ ប្រការនេះអាចកើតមានឡើងដោយការដកហូតយកដើមឈើធំទាំងអស់នៅក្នុងព្រៃ ប៉ុន្តែនៅតែមិនបានកំណត់ថាមានការបាត់បង់ព្រៃឈើ។ ការប្រមូលផលជាធម្មតាកើតឡើងក្នុងផ្នែកមួយ

នៃការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាពមិនត្រូវបានចាត់ទុកថាជាការរេចរឹលព្រៃឈើទេ ប៉ុន្តែនៅក្នុងការអនុវត្តជាក់ស្តែង វាមិនតែងតែត្រូវបានធ្វើអោយឃើញពីភាពខុសគ្នាក្នុងរយៈពេលខ្លី តាមរយៈការត្រួតពិនិត្យនៃការស្តុកកាបូននោះទេ ។

“ ជាការប្រែប្រួលព្រៃឈើ ដែលជះឥទ្ធិពលជាអវិជ្ជមានដល់សារព័ន្ធព្រៃ ឬ មុខងាររបស់តំបន់នោះ ជាហេតុធ្វើឱ្យថយចុះនូវសមត្ថភាពក្នុងការផ្គត់ផ្គង់ផលិតផល និង/ឬ សេវារបស់វា” ។

**ជាអាងស្តុកកាបោន**

ព្រៃឈើ និងអេកូស៊ីស្តែមណាមួយ គឺជាអាងស្តុកកាបោន ។ កាបោនមាននៅគ្រប់កន្លែង ទាំងនៅក្នុងស្លឹករហូតដល់ក្នុងដី ។ វិធីដែលល្អក្នុងការមើលអោយឃើញការស្តុកនូវកាបោនគឺត្រូវគិតពីការស្តុកនៃជីវម៉ាស់ក្នុង ប្រព័ន្ធ អេកូស៊ីស្តែម ។ ជីវម៉ាស់គឺជាម៉ាស់នៃសារធាតុសរីរាង្គនៅក្នុងតំបន់ឬអេកូស៊ីស្តែមមួយនៅក្នុងពេលវេលាមួយ ។ ជិត ៥០ភាគរយនៃជីវម៉ាស់ស្ងួតគឺជាកាបោន ។ ប្រសិនបើជីវម៉ាស់ស្ងួតរបស់ឈើមាន ២តោន នោះវាមាននូវសារ ជាតុកាបោន ១តោន ។

នៅក្នុងប្រព័ន្ធអេកូឡូស៊ីស្តែមព្រៃឈើជាច្រើននៅក្នុងបណ្តាប្រទេសតំបន់ត្រូពិច ភាគច្រើននៃកាបោន ត្រូវបានរក្សាទុកនៅក្នុងជីវម៉ាស់រស់ ព្រៃឈើដែលដុះលូតលាស់នៅក្នុងដីភក់ល្បាប់គឺជាករណីលើកលែងដោយសារតែភាគច្រើនកាបោនត្រូវបានរក្សាទុកនៅក្នុងដី។

**លំហូរកាបោន Carbon flux**

រុក្ខជាតិប្រើប្រាស់ពន្លឺថ្ងៃជាប្រភពនៃថាមពល ស្លឹកស្រូបឧស្ម័នកាបូនិកពីបរិយាកាស និងធ្វើការបំលែងតាមរយៈដំណើរការនៃការធ្វើស្មើសំយោគ ។ ផលិតផលតាមរយៈដំណើរការនេះបានបែងចែកដល់រុក្ខជាតិទាំងមូល ហើយបានបញ្ចេញជាកាកសំណល់លើដីនៅពេលដែលមែកឈើ ឬស្លឹកឈើបានជ្រុះនិងរលួយ។ ឧស្ម័នកាបូនិកនឹងត្រូវបំភាយ ជាថ្មីម្តងទៀតនៅពេលដែលដើមឈើមានការពុកផុយ ។

**រូបភាពទី ២: វដ្តនៃកាបោនជាសាកល**




ប្រភព ៖ NASA

ដូច្នេះ ព្រៃឈើបានដើរតួនាទីយ៉ាងសំខាន់ក្នុងវដ្តនៃកាបោនជាសាកល (សូមអានរូបភាពទី២) ។ បច្ចុប្បន្ន ព្រៃឈើគ្របដណ្តប់លើផ្ទៃដី ៣១%នៃផ្ទៃដីសរុបលើសាកលោក ឬប្រមាណ ៤ ពាន់លានហិកតាលើសាកលលោក ឬ៣០ ភាគរយនៃផ្ទៃដីសរុបលើពិភពលោក[1] ។

យោងតាមរបាយការណ៍របស់វិទ្យាស្ថាន World Resources Institute ព្រៃឈើស្តុកកាបោនប្រមាណជា ៤០ភាគរយនៃចំនួនកាបោនសរុប ដែលត្រូវបានរក្សាទុកនៅលើដីក្នុងប្រព័ន្ធអេកូឡូស៊ី។ រូបភាពខាងក្រោមនេះបង្ហាញពីការផ្ទុកកាបោនសកលនៅក្នុងរុក្ខជាតិខាងលើនិងខាងក្រោមដី ។

[1] United Nations Food and Agriculture Organization (FAO) Global Forest Resources Assessment 2005

(WRIhttp://earthtrends.wri.org/maps_spatial/maps_detail_static.php?map_select=227&theme=3).




ព្រៃឈើកាបោន **Forest Carbon Pools** (Source: ipcc, http://www.ipcc.ch/ipccreports/sres/land_use/index.php?idp=131)

អាងស្តុកកាបោនព្រៃឈើ រួមមាន ជីវម៉ាសនៅលើ និងក្រោមដី ឈើងាប់ និងជាតិកាបោននៃដី។

**ជីវម៉ាសរស់៖** ផ្នែកនៅលើដី (ខ្នែង មែក ស្លឹក ផ្កា និងផ្លែ) និងផ្នែកនៅក្រោមដី (ឫស)។ កម្រិត និងល្បឿន នៃការស្រូបយកកាបោនរបស់ជីវម៉ាសរស់ អាស្រ័យលើប្រភេទ ជាតុអាកាស និងគុណភាពដី។ ជួនកាលទោះបីជាព្រៃឈើ នៅបន្តលូតលាស់ ក៏ជីវម៉ាសព្រៃឈើនេះមិនអាចស្រូបកាបោនបន្តទៀតទេ នៅពេលដែលវាកើនដល់កម្រិតអតិបរមា។ ព្រៃឈើអាចឈានដល់កម្រិតអតិបរមានៃកម្រិតស្តុកកាបោន ក្នុងរយៈពេលជាច្រើនទសវត្ស ឬសតវត្ស។ កម្រិតស្តុក កាបោននេះក៏អាស្រ័យលើការគ្រប់គ្រងធនធានព្រៃឈើនោះ។ កាបោនស្តុកមានកម្រិតខ្ពស់នៅក្នុងជីវម៉ាសរស់នៃ តំបន់ ព្រៃដែលសំបូរឈើថ្មី (ឈើអាយុតិច)។ ប្រសិនបើមិនមានការគណនាកម្រិតស្តុកកាបោន ដែលមាននៅក្នុងជីវម៉ាស រស់ផ្នែកក្រោមដីទេ ការបញ្ចេញឧស្ម័ន អាចត្រូវរាយការណ៍ក្នុងកម្រិតទាបជាងភាពជាក់ស្តែង។ ជាពិសេសនៅ ក្នុង ករណីនៃការដាំដុះ និងស្តារព្រៃឈើឡើងវិញ ការរាយការណ៍ពីកម្រិតនៃការស្រូបយកកាបោន អាចទាបជាងភាព ជាក់ស្តែង។

***កំទិចកំទីសម្រាម*** ៖ បន្ទាប់ពីការបង្កើតតំបន់ព្រៃឈើថ្មី កាបោនមាននៅក្នុងសំរាមនិងកំទេចកំទីឈើនានា( សារធាតុ សរីរាង្គស្លាប់) មានការកើនឡើងទៅតាមពេលវេលា ។ ក្នុងការបាត់បង់ព្រៃឈើ បរិមាណដ៏ច្រើននៃកំទេចកំទីត្រូវបានបង្កើតជាធម្មតានៅពេលដើមឈើបានកាប់រំលំ ។ បរិមាណដែលនៅសេសសល់លើដីអាចមានបរិមានតិចតួច ប្រសិនកំ

ទេចកំទីត្រូវបានដុត ឬបានយកចេញពីតំបន់នោះ ប៉ុន្តែអាចមានកំទេចកំទីជាច្រើនបានរក្សាទុកនៅក្នុងតំបន់ ប្រសិនបើដើមឈើមិនត្រូវបានកាប់រំលំ ប៉ុន្តែគ្រាន់តែបានសម្លាប់ដោយចាក់ថ្នាំគីមី។

***ដី:*** នៅលើដីដែលពីមុនធ្លាប់បានដាំដុះដំណាំនានា តែបានធ្វើអោយមានព្រៃឈើថ្មីឡើងវិញ សារជាតុសរីរាង្គដីនានា ត្រូវបានគេរំពឹងថានឹងមានការកើនឡើង កើនឡើងដោយប្រើពេលវេលាពី មួយទសវត្សទៅសតវត្ស (O'Connell និង Sankaran ឆ្នាំ 1997) ។ សារជាតុសរីរាង្គដីនឹងថយចុះយ៉ាងឆាប់រហ័សប្រសិនបើមានការបាត់បង់ព្រៃឈើ ប្រសិនបើដីត្រូវបានគេដាំដុះជាបន្តបន្ទាប់ ការផ្លាស់ប្តូរនៅក្នុងសារជាតុសរីរាង្គដីទំនងជាមានទំហំតូចប្រសិនបើដីមិនត្រូវបានដាំដុះ។

## សេវាកម្មអេកូស៊ីស្តែម

មានសម្ភារៈ និងសេវាកម្មនានាដែលមានសារៈសំខាន់សម្រាប់ជីវិតមនុស្សដែលអាចទាញយកពីព្រៃឈើ និង អេកូស៊ីស្តែម ។ សហគមន៍មូលដ្ឋានដែលរស់នៅជិតតំបន់ទីជម្រេលនានាបាន និងកំពុងប្រើប្រាស់ និងលក់ដូរនូវផលិតផលនានា អស់រយៈពេលជាច្រើនទសវត្សរ៍មកហើយ(ដូចជា អុស ចំណីអាហារសត្វ ឈើ ឱសថបូរាណជាដើម)។ លើសពីនេះទៀត ក៏នៅមានសេវាកម្មដោយប្រយោលនានាផងដែរ ដូចជា ព្រៃឈើនៃតំបន់ ទីជម្រេលនានាដែលអាចជួយក្នុងការការពារការហូរច្រោះ និងការបង្កើននូវ ការប្រភពទឹក ។ តាមរយៈនេះ សហគមន៍នានាដែលរស់នៅខ្សែទឹក ខាងក្រោមអាចទទួលបាននូវផលប្រយោជន៍ជាច្រើន។ដូចគ្នានេះដែរ ការអភិរក្ស និងការគ្រប់គ្រងធនធានព្រៃឈើបានជួយក្នុងការអភិរក្ស និងការធ្វើអោយប្រសើរឡើងនូវជីវៈចម្រុះ ។លើសពីនេះទៀត ដោយសារ តែព្រៃឈើ និង អេកូស៊ីស្តែមផ្តល់នូវសម្រស់ធម្មជាតិដែលបានជួយដល់ ការជម្រុញអោយមានជាទេសចរណ៍ធម្មជាតិផងដែរ ។



ព្រៃឈើក៏បានដើរតួនាទីយ៉ាងសំខាន់ក្នុងការកាត់បន្ថយនូវការប្រែប្រួលអាកាសធាតុដោយសារតែបានរក្សាទុកនូវឧស្ម័នកាបូនិកក្នុងបរិយាកាសដោយបានរក្សាទុកនូវឧស្ម័នទាំងនេះដូចជាជីវម៉ាស់ ។ ដោយទទួលស្គាល់នូវភាពសំខាន់នៃសេវាកម្មបរិស្ថានចំពោះជីវិតរបស់មនុស្ស ការបង់ថ្លៃសេវាកម្ម បរិស្ថាននានាត្រូវបានផ្តួចផ្តើមឡើងក្នុងការសិក្សាមួយចំនួន ។

យោងតាមការស្រាវជ្រាវរបស់ **Wunder** ក្នុងឆ្នាំ 2005, តាមរយៈសេវាកម្មនានាដែលបានគ្រប់គ្រង ក្រោមការ បង់សេវាកម្មបរិស្ថានរួមមាន ៖

- ការស្រូប និងស្តុកកាបោន Carbon sequestration and stock
- សេវាកម្មទីជម្រេល Watershed Services

- ➢ សេវាកម្មជីវៈចម្រុះ Biodiversity Services
- ➢ សម្រស់ធម្មជាតិ Natural Beauty

## វាយតម្លៃ

វាយតម្លៃមេរៀនដោយសួរនូវសំណួរដូចខាងក្រោម ៖

- លើកនូវមូលហេតុ៣នៃការបាត់បង់ និងរេចរិលព្រៃឈើនៅតាមតំបន់ដែលអ្នករស់នៅ
- តើមានភាពប្រឈមអ្វីខ្លះ និងជម្រើសនានាដើម្បីបញ្ឈប់នូវការបាត់បង់ និងរេចរិលព្រៃឈើ ?

## សន្និដ្ឋាន

នាពេលបច្ចុប្បន្ន កម្ពុជាបានទទួលរងនូវការបាត់បង់ព្រៃឈើប្រមាណ ២ភាគរយក្នុងមួយឆ្នាំ ។ ការបាត់បង់ ព្រៃឈើកើតមានក្នុងអត្រាមួយខ្ពស់បំផុត ហើយអត្រានៃការបាត់បង់នេះមានភាពខុសគ្នាទៅតាមតំបន់ក្នុង ប្រទេស កម្ពុជា ដោយសារតែកត្តាផ្សេងៗគ្នា ដូចជា កាត់កាប់ព្រៃយកដីធ្វើចំការ សកម្មភាពកាប់ឈើអនាធិបតេយ្យ កំសោយ ភាពនៃអភិបាលកិច្ច និងអំពើពុករលួយ មានតម្រូវការខ្ពស់លើការប្រើប្រាស់ផលិតផលព្រៃឈើដែលធ្វើ អោយការនៃ ការបាត់បត់ និងរេចរិលព្រៃឈើមានដំណើរការយ៉ាងរហ័សនាពេល បច្ចុប្បន្ន។

# កត្តាដែលធ្វើឲ្យ បាត់បង់ព្រៃឈើ និងរេចរឹលព្រៃឈើ

## កត្តាជម្រុញឲ្យបាត់បង់ព្រៃឈើ និងរេចរឹលព្រៃឈើក្នុងព្រះរាជាណាចក្រកម្ពុជា

ប្រទេសកម្ពុជាត្រូវបានចាត់ទុកថាជាប្រទេសមួយដែលមាន ព្រៃឈើគ្របដណ្តប់ច្រើន ហើយក៏ ជាប្រទេស មួយដែលមានការបាត់បង់ព្រៃឈើច្រើនជាងគេផងដែរ[2] ។

## កត្តាជម្រុញឲ្យបាត់បង់ព្រៃឈើ និងរេចរឹលព្រៃឈើដែលបានរកឃើញតាមរយៈវេទិកាផ្សព្វផ្សាយផែនទីបង្ហាញផ្លូវដែលបូក

| | នៅក្នុងវិស័យព្រៃឈើ | នៅក្រៅវិស័យព្រៃឈើ |
|---|---|---|
| ផ្ទាល់ | • ការកាប់ឈើដោយគ្មាននិរន្តរភាពនិងល្មើសច្បាប់<br>• ភ្លើងព្រៃ (មិនទាន់ឯកភាពគ្នា)<br>• ការកាប់អុសដោយគ្មាននិរន្តរភាព | • ការរានឆ្ការសម្រាប់ធ្វើកសិកម្ម<br>• ការពង្រីកកន្លែងតាំងទីលំនៅ<br>• ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ |
| ប្រយោល | • ខ្វះការកំណត់តំបន់ព្រៃ<br>• សមត្ថភាពស្ថាប័នមានកម្រិតទាប និងការអនុវត្តគោលនយោបាយនៅទន់ខ្សោយ<br>• ការអនុវត្តច្បាប់ស្តីពីព្រៃឈើមិនទាន់ម៉ត់ចត់<br>• អភិបាលកិច្ចវិស័យព្រៃឈើនៅទន់ខ្សោយ<br>-ការចូលរួមនៃអ្នកពាក់ព័ន្ធនៅមានកម្រិតទាប<br>-ខ្វះតម្លាភាពនិងគណនេយ្យភាព<br>-ការវាយតម្លៃមិនគ្រប់ជ្រុងជ្រោយអំពីផលប៉ះពាល់សង្គមនិងបរិស្ថាន<br>• ខ្វះប្រភពអុសនិងឈើជំនួសដែលមាននិរន្តរភាព រួមទាំងថាមពលអុសសម្រាប់បំពេញតាមតម្រូវការ<br>• តម្រូវការថាមពលអុសសម្រាប់ប្រើប្រាស់តាមផ្ទះនិងក្នុងឧស្សាហកម្ម<br>• ប្រសិទ្ធភាពទាបនៃការបម្លែងឈើនិងការប្រើប្រាស់សម្រាប់សាងសង់ ការផលិតថាមពល។ល។<br>• ខ្វះការលើកទឹកចិត្តដែលជម្រុញការគ្រប់គ្រងព្រៃឈើឲ្យមាននិរន្តរភាព<br>• ខ្វះហិរញ្ញវត្ថុដើម្បីគាំទ្រការគ្រប់គ្រងព្រៃឈើឲ្យមាននិរន្តរភាព | • កំណើនចំនួនប្រជាជន<br>• ភាពក្រីក្រ<br>• កំណើនប្រាក់ចំណូលនិងតម្រូវការធនធាន<br>• កំណើនភាពងាយចូលក្នុងតំបន់ព្រៃឈើ<br>• ទិន្នផលកសិកម្មមានកម្រិតទាប<br>• ចំណាកស្រុកចូលក្នុងតំបន់ព្រៃឈើ<br>• ការតាំងទីលំនៅថ្មី ដែលរួមទាំង ក្នុងតំបន់ជាប់ព្រំដែន<br>• ការអភិវឌ្ឍឧស្សាហកម្មទ្រង់ទ្រាយធំ (ដែលរួមទាំងសម្បទានដីសេដ្ឋកិច្ចនិងសង្គមកិច្ច និងសម្បទានដទៃទៀត)<br>• ការជួញដូរដីធ្លី<br>• តម្រូវការធនធាននៅកម្រិតតំបន់<br>• បទប្បញ្ញត្តិ ESIA នៅទន់ខ្សោយនិងខ្វះការអនុវត្ត<br>• អភិបាលកិច្ច<br>-ភាពមិនច្បាស់លាស់នៃកម្មសិទ្ធិលើដីព្រៃ – ទន់ខ្សោយបំផុតនៅក្នុងព្រៃឈើនិងតំបន់ដទៃទៀតនៅក្រៅដីលំនៅស្ថាន និងដីដាំដំណាំ<br>-ការទន្ទ្រានយកដីជាកម្មសិទ្ធិ<br>-ការអនុវត្តច្បាប់នៅមានភាពទន់ខ្សោយ<br>-ការចុះបញ្ជីដីធ្លីនៅមានកម្រិតកំណត់ (កម្មសិទ្ធិឯកជន |

[2] Griscom, B., Shoch, D., Standley, B., Cortez, R. and Virgilio, N. 2009. Sensitivity of amounts and distribution of tropical forest carbon credits depending on baseline rules. Environmental Sciences and Policy 12:897-911.

| | | |
|---|---|---|
| | • សកម្មភាពរបស់ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរមូលដ្ឋាន និងសហគមន៍មូលដ្ឋាន។ | និងរដ្ឋ)<br>-ការកសាងផែនការប្រើប្រាស់ដីធ្លីនៅពុំទាន់គ្រប់គ្រាន់<br>-សមត្ថកិច្ចត្រួតគ្នា/មិនច្បាស់លាស់<br>• និយាមសង្គម (សិទ្ធិភោគៈតាមរយៈការប្រើប្រាស់)<br>• ផលប្រយោជន៍សេដ្ឋកិច្ចនៅថ្នាក់ជាតិពីការគ្រប់គ្រងព្រៃឈើដោយនិរន្តរភាពច្រើនតែទាបជាងការប្រើប្រាស់ដីតាមជម្រើសផ្សេង<br>• ថ្លៃឱកាសនៃការគ្រប់គ្រងព្រៃឈើដោយនិរន្តរភាពនៅមូលដ្ឋាន<br>• ការយល់ដឹងពីតួនាំទីព្រៃឈើក្នុងបរិស្ថាននៅមានកម្រិតទាប។ |

ប្រភព៖ ផែនទីបង្ហាញផ្លូវ (២០១១)

## យុទ្ធសាស្ត្រជាគោលសម្រាប់កាត់បន្ថយការបាត់បង់ និងរេចរឹលព្រៃឈើ

មានជំហាននានាដែលត្រូវអនុវត្តសម្រាប់ការកាត់បន្ថយការបាត់បង់ និងរេចរឹលព្រៃឈើ ដែល ជំហានទាំងនេះមានដូចខាងក្រោម ៖

### សកម្មភាពក្រៅពីព្រៃឈើ

ដោះស្រាយកត្តាជម្រុញនានាដែលនាំអោយមានការបាត់បង់ព្រៃឈើ។ ការពង្រីកតំបន់ សម្រាប់កសិកម្មទៅក្នុងតំបន់ព្រៃឈើនៅដែលជាកត្តាជម្រុញដ៏សំខាន់នៃការបាត់បង់ និងរេចរឹលព្រៃឈើលើពិភពលោក ។ ប្រការនេះគឺការពង្រីកដីព្រៃសម្រាប់វិស័យកសិកម្មខ្នាតធំឬការងារកសិកម្មចិញ្ចឹមជីវិតខ្នាតតូច។ ការពង្រីកតំបន់ទីក្រុង និងហេដ្ឋារចនាសម្ព័ន្ធ ផ្លូវថ្នល់ ទំនប់ និងការរុករករ៉ែគឺជាកត្តាចំបងដ៏សំខាន់ផ្សេងទៀតនៃការបាត់បង់ព្រៃឈើ ។ ប្រជាជននៅពិភពលោកត្រូវបានរំពឹងថានឹងកើនឡើងរហូតដល់ ៩ ពាន់លាននាក់នៅត្រឹមឆ្នាំ ២០៥០ ដែលនឹងដាក់សម្ពាធបន្ថែមទៀតលើធនធានព្រៃឈើ។ នៅក្នុងតំបន់អាស៊ីអាគ្នេយ៍ ចំនួនប្រជាជនត្រូវបានគេរំពឹងថានឹងកើនឡើងពី ៥៩៣ លាននាក់នៅឆ្នាំ ២០១០ ដល់ ៧៥៩ លាននាក់នៅក្នុងឆ្នាំ ២០៥០[3]។

ដើម្បីដោះស្រាយកត្តាជម្រុញទាំងនេះ មានតម្រូវការសម្រាប់ការរៀបចំ និងបន្សាំផែនការនៃការប្រើប្រាស់ដីអោយកាន់តែប្រសើរឡើង និងការប្រើប្រាស់ធនធានអោយមានប្រសិទ្ធភាពបន្ថែមទៀត ការបង្កើនភាពធន់ ទ្រាំនៃផលិតផលកសិកម្មនិងបង្កើនផលិតភាពកសិកម្ម កាត់បន្ថយកាកសំណល់និងបង្កើនការកែច្នៃនូវផលិតផល សម្រាប់ការប្រើប្រាស់ឡើងវិញ ។ ប្រការនេះនឹងតម្រូវឱ្យមានការវិនិយោគនៅកម្រិតថ្នាក់ជាតិ និងមូលដ្ឋាន ព្រមទាំងការផ្ទេរបច្ចេកវិទ្យានៅក្នុងវិស័យជាច្រើនផ្សេងគ្នា រួមទាំងវិស័យកសិកម្ម ។

### ក្នុងវិស័យព្រៃឈើ

**កិច្ចការពារព្រៃឈើ** ៖ ការបង្កើត និងគ្រប់គ្រងតំបន់ឧទ្យានជាតិ ឬតំបន់ការពារធម្មជាតិ ឬការរៀបចំតំបន់ (Zone) ឬការកំណត់តំបន់ព្រៃឈើដោយផ្តោតលើការប្រើប្រាស់នានា ។ តំបន់អេកូស៊ីស្តែមដែលមាន សារៈសំខាន់ និងកំពុងទទួលរងការគំរាមកំហែងត្រូវធ្វើការរក្សាទុក និងដាក់យុទ្ធសាស្ត្រនានាសម្រាប់ការត្រួតពិនិត្យ និងគ្រប់គ្រងអោយបានត្រឹមត្រូវនូវប្រព័ន្ធអេកូឡូស៊ីនៃតំបន់បម្រុងនោះអោយបានត្រឹមត្រូវ។ ជាទូទៅ ប្រជាជនដែលរស់ នៅក្នុងតំបន់នេះត្រូវបានគេជម្លាសចេញពីតំបន់នេះ ។

---

[3] Turn down the heat. World Bank 2013.

**ការគ្រប់គ្រងព្រៃឈើដោយនិរន្តរភាព** Sustainable Forest Management (SFM)៖ ការទទួលខុសត្រូវ និងការប្រើប្រាស់ព្រៃឈើក្នុងរបៀបមួយដែលអាចរក្សាជីវចំរុះ ផលិតភាព ការបង្កើតឡើងវិញនូវសមត្ថភាពនិងសក្តានុពលរបស់ ព្រៃឈើក្នុងការបំពេញមុខងារនានាដែលទាក់ទងនឹងអេកូឡូស៊ី សេដ្ឋកិច្ច និងសង្គម ដោយមិនបង្កអោយមានការខូចខាតដល់ប្រព័ន្ធអេកូឡូស៊ីផ្សេងទៀត (និយមន័យអង្គការ FAO) ។

ការគ្រប់គ្រងព្រៃឈើដោយនិរន្តភាពសម្រេចបាននូវតុល្យភាពរវាងតម្រូវការរបស់ប្រជាជននិងការអភិរក្សរយៈពេលវែងនូវសុខភាពព្រៃឈើ និងអេកូឡូស៊ី ។

ប្រការនេះ អាចត្រូវធ្វើការរួមបញ្ចូលនូវវិធីសាស្ត្រជាច្រើន ដូចជា សហគមន៍ព្រៃឈើ សហគមន៍តំបន់ការពារធម្មជាតិ សហគមន៍នេសាទ ។ល។ ការបែងចែកតំបន់ព្រៃឈើសម្រាប់ការប្រើប្រាស់ច្រើនយ៉ាង និងការ កាត់បន្ថយផលប៉ះពាល់នៃការកាប់ឈើ ។

**ការបង់សេវាកម្មបរិស្ថាន** (Payment for Environmental Services (PES): PES គឺជាប្រភេទនានានៃការប្រើប្រាស់យន្តការទីផ្សាររវាងអ្នកទិញ (អ្នកដែលទទួលបានផលប្រយោជន៍ពីសេវាបរិស្ថាន ដូចជាប្រជាជនតាមទីក្រុងពោលគឺអ្នកដែលចង់បានទឹកស្អាត) និងអ្នកលក់ (អ្នកដែលគ្រប់គ្រងសេវាកម្ម បរិស្ថាននានាពោលគឺសហគមន៍តំបន់ខ្ពង់រាបដែលប្រកបរបរកសិកម្ម និងកំពុងរស់នៅក្បែរប្រភពទឹក) ។

# **សេចក្តីផ្តើមនៃ** REDD **និង** REDD+

ភស្តុតាងវិទ្យាសាស្ត្របានលើកឡើងថា ឧស្ម័នផ្ទះកញ្ចក់ជាពិសេសកាបោនឌីអុកស៊ីតមានតួនាទី យ៉ាងសំខាន់ក្នុងការធ្វើអោយមានកំនើនជាមធ្យមនូវ កំដៅនៅពិភពលោកក្នុងកំឡុងពេលប៉ុន្មានទសវត្សចុងក្រោយនេះ ។ ព្រៃឈើអាចធ្វើអោយមានទាំងការកើនឡើង និងថយចុះនូវឧស្ម័នកាបូនិកដែលមាននៅក្នុងបរិយាកាស ដោយព្រៃឈើបានដើរតួនាទីជាអាងស្តុកកាបោន ដោយបានស្រូបយកនូវឧស្ម័នកាបូនិកពីបរិយាកាស ។ មួយវិញទៀត នៅពេលដែលព្រៃឈើត្រូវបានកាប់ និងដុតបំផ្លាញ វានឹង ធ្វើអោយមានការបំភាយនូវឧស្ម័នកាបូនិកដ៏សន្ធឹកសន្ធាប់ ដូច្នេះ ការ ថែរក្សា និងការដាំដុះព្រៃឈើឡើងវិញគឺជាមធ្យោបាយដ៏មានសារសំខាន់ក្នុងការកាត់បន្ថយការប្រែប្រួលអាកាសធាតុ ។

តើ REDD+ ជាអ្វី?

R (Reducing) = ការកាត់បន្ថយ

E (Emission) = ការបំភាយឧស្ម័នពី

D (Deforestration) = ការបាត់បង់ និង

D (Degradation) = រេចរិលព្រៃឈើ

\+

ការអភិរក្សព្រៃឈើធម្មជាតិ

ការគ្រប់គ្រងព្រៃឈើអោយមាននិរន្តភាព និង

សមត្ថភាពនៃការស្រូបយកនូវឧស្ម័នកាបូនិករបស់ព្រៃឈើគឺអាស្រ័យទៅលើការគ្រប់គ្រងព្រៃទាំងនេះ ។ ការគ្រប់គ្រងព្រៃឈើបានល្អបានជួយដល់ សមត្ថភាព នៃការស្រូបយកនូវឧស្ម័នកាបូនិករបស់ព្រៃឈើ និងកសាងសមត្ថភាពនៃសហគមន៍នានាដែលពឹងអាស្រ័យ លើព្រៃ ឈើក្នុងការផ្តល់នូវសេវាកម្ម បរិស្ថានសំខាន់ៗនានា ។ ដោយពិចារណាលើកត្តាទាំងនេះ យន្តការមួយត្រូវបាន ស្នើឡើងនៅថ្នាក់ សាកលលោកដែលហៅថា **ការកាត់បន្ថយការសាយភាពឧស្ម័នពីការបាត់បង់ និងរេចរិលព្រៃឈើ** (Reducing Emissions from Deforestration and Forest Degradation - REDD) ។ នៅក្រោមយន្តការនេះ ប្រទេសនានាដែលមានការបំភាយឧស្ម័នក្នុងកម្រិតខ្ពស់ (ដូចជា ប្រទេសអភិវឌ្ឍន៍នានា)នឹងផ្តល់ នូវហិរញ្ញប្បទាន ដល់ប្រទេសកំពុងអភិវឌ្ឍសម្រាប់កិច្ចការពារ និងដាំដុះព្រៃឈើរបស់ពួកគេ ដោយហេតុនេះអាចកាត់បន្ថយការ បាត់បង់ និងរេចរិលព្រៃឈើ និងអាចបង្កើននូវការស្រូបកាបោន ។ ដូច្នេះ គោលបំណងនៃ (REDD) គឺដើម្បី បន្ថយនូវការបំភាយនូវឧស្ម័នពីព្រៃឈើដោយផ្តល់នូវផលប្រយោជន៍សេដ្ឋកិច្ចនានាដល់អ្នកអនុវត្តនូវការងារនេះ ។

ប្រការនេះត្រូវបានគេរំពឹងទុកថា ហិរញ្ញប្បទានដែលជាផលប្រយោជន៍នេះនឹងអាចពង្រីកនូវការគ្រប់គ្រងព្រៃឈើដោយនិរន្តភាព និងបង្កើននូវការចិញ្ចឹមជីវិតរបស់ប្រជាសហគមន៍ដែលមានការពឹងអាស្រ័យលើព្រៃឈើទាំងនេះ ។ ដើម្បីធ្វើអោយប្រាកដថា ផលប្រយោជន៍ទាំងនេះនៅតែបន្តទទួលបាន ជាការសំខាន់ណាស់ដែលត្រូវតែបន្តនូវការកាត់បន្ថយការបំភាយនូវឧស្ម័នដោយសារតែការបាត់បង់ និង រេចរិលព្រៃឈើ និងបង្កើននូវការ ស្តុកកាបោន ។

ទស្សនទាននៃ REDD បានឈានរហូតដល់ REDD+ ដែលទំហំនៃការអនុវត្ត REDD ពីមុន មានដែនកំណត់ដោយគិតគូរត្រឹមតែការបាត់បង់ និងរេចរិលព្រៃឈើ ប៉ុន្តែចំពោះការអនុវត្ត REDD+ ក៏បានរួមបញ្ចូលផងដែរដល់ការគ្រប់គ្រងព្រៃឈើដោយនិរន្តភាព និងបង្កើននូវការស្តុកកាបោនព្រៃឈើ ។

## ការវិវត្តនៃ REDD+ និងភាពប្រឈមនានា

ជាគំនិតដើម REDD+ ត្រូវបានចាត់ទុកថាជាយន្តការសេដ្ឋកិច្ចមួយដែលមានតម្លៃថោក មានភាពងាយស្រួល និងអាចជឿជាក់បាន ដែលអាចកាត់បន្ថយនូវបរិមាណនៃឧស្ម័នកាបូនិកយ៉ាងច្រើននៅក្នុងបរិយាកាស ។ ទោះជាយ៉ាងណាក៏ដោយ ក៏នៅមានការជជែកវែកញែកជាច្រើននៅថ្នាក់ជាតិ និងអន្តរជាតិនានាទាក់ទងនឹង យន្តការនៃការអនុវត្តដែលមានភាពសមស្របមួយ ។

ជាដំបូង ជាការចាំបាច់ដែលត្រូវយល់ដឹងអំពីមូលដ្ឋាននានាអំពីដំណើរការនៃការរៀបចំគោលនយោបាយនានាអំពី REDD+ ដូចខាងក្រោម ៖

- តើទស្សនទាននៃ REDD និង REDD+ មានការវិវត្តដោយរបៀបណា ហើយតើវាបានបន្តពង្រីក ដោយរបៀបណា?
- តើ REDD+ រួមចំណែកដល់ការធ្វើអោយប្រសើរឡើងដល់ការចិញ្ចឹមជីវិត ការអភិរក្សជីវចម្រុះ និងសមធម៌ និងនិរន្តរភាពនៃការអភិវឌ្ឍសង្គមដោយរបៀបណា ?
- តើជំហ៊ាន និងចំណុចសំខាន់ៗអ្វីខ្លះដែលត្រូវធ្វើការគិតគូរក្នុងដំណើរការនៃការអនុវត្តដើម្បី ទទួលបាននូវសមិទ្ធិផលខាងលើនេះ ?

ក្រោយពេលដែលសាកលលោកទទួលស្គាល់នូវតម្រូវការចាំបាច់ទាំងនេះសម្រាប់ការរៀបចំសកម្មភាពនានាក្នុងការកាត់បន្ថយនូវការបញ្ចេញឧស្ម័ននានា ប្រទេសនានាឯកភាពគ្នាក្នុងការផ្តួចផ្តើមនូវសកម្មភាពកាត់បន្ថយនានាតាមរយៈពិធីសារក្យូតូដែលបានរៀបចំកាលពីឆ្នាំ ១៩៩៧ ។ ទស្សនទាននៃការកាត់បន្ថយការបំភាយឧស្ម័នតាមរយៈការប្រើប្រាស់ដី ការប្រែប្រួលលើការ ប្រើប្រាស់ដី និងដីព្រៃឈើ (LULUCF) បានចាប់កំណើតឡើង ។ ចំណុចនេះរួមមាននូវការកាត់ បន្ថយ ការបំភាយឧស្ម័ន និងការស្តុកកាបោននៃវិស័យព្រៃឈើតាមរយៈសកម្មភាពនានា ។ ទោះជាយ៉ាង ណាក៏ ដោយ ការសំរេចចិត្តលើសកម្មភាពណាដែលត្រូវធ្វើការពិចារណា ហើយថាតើការបំភាយឧស្ម័នពីការ ប្រើប្រាស់ដីនេះត្រូវ ធ្វើការវាស់វែងដោយរបៀបណាអោយមានប្រសិទ្ធិភាពនៅមិនទាន់ច្បាស់លាស់នៅឡើយ ។ ដូច្នេះ យន្តការអភិវឌ្ឍ ស្អាតបានស្នើឡើង ហើយត្រូវបានផ្តល់ការអនុញ្ញាតិសម្រាប់ការអនុវត្ត ។ យន្តការអភិវឌ្ឍន៍ស្អាត (CDM) គ្រាន់តែ ផ្តល់ការគាំទ្រសម្រាប់តែគម្រោងដាំដុះ និងស្តារព្រៃឈើឡើងវិញ ។ ការបាត់បង់និងរេចរិលព្រៃឈើ មិនត្រូវបាន គេពិចារណានោះទេដោយសារតែបញ្ហាបច្ចេកទេសជុំវិញការវាស់វែង និងគណនេយ្យភាពសម្រាប់ការ លេចធ្លាយនូវ ការ បំភាយឧស្ម័នកាបោន ។

CDM មិនបានឆ្លើយតបចំពោះការរំពឹងទុកក្នុងវិស័យព្រៃឈើនោះទេ ។ ប្រទេសកំពុងអភិវឌ្ឍ ដូចជា កម្ពុជាទទួលបានគម្រោង CDM តិចតួចសម្រាប់ការងារព្រៃឈើ ចំណែកប្រទេសឥណ្ឌា និងប្រទេសចិន គឺជា ប្រទេសដែលទទួលបាននូវគម្រោងយន្តការស្អាតវិស័យព្រៃឈើនេះច្រើនជាងគេ ។ ជាលទ្ធផល សហភាពអឺរ៉ុប បាន ផ្តល់

ភាពសំខាន់ចំពោះការចូលរួមរបស់ប្រទេសកំពុងអភិវឌ្ឍន៍ក្នុងសកម្មភាពបំភាយឧស្ម័ននានាដែលពាក់ព័ន្ធ ។ ទស្សនទាននៃការកាត់បន្ថយការបំភាយឧស្ម័នពីការបាត់បង់ព្រៃឈើបានស្នើឡើងដោយប្រទេសកូស្តារីការ និង ប្រទេស ប៉ាពួនូហ្គីនី PNP ក្នុងសន្និសិទ្ធបណ្តាភាគី (Conferences of the Parties (COP) លើកទី ១១ នាទីក្រុងម៉ុងរ៉េអាល់នៃប្រទេសកាណាដា ។ ទស្សនទាននេះបានទទួលយកទៅអនុវត្តដោយយកចិត្តទុក ដាក់នូវ ភាពសំខាន់នៃការរួមចំណែករបស់ប្រទេសកំពុងអនុវត្តនានាក្នុងការបំភាយឧស្ម័នផ្សេងៗ ជាពិសេសឧស្ម័នពីការបាត់បង់ និងរេចរិលព្រៃឈើ ។

របាយការណ៍មួយដែលបានសរសេរដោយសេដ្ឋវិទូជនជាតិអង់គ្លេសលោក Nicholas Stern ក្នុងឆ្នាំ ២០០៦ បានសន្និដ្ឋានថា ការអភិរក្សព្រៃឈើគឺវិធីមួយដែលមានប្រសិទ្ធភាពសេដ្ឋកិច្ចយ៉ាងច្រើនសម្រាប់ការកាត់ បន្ថយការប្រែប្រួលអាកាសធាតុ ។របាយកាណ៍នោះបានសង្កត់ធ្ងន់ថា ការបាតបង់ និង រេចរិលព្រៃឈើបានរួម ចំណែកច្រើនជាងការបំភាយឧស្ម័នផ្ទះកញ្ចក់ពីវិស័យគមនាគមន៍ទូទាំងសាកលោក ប្រចាំឆ្នាំ ។

កិច្ចប្រជុំ COP លើកទី១៣ ដែលបានរៀបចំឡើងនៅទីក្រុងបាលី នៃប្រទេសឥណ្ឌូនេស៊ី ក្នុងឆ្នាំ ២០០៧ បានធ្វើការពិភាក្សាយ៉ាងលំអិតអំពីអនុសាសន៍ដែលបានលើកឡើងនៅក្នុងរបាយការណ៍របស់សេដ្ឋវិទូ Stern ហើយ បានទទួលនូវយន្តការមួយថ្មីសម្រាប់ការកាត់បន្ថយការបំភាយឧស្ម័នពីការបាត់បង់ និងរេចរឹលព្រៃឈើ ។ ក្រោម យន្តការនេះ អ្នកដែលបំភាយឧស្ម័នច្រើនត្រូវធ្វើការទូទាត់ដល់ប្រទេសកំពុងអភិវឌ្ឍដែលបានកាត់បន្ថយ ការបាត់ បង់ និងរេចរឹលព្រៃឈើ ។ ទស្សនទាននេះត្រូវបានគេស្គាល់ថា ការកាត់បន្ថយការបំភាយឧស្ម័ន ពីការ បាត់បង់ និងរេចរឹលព្រៃឈើ (REDD) ។

នៅក្នុងកិច្ចប្រជុំ COP លើកទី 16 កាលពីខែធ្នូ ឆ្នាំ២០១០ យន្តការរេដបូក ត្រូវបានអនុម័តជាផ្លូវការដោយរួមបញ្ចូលនូវសកម្មភាពមួយចំនួនដូចខាងក្រោម៖

- កាត់បន្ថយការបញ្ចេញឧស្ម័នកាបោនដោយបញ្ឈប់ការបាត់បង់ព្រៃឈើ
- កាត់បន្ថយការបញ្ចេញឧស្ម័នកាបោនដោយបញ្ឈប់ការរេចរឹលព្រៃឈើ
- ការអភិរក្សព្រៃឈើ (កាបោនស្តុក) និងនិរន្តភាពនៃការគ្រប់គ្រងព្រៃឈើ
- បង្កើនការស្តុកកាបោន

ផ្នែកបច្ចេកទេសលំអិតទាក់ទងទៅនឹងការអនុវត្ត REDD+ កំពុងតែស្ថិតនៅក្រោមការអនុវត្តតាម រយៈកិច្ច ប្រជុំប្រចាំឆ្នាំរបស់ UNFCCC ។ ការងារបច្ចេកទេសដែលបានគិតគូរទាំងនេះរួមមាន ប្រព័ន្ធនៃការតាមដានត្រួតពិនិត្យព្រៃឈើ ការធ្វើរបាយការណ៍ទាក់ទងនឹងការធានាសុវត្ថិភាព ការបង្កើតកម្រិតយោង តាមដាន ការរាយការណ៍ និងការធ្វើសុពលភាព (MRV) ការទូទាត់ និងផលប្រយោជន៍នានាដែលមិនមែនជាកាបោន ។ល។ យោងតាមការធ្វើសេចក្តីសម្រេចចិត្តក្នុងកិច្ចប្រជុំ COP ទី ១៩ នៅ វ៉ារសូ (Warsaw) បច្ចុប្បន្ន យើងទទួល បាននូវរាល់តម្រូវការនានាផ្នែកបច្ចេកទេស និងគោលនយោបាយចាំបាច់ដើម្បីអនុញ្ញាតឱ្យការអនុវត្តន៍ REDD + និងការវាយតម្លៃលទ្ធផលរំពឹងទុកនានាសម្រាប់ការសម្រេចចិត្តទាក់ទងទៅនឹងការផ្តល់ហិរញ្ញប្បទាននិងលក្ខខណ្ឌនានាដែលនឹងចែងអំពី។

ប្រទេសកម្ពុជានឹងទទួលបានផលប្រយោជន៍សេដ្ឋកិច្ចសម្រាប់ជាការលើកទឹកចិត្តក្នុងការអនុវត្ត REDD+ ដែលជាការរួមចំណែករបស់ពួកគេក្នុងការអភិរក្សព្រៃឈើ ។ តាមរយៈយន្តការនេះ ប្រទេសកំពុងអភិវឌ្ឍនានា ត្រូវតែធ្វើការបញ្ជាក់អំពីបរិមាណនៃកាត់បន្ថយការបំភាយឧស្ម័នកាបូនិកពីព្រៃឈើរបស់ពួកគេ ។ សម្រាប់ការងារ នេះ ពួកគេត្រូវត្រួតពិនិត្យការបាត់បង់ព្រៃឈើ និងការបង្កើននូវសមត្ថភាពនៃការគ្រប់គ្រងព្រៃឈើរបស់ស្ថាប័ន និងភ្នាក់ងារនានា ។

ការវិវត្តនៃ **REDD+**

| ឆ្នាំ | សមិទ្ធិផលសម្រេចបាន |
|---|---|
| ២០០៥ | • ប្រទេស PNG និងប្រទេសកូស្តារីកាបានដាក់សំណើនៅសន្និបាតសហប្រជាជាតិ ស្តីពីការ ប្រែប្រួលអាកាសធាតក្នុងកិច្ចប្រជុំប្រទេសជាសមាជិកអនុសញ្ញាប្រែប្រួលអាកាសធាតុលើកទី ១១ ក្នុងការពិចារណានូវយន្តការនៃការកាត់បន្ថយការប្រែប្រួលអាកាសធាតុ និងធ្វើការ បញ្ជ្រាបប្រទេសកំពុងអភិវឌ្ឍន៍ក្នុងកិច្ចប្រឹងប្រែងលើការកាត់បន្ថយការប្រែប្រួលអាកាសធាតុ តាមរយៈការកាត់បន្ថយការបាត់បង់ និងរេចរឹលព្រៃឈើ (**RED**) |
| ២០០៦ | • អ្នកវិទ្យាសាស្ត្ររបស់អង្គការ **UNFCCC** និងគណៈកម្មាការប្រឹក្សាយោបល់ បច្ចេកទេសបានបង្ហាញការសិក្សាបច្ចេកទេសមួយ និងអនុសាសន៍របស់ខ្លួនដែលទាក់ទងនឹង របាយការណ៍របស់លោក **Stren** ដោយមានការគាំទ្រពីប្រទេសចំនួន ៨។<br>• មានការឯកភាពក្នុងការផ្តួចផ្តើមពិភាក្សាពីបញ្ញត្តិសំខាន់ៗនានា និងវិធីសាស្ត្រសម្រាប់ការអនុវត្ត REDD ដើម្បីបង្ហាញនៅក្នុងកិច្ចប្រជុំ **COP** លើកទី១៣ នៅទីក្រុងបាលី ។ |
| ២០០៧ | • កិច្ចពិភាក្សាក្នុងកិច្ចប្រជុំ **COP** លើកទី ១៣នៅទីក្រុងបាលី នៃប្រទេសឥណ្ឌូនេស៊ី បានឯកភាពជារួមទាក់ទងនឹង **REDD** ជាលើកទី១។<br>• ធនាគារអភិវឌ្ឍន៍ពិភពលោក បានចាប់ផ្តើមផ្តល់នូវហិរញ្ញប្បទាន ភាពជាដៃគូសម្រាប់កាបោនព្រៃឈើដើម្បីគាំទ្រដល់ការរៀបចំ **REDD** និងកសាងសមត្ថភាពក្នុងប្រទេសអភិវឌ្ឍនានា ។ ដូចគ្នានេះដែរ អង្គការសហប្រជាជាតិចំនួន ៣ គឺ **UNDP, UNEP** និង **FAO** ក៏បានចាប់ផ្តើមកម្មវិធី **UN-REDD** ដែលជាកម្មវិធីរួមគ្នាក្នុងការគាំទ្រដល់ប្រទេសនានាសម្រាប់ដំណាក់កាលត្រៀមលក្ខណៈ |
| ២០០៨ | • ប្រទេសនានាដូចជា ប្រទេសណរវេយ ចក្រភពអង់គ្លេស និងអាល្លឺម៉ង់ បានប្រកាសលើ ការផ្តល់ថវិកាសម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍ក្នុងការជួយពួកគេលើការដោះស្រាយបញ្ហាបាត់បង់ និងរេចរឹលព្រៃឈើ<br>• ការបង្កើតឡើងនូវមូលនិធិនៃហិរញ្ញប្បទានកាបោនព្រៃឈើក្នុងប្រទេសកំពុងអភិវឌ្ឍន៍នានា ។ ឧទាហរណ៍ ហិរញ្ញប្បទានកាបោនរបស់អាហ្វ្រិកានកុងហ្គោ និងហិរញ្ញប្បទានអាមាហ្សូន (Amazon Fund) ។ល។<br>• បណ្តាប្រទេសកំពុងអភិវឌ្ឍន៍នានាបានចូលរួមចំណែកក្នុងដំណាក់កាលត្រៀមលក្ខណៈសម្រាប់ |

| | |
|---|---|
| | **REDD** |
| ២០០៩ | កិច្ចប្រជុំ **COP** លើកទី ១៥នៅទីក្រុងកូពេនហាហ្គិន នៃប្រទេសដាណាមាក បានទទួល ការឯកភាពលើបញ្ហាវិធីសាស្រ្តទាក់ទងទៅនឹង **REDD+** ដោយសង្កត់ធ្ងន់លើការប្រើប្រាស់នូវគោលការណែនាំរបស់ **IPCC** ក្នុងការប៉ាន់ប្រមាណនូវការបំភាយ និងការដកចេញនូវពីវិស័យព្រៃឈើ |
| ២០១០ | កិច្ចប្រជុំ **COP** លើកទី ១៦នៅ **Cancun** នៃប្រទេសម៉ិកសិក្ខ ក្នុងខែវិច្ឆិកា កិច្ចព្រមព្រៀងនៅ **Cancun** បានសម្រេចក្នុងការដាក់បញ្ចូលនូវសកម្មភាពចំនួន ៥ ក្រោម **REDD+** និងការធានាសុវត្ថិភាពចំនួន ៧ ដែលត្រូវដោះស្រាយ និងគោរពតាម ហើយស្នើអោយប្រទេសនានារៀបចំនូវយុទ្ធសាស្រ្តនានាសម្រាប់ **REDD+** ប្រព័ន្ធនៃការត្រួតពិនិត្យព្រៃឈើជាតិ កម្រិតគោល និងកម្រិតយោងនៃការបំភាយពីព្រៃឈើ Forest Reference Emission Levels and Forest Reference Levels ក៏ដូចជាប្រព័ន្ធនៃការផ្តល់ព័ត៌មានទាក់ទងនឹងការធានាសុវត្ថិភាព |
| ២០១១ | • **COP**17 នៅក្នុង **Durban**, អាហ្វ្រិកខាងត្បូងឈានដល់ការសម្រេចចិត្តមួយស្តីពីការណែនាំសម្រាប់ការបង្កើតឡើងនូវកម្រិតនៃការបំភាយចេញពីព្រៃឈើ និងកម្រិតយោងព្រៃឈើ និងស្នើអោយបណ្តាប្រទេសនានាស្នើ ឡើងនូវកម្រិតយោងទៅកាន់ **UNFCCC**<br>• ក្នុងកិច្ចប្រជុំ **COP** 17 ក៏បានទទួលនូវការសម្រេចចិត្តស្តីពីការណែនាំនៅលើប្រព័ន្ធសំរាប់ការផ្តល់ពត៌មានសម្រាប់ការគោរព និងដោះស្រាយលើការធានាសុវត្ថិភាពផងដែរ ។ អំពីហិរញ្ញប្បទានរបស់**REDD+ COP** បានសម្រេចថានឹងត្រូវបានដោះស្រាយការធានាសុវត្ថិភាព និងការគោរពដោយមិនគិតពីប្រភពឬប្រភេទនៃការផ្តល់ហិរញ្ញប្បទាន។ |
| ២០១៣ | **COP**ទី ១៩ នៅ វ៉ារស្សា នៃប្រទេសប៉ូឡូញបានឈានដល់ការសម្រេចចិត្តលើចំណុចដូចខាងក្រោម៖<br>១. ការដោះស្រាយមូលហេតុនៃការបាត់បង់ និងរេចរឹលព្រៃឈើ<br>២. គម្រូសម្រាប់ប្រព័ន្ធការត្រួតពិនិត្យព្រៃឈើថ្នាក់ជាតិ<br>៣. ពេលវេលានិងភាពញឹកញាប់នៃការធ្វើបទបង្ហាញលើសេចក្តីសង្ខេប ព័ត៌មានពីរបៀបលើការធានាសុវត្ថិភាពត្រូវបានដោះស្រាយនិងគោរព<br>៤. គម្រូសម្រាប់ការវាស់វែង រាយការណ៍និងផ្ទៀងផ្ទាត់ (**MRV**)<br>៥. គោលការណ៍ណែនាំនិងនីតិវិធីសម្រាប់ការវាយតម្លៃបច្ចេកទេសលើការដាក់ស្នើរបស់ប្រទេសភាគីអំពីកម្រិតគោលនៃការបំភាយដែលបានស្នើនិង ឬ /កម្រិតគោលព្រៃឈើ<br>៦. គាំទ្រលើការសម្របសម្រួល<br>៧. ការទូទាត់សំណងដោយផ្អែកលើលទ្ធផល |

**ហេតុអ្វីបានជាប្រទេសអភិវឌ្ឍន៍ និងប្រទេសកំពុងអភិវឌ្ឍមានការចាប់អារម្មណ៍ពី REDD+?**

ការបញ្ចៀសនូវគ្រោះមហន្តរាយដោយសារតែការប្រែប្រួលអាកាសធាតុគឺជាគោលដៅចម្បងរបស់ UNFCCC[4]។ បណ្តាប្រទេសនានាយល់ស្របថា យោងទៅតាមគោលការណ៍នៃការទទួលខុសត្រូវជារួម ប៉ុន្តែការទទួលខុសត្រូវ និងសមត្ថភាពរបស់បណ្តាប្រទេសកំពុងអភិវឌ្ឍអាចមានភាពខុសៗគ្នា ដើម្បីប្រឹងប្រែងធ្វើការងារដ៏ធំបំផុតនេះ។ ជាមួយនឹងការបំភាយឧស្ម័នសកលដ៏ធំនេះ ដែលកំពុងតែកើតមានក្នុងប្រទេសកំពុងអភិវឌ្ឍន៍មួយចំនួននាពេលនេះ មានការចាប់អារម្មណ៍យ៉ាងច្រើនក្នុងការគាំទ្រប្រទេសកំពុងអភិវឌ្ឍន៍ដើម្បីកាត់បន្ថយការប្រែប្រួលអាកាសធាតុដោយធ្វើតាមយុទ្ធសាស្ត្រអភិវឌ្ឍន៍ដោយការប្រើប្រាស់កាបូនក្នុងកម្រិតទាប ការកសាងប្រព័ន្ធថាមពលប្រកបដោយប្រសិទ្ធភាព កាត់បន្ថយការបំភាយឧស្ម័នពីការបាត់បង់ព្រៃឈើ ។ល។ មានករណីជាច្រើនប្រការនេះក៏អាចជាវិធីសាស្ត្រដែលមានការចំណាយដ៏មានប្រសិទ្ធិភាពបំផុត ដើម្បីកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ ។

បើទោះបីជាប្រទេសកំពុងអភិវឌ្ឍន៍ ត្រូវធ្វើការអភិរក្ស និងគ្រប់គ្រងព្រៃឈើសម្រាប់ជីវភាពរស់នៅ ផ្ទាល់ខ្លួនរបស់ពួកគេក៏ដោយ តាមរយៈយន្តការ រ៉េដ + ពួកគេអាចទទួលបាននូវការលើកទឹកចិត្តបន្ថែមទៀតសម្រាប់ការអភិរក្សព្រៃឈើទាំងនេះ ។ ទោះជាយ៉ាងណាក៏ដោយ នៅមានបញ្ហាមួយចំនួនដែលមិនទាន់បានដោះស្រាយនៅឡើយទាក់ទងទៅនឹងបរិមាណនៃឧស្ម័នកាបូនិកដែលត្រូវកាត់បន្ថយពីវិស័យព្រៃឈើនេះ រៀបចំនូវកម្រិតគោលដើម្បីធ្វើការកត់ត្រានូវកម្រិតនៃការបំភាយឧស្ម័ន និងបញ្ហាបច្ចេកទេសនានា ។

បណ្តាប្រទេសអភិវឌ្ឍន៍នានាអាចកាត់បន្ថយការបំភាយឧស្ម័នកាបូនិកយឺតៗនិងតាមផែនការរបស់គេដែលប្រទេសទាំងនេះមិនចាំបាច់ទទួលខុសត្រូវចំពោះតម្លៃសេដ្ឋកិច្ចក្នុងការកាត់បន្ថយឧស្ម័នពីការប្រើប្រាស់កាបោន ។

---

[4] មាត្រាទី២ នៃក្របខ័ណ្ឌអនុសញ្ញាសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ

## ការវិនិយោគក្នុងការងារ REDD+

### ១. ការវិនិយោគសម្រាប់ការត្រួតពិនិត្យការបាត់បង់ព្រៃឈើ

ការបាត់បង់ព្រៃឈើមិនមែនកើតឡើងដោយសារតែការមិនយកចិត្តទុកដាក់ និងភាពល្ងង់ខ្លៅលើការគ្រប់គ្រងនោះទេ ប៉ុន្តែគឺដោយសារតែព្រៃឈើមានការចាប់អារម្មណ៍ច្រើនពីស្ថាប័ន អង្គការ និងបុគ្គលជាឯកជនជាច្រើន (ដូចជា អ្នកពាក់ព័ន្ធនានា) ដែលបានទទួលនូវផលប្រយោជន៍សេដ្ឋកិច្ចយ៉ាងច្រើនពីព្រៃឈើ ។ ដូច្នេះ ដើម្បីត្រួតពិនិត្យការបាត់បង់ព្រៃឈើ យើងត្រូវតែធ្វើគ្រប់អ្នកពាក់ព័ន្ធទាំងអស់ជឿជាក់ថា ដើមឈើឈរមានប្រយោជន៍សេដ្ឋកិច្ចទាំងផ្ទាល់ និងប្រយោលច្រើនជាងឈើដែលបានកាប់ ។

មកទល់ពេលនេះ មានវិធីសាស្ត្រពីរយ៉ាងដែលបានអនុវត្តដើម្បីធ្វើការត្រួតពិនិត្យការបាត់បង់ព្រៃឈើនៅតំបន់ត្រូពិក ៖ វិធីសាស្ត្រដោយផ្អែកលើបទដ្ឋានគតិយុត្តផ្តោតលើគោលនយោបាយ បទបញ្ញត្តច្បាប់ និងការអនុវត្តច្បាប់ និងវិធីសាស្ត្រផ្តោតលើការលើកទឹកចិត្តដោយផ្អែកលើយន្តការទូទាត់នានាសម្រាប់និរន្តភាពនៃការគ្រប់គ្រង និងអភិរក្សព្រៃឈើ ។ វិធីសាស្ត្រដោយផ្អែកលើបទដ្ឋានច្បាប់គឺជាវិធីសាស្ត្រមួយដែលមានសារៈសំខាន់សម្រាប់រយៈពេលវែង ។ ទោះជាយ៉ាងណាក៏ដោយ ផលប្រយោជន៍សេដ្ឋកិច្ចត្រូវបានទទួលការយកចិត្តទុកដាក់ និងប្រើប្រាស់យ៉ាងច្រើនក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ។ ទោះជាយ៉ាងណាក៏ដោយ ធនធានថវិកាតែងតែមិនគ្រប់គ្រាន់សម្រាប់ការត្រួតពិនិត្យការបាត់បង់ព្រៃឈើទាំងជាយន្តការផលប្រយោជន៍ថ្នាក់ជាតិ និងអន្តរជាតិ ។

### ២. ស្ថានភាពនៃការវិនិយោគ REDD+

មានវិធីជាមូលដ្ឋានពីរដែលREDD+ អាចទទួលបានថវិកាសម្រាប់ពេលអនាគត ៖ យន្តការមូលនិធិ (Fund Based Mechanism) និងយន្តការទីផ្សារ (Market Based Mechanism) ឬការរួមបញ្ចូលនូវយន្តការទាំងពីរខាងលើ ។ កិច្ចពិភាក្សាពីវិធិដែលសមស្របក្នុងការផ្តល់មូលនិធិកំពុងតែបន្ត ហើយកំពុងតែមានទំនាក់ទំនងទៅនឹងកិច្ចពិភាក្សាជាសាកលអំពីកិច្ចព្រមព្រៀងទាក់ទងទៅនឹងការប្រែប្រួលអាកាសធាតុ ។

តាមរយៈការសិក្សាស្តីពីការវិនិយោគព្រៃឈើជាសាកលរបស់លោក Eliasch (2008) មានតម្រូវការជាថវិកាពី ១៧ ទៅ ៣៣ កោដដុល្លាក្នុងការវិនិយោគក្នុងវិស័យនេះសម្រាប់ជាការស្នើឡើងក្នុងការកាត់បន្ថយអោយបាន៥០ភាគរយនៃការបំភាយឧស្ម័នពីការបាត់បង់ព្រៃឈើហូតដល់ឆ្នាំ ២០៣០ ។

រហូតមកដល់ពេលនេះការគាំទ្រភាគច្រើនត្រូវបានគេផ្តល់ឱ្យតាមរយៈការគាំទ្រពហុភាគីនិងទ្វេភាគីដែលជាជំនួយអភិវឌ្ឍន៍ប្រពៃណី។ យោងតាមរបាយការណ៍គោលរបស់ Cambodia REDD + Partnership

Voluntary ពីឆ្នាំ 2012 ថវិកាគាំទ្រតាមរយៈជំនួយខាងលើនេះមានចំនួន 6,27 ពាន់លានដុល្លារអាមេរិកនៅក្នុងរយៈពេលពីឆ្នាំ 2006-2022 នេះ។ ជាការកត់សម្គាល់ តាមរយៈការគាំទ្រនេះ ម្ចាស់ជំនួយភាគច្រើនមិនអាចបែងចែកការផ្តល់ជំនួយច្រើនជាងមួយ ឬពីរឆ្នាំទៅមុខនោះទេ ដូច្នេះ មានតែ បណ្តាប្រទេសមួយចំនួនតូចប៉ុណ្ណោះដែលមានទិន្នន័យហួសពីឆ្នាំ 2015 ។

## **យន្តការនៃការវិនិយោគ** REDD+

ដូចដែលបានរៀបរាប់ខាងលើ មានយន្តការពីរសំខាន់សម្រាប់ផ្តល់ថវិកាលើការអនុវត្ត REDD+ ៖ ទាំងពីរនេះនឹងបង្ហាញបន្ថែមដូចខាងក្រោម។

ដូចដែលបានរៀបរាប់ខាងលើ មានយន្តការពីរសំខាន់សម្រាប់ការផ្តល់មូលនិធិ REDD+ គឺ: យន្តការ មូលនិធិ (Fund Based Mechanism) និងយន្តការទីផ្សារ (Market Base Mechanism) ដែលយន្តការទាំងពីរនេះនឹងមានការពិភាក្សាលំអិតដូចខាងក្រោម ៖

### ក. **យន្តការមូលនិធិ** (Fund Based Mechanism)

បណ្តាប្រទេសនានាអាចផ្តល់មូលនិធិដល់យន្តការមូលនិធិ (Fund Based Mechanism) ។ ឧទាហរណ៍ មូលនិធិសម្រាប់វិធីនេះអាចបានមកពីការដេញថ្លៃពីផែនការជួយដូរពីការកាត់បន្ថយការ បំភាយឧស្ម័នរបស់សហភាពអឺរ៉ុប ការដាក់ពន្ធលើប្រភពផ្សេងទៀត។ មូលនិធិអាកាសធាតុបៃតង (Green Climate Fund) អាចជាមធ្យោបាយដ៏សំខាន់ក្នុងការងារនេះ ។ ប្រភពនៃការវិនិយោគក៏អាចរួមបញ្ចូលទាំងមូលនិធិជំនួយអភិវឌ្ឍន៍ទ្វេភាគីពីប្រទេសនានា ដូចជា មូលនិធិន័រវែស ។

ប្រទេសកំពុងអភិវឌ្ឍន៍ត្រួតពិនិត្យការបាត់បង់ និងរេចរឹលព្រៃឈើនៅថ្នាក់ជាតិដោយប្រើស្តង់ដារដាក់លាក់ និងកម្រិតគោលមួយចំនួន ។ ការផ្តល់ថវិកាត្រូវបានផ្តល់ជូនទៅតាមបរិមាណនៃការកាត់បន្ថយ ការបំភាយដែលសម្រេចបាន។

### **ខ. យន្តការទីផ្សារ**

ប្រទេសនានា និងបណ្តាប្រទេសឧស្សាហកម្មនានានៃបណ្តាប្រទេសដែលបានឯកភាពក្រោមអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (UNFCCC) អាចវិនិយោគតាមយន្តការនេះ ដោយធ្វើការទូទាត់នូវកាតព្វកិច្ចរបស់ខ្លួនដើម្បីកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់នេះ។ យន្តការដែលសមស្របសម្រាប់

ការវិនិយោគលើ REDD+ នេះកំពុងតែស្ថិតនៅក្រោមការជជែកពិភាក្សា ។ យន្តការទាំងពីរនេះមានទាំងគុណសម្បត្តិ និងគុណវិបត្តិ ។

ទស្សនផ្សេងគ្នាដែលគាំទ្រ និងប្រឆាំងទៅនឹងយន្តការមូលនិធិ និងយន្តការទីផ្សារ មានបង្ហាញដូចខាងក្រោមៈ

១. ការទូទាត់ (Offsetting) មិនបានកាត់បន្ថយការបំភាយឧស្ម័ននោះទេ វាគ្រាន់ជាការផ្លាស់ទីពីកន្លែងមួយទៅកន្លែងមួយផ្សេងទៀត ដូច្នេះ ផលប្រយោជន៍ជាក់លាក់ (Net Benefits) សម្រាប់បរិយាកាស គឺ សូន្យ។ លើសពីនេះទៀត មានការព្រួយបារម្ភអំពីបរមោណី និងអចិន្ត្រៃយ៍ភាព បន្ទាប់មកទៀតគឺផលប្រយោជន៍ជាក់លាក់សម្រាប់អាកាសធាតុ អាចអវិជ្ជមាន ។

២. ការទូទាត់ (Offsetting) នឹងជួយជម្រុញឲ្យមានកិច្ចប្រឹងប្រែងបន្ថែម ដោយសារតែវិធាននេះមាន ប្រសិទ្ធិភាពក្នុងការកាត់បន្ថយការបញ្ចេញឧស្ម័ន។

៣. លំហូរនៃឥណទានកាបោនពីរេដបូកមិនអាចទស្សទាយបានទេ ហើយអាចនាំឲ្យតំលៃកាបោននៅលើទីផ្សារធ្លាក់ចុះ ដោយសារការវិនិយោគនេះមិនអាចប្រកួតប្រជែងជាមួយវិស័យផ្សេងទៀត។ នេះមានន័យថាប្រទេសអភិវឌ្ឍន៍ទាំងឡាយនឹងមិនចាត់វិធានការកាត់បន្ថយការប្រែបប្រួលអាកាសធាតុក្នុងប្រទេសរបស់ពួកគេទេដោយសារភាពចំណេញពីការវិនិយោគផ្សេងទៀត។

៤. ទីផ្សារកាបោនគឺជាវិធីដ៏មានប្រសិទ្ធិភាពដើម្បីគៀងគរមូលនិធិ ។ ដោយសារវិធីសាស្ត្រនៃការផ្តល់មូលនិធិផ្ទាល់អាចមានការពិបាកច្រើន។

៥. ការថែរក្សាប្រព័ន្ធអេកូឡូស៊ីព្រៃឈើមិនគួរពឹងផ្អែកលើយន្តការគៀងគរមូលនិធិដែលមិនទាន់មានភាពច្បាស់លាស់ដូចជាយន្តការទីផ្សារកាបោននេះ។

ការព្រួយបារម្មណ៍ណាមួយក្នុងចំណោមចំណុចទាំងឡាយខាងលើនេះណាមួយដែលសំខាន់ជាងគេគឺអាស្រ័យលើអ្នកដែលយើងធ្វើការសាកសួរ ។ ជាការអនុវត្ត ដំណោះស្រាយមួយអាចមានប្រភពនៃការផ្តល់ហិរញ្ញប្បទានខុសៗគ្នា អាស្រ័យលើការចង់បានរបស់ប្រទេសនីមួយៗ និងមូលនិធិនានាដែលអាចមាន ។

## REDD+ ក្នុងបរិបទនៃប្រទេសកម្ពុជា

សកម្មភាពសំខាន់ៗចំនួន ៥ខាងក្រោមដែលអាចអនុវត្តបានក្រោមយន្តការ REDD+ នៃប្រទេសកម្ពុជា (កថាខ័ណ្ឌទី ៧០ សេចក្តីសម្រេចទី 1/CP.16):

a) កាត់បន្ថយការបំភាយឧស្ម័នដោយការបាត់បង់ព្រៃឈើ

b ) កាត់បន្ថយការបំភាយឧស្ម័នដោយការរេចរឹលព្រៃឈើ

c ) អភិរក្សព្រៃឈើសម្រាប់ការស្តុកកាបោន

d ) ការគ្រប់គ្រងព្រៃឈើដោយនិរន្តភាព

e ) បង្កើនអាងស្តុកកាបោន

- ប្រទេសនីមួយៗអាចផ្តោតលើសកម្មភាពណាមួយដែលសមស្របនឹងលក្ខខ័ណ្ឌរបស់ប្រទេសសាមី ព្រមទាំង ផ្តល់មូលហេតុច្បាស់លាស់ប្រសិនបើគេសម្រេចដកចេញនូវសកម្មភាពណាមួយខាងលើពីយុទ្ធសាស្ត្រជាតិរបស់ខ្លួន។
- យន្តការថ្នាក់ជាតិ (ថ្នាក់ក្រោមជាតិអាចអនុវត្តបានជាបណ្តោះអាសន្ន)
- ការចូលរួមដោយស្ម័គ្រចិត្ត

កម្ពុជាកំពុងប្រឈមនឹងការត្រួតពិនិត្យលើបាត់បង់ និងរេចរឹលព្រៃឈើ។ ដើម្បីទទួលបានផលប្រយោជន៍ពីរេដបូក កម្ពុជាត្រូវមានដំណោះស្រាយចំពោះភាពប្រឈមទាំងនេះ រួមនឹងបញ្ហាមួយចំនួនទៀតដូចជា យុទ្ធសាស្ត្រជាតិស្តីពីរេដបូក ប្រព័ន្ធធានាសុវត្ថភាព យន្តការបែងចែកផលប្រយោជន៍ ប្រព័ន្ធត្រួតពិនិត្យ រាយការណ៍ និងផ្ទៀងផ្ទាត់ការបញ្ចេញឧស្ម័ន និងបទដ្ឋានច្បាប់ដែលពាក់ព័ន្ធ។

គោលបំណងនៃយន្តការរេដបូកនៅក្នុង UNFCCC គឺចង់អនុវត្តន៍រេដបូកនៅថ្នាក់ជាតិ។ ការកាត់បន្ថយការបញ្ចេញឧស្ម័នកាបូនិចពីការបាត់បង់ និងរេចរឹលព្រៃឈើ ព្រមទាំងការស្រូបការបោនពីការដាំដុះព្រៃឈើឡើងវិញ នៅក្នុងប្រទេសកម្ពុជានឹងត្រូវធ្វើការវាស់វែងនៅថ្នាក់ជាតិ សម្រាប់ជាមូលដ្ឋានក្នុងការទូទាត់ការលើកទឹកចិត្តពីកម្រិតនៃការកាត់បន្ថយការបញ្ចេញឧស្ម័ន។ ដូចនេះយុទ្ធសាស្ត្រមួយនៅថ្នាក់ជាតិ មានលក្ខណៈអន្តរវិស័យ និងរួមបញ្ចូលនូវអ្នកពាក់ព័ន្ធចំរុះ ដែលរួមចំណែកលើកកំពស់ការប្រើប្រាស់ដី ដើម្បីឲ្យកម្ពុជាទទួលបាននូវផលប្រយោជន៍ពីសកម្មភាពរេដបូក។

ដើម្បីជាមូលដ្ឋានក្នុងការបន្តអភិវឌ្ឍន៍យន្តការរេដបូកឲ្យមានប្រសិទ្ធិភាព កម្ពុជាគួរតែសិក្សានូវ មេរៀនពីការអនុវត្តរេដបូករបស់គម្រោងរេដបូកដែលមានស្រាប់ ក៏ដូចជាបទពិសោធន៍ពីការអនុវត្តរេដបូកក្នុងកម្រិតផ្សេងៗ (ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ)នៅថ្នាក់អន្តរជាតិ និងធ្វើការវិភាគដើម្បីជាការជួយដល់ការធ្វើសេចក្តីសម្រេចចិត្តដើម្បីដំណើរការរេដបូកនៅកម្ពុជា[5] ។

ជាការប្រសើរ គោលការណ៍សំខាន់នៃយន្តការរេដបូកដែលនឹងអនុវត្តន៍នៅកម្ពុជាឆ្លើយតបនឹងតម្រូវការសហគមន៍មូលដ្ឋាន និងធានានូវផលប្រយោជន៍ចំរុះដល់សហគមន៍មូលដ្ឋាន ជនជាតិដើមភាគតិច ស្ត្រី ព្រមទាំងរួម

[5] UN-REDD+ Taskforce Secretariat Terms of Reference fore REDD+ Demonstration Team, 2013

ចំណែកដល់ការគ្រប់គ្រងព្រៃឈើ និងការអភិរក្សជីវចំរុះអោយកាន់តែមាននិរន្តភាព ក៏ដូចជាការប្រើប្រាស់ដីប្រកបដោយប្រសិទ្ធិភាព។

### រេដបូកនាពេលអនាគត

ភាពជោគជ័យនាពេលអនាគតនៃយន្តការរេដបូកអាស្រ័យលើកត្តាជាច្រើន ក្នុងនោះមាន ប្រសិទ្ធិភាពក្នុងការកាត់បន្ថយការសាយភាយឧស្ម័នពីការបាត់បង់ និងរេចរឹលព្រៃឈើ ប្រសិទ្ធិភាពលើការចំណាយ និងការបែងចែកផលប្រយោជន៍ ការចំណាយ និងហានិភ័យ។ ទាំងនេះជាបញ្ហាដែលស្មុគស្មាញ។ ការវិនិយោគនៅថ្នាក់ជាតិ និងការបែងចែកតំលៃ/ការចំណាយលើសកម្មភាពរេដបូក ដើរតួនាទីសំខាន់ក្នុងការទទួលជោគជ័យនៃយន្តការរេដបូក។ កម្រិតយោងនៃការសាយភាយឧស្ម័នពីការបាត់បង់ និងរេចរឹលព្រៃឈើ ជាកត្តាបច្ចេកទេសដែលជួយជាមូលដ្ឋានក្នុងការវាស់វែងកម្រិតនៃការកាត់បន្ថយការបញ្ចេញឧស្ម័ន និងការបែងចែកផលប្រយោជន៍ពីរេដបូក។ ប្រសិនបើកត្តាទាំងនេះត្រូវបានដោះស្រាយវានឹងជួយជម្រុញភាពជោគជ័យនៃយន្តការរេដបូកនៅកម្ពុជា។ ចំណុចខាងក្រោមនេះទាក់ទងនឹងការអនុវត្ត រេដបូកនៅកម្ពុជា ហើយដែលនឹងត្រូវពិភាក្សាស៊ីជម្រៅនៅមេរៀនបន្ទាប់។

- តើអ្វីខ្លះជាភាពប្រឈមក្នុងការវាស់វែងកម្រិតនៃការបាត់បង់ និងរេចរឹលព្រៃឈើ ហើយមានជម្រើសណាខ្លះក្នុងការដោះស្រាយភាពប្រឈមទាំងនេះ?
- តើរេដបូកផ្តល់ជាផលប្រយោជន៍ និងតំលៃអ្វីខ្លះដល់អ្នកពាក់ព័ន្ធ?
- តើផលប្រយោជន៍ពីរេដបូក នឹងត្រូវប្រៀបធៀបដូចម្តេចជាមួយតម្រូវប្រើប្រាស់នៅថ្នាក់ជាតិ និងរបស់សហគមន៍មូលដ្ឋាន (ផលព្រៃឈើ)?
- តើកម្រិតគោល និងកម្រិតយោងនៃការបញ្ចេញឧស្ម័ន ដែលរួមចំណែកដល់ការបង្កើនកាបោនស្តុក (ដែលជាមូលដ្ឋានក្នុងការទូទាត់សំណង) នឹងត្រូវគណនាតាមរបៀបណា?
- តើនិរន្តភាពនៃយន្តការនេះនឹងត្រូវធានាដូចម្តេច ហើយអ្នកណាជាអ្នកទទួលខុសត្រូវ?
- តើការបញ្ចេញកាបោនពីព្រៃឈើនឹងត្រូវ ត្រួតពិនិត្យ វាស់វែង ផ្ទៀងផ្ទាត់ និងរាយការណ៍យ៉ាងដូចម្តេច?
- តើការរេចរឹលព្រៃឈើនឹងត្រូវវាស់វែងដូចម្តេច?
- តើផលប្រយោជន៍ចំរុះ (សេដ្ឋកិច្ចសង្គម និងបរិស្ថាន)តាមរយៈរេដបូកត្រូវធានាតាមរបៀបណា ហើយថាតើ ផលប៉ះពាល់ជាអវិជ្ជមានត្រូវបញ្ចៀសបែបណា?

# គំនិតផ្តួចផ្តើមពីរេដបូកនៅកម្ពុជា

ដំណាក់កាលទាំងបីនៃ REDD+

- REDD+ នឹងធ្វើការអនុវត្តតាមរយៈវិធីសាស្រ្តគោលនយោបាយ និងការលើកទឹកចិត្តជាវិជ្ជមាន
- REDD+ គួរតែត្រូវបានអនុវត្តជាបីដំណាក់កាល
- ប្រទេសនានាគួរតែរៀបចំនូវធាតុនានាដូចខាងក្រោម៖
    - យុទ្ធសាស្រ្តថ្នាក់ជាតិ ឬផែនការសកម្មភាព
    - កម្រិតបំភាយឧស្ម័នព្រៃឈើ Forest reference emission levels and forest reference levels – **RELs/RLs (performance benchmarks)**
    - ប្រព័ន្ធពិនិត្យតាមដានព្រៃជាតិ
    - ប្រព័ន្ធការពារសុវត្ថិភាពព័ត៌មាន (មានការធានាសុវត្ថិភាពចំនួនប្រាំពីររបស់REDD+ កម្ពុជា)
- បណ្តាប្រទេសដែលគួរតែដោះស្រាយបញ្ហានានាដែលមានទំនាក់ទំនង ៖ កត្តា/មូលហេតុនៃការបាត់បង់ និងរេចរឹលព្រៃឈើ បញ្ហាកម្មសិទ្ធិដីធ្លី បញ្ហាអភិបាលកិច្ចព្រៃឈើ បញ្ហាយេនឌ័រនិងការធានាសុវត្ថិភាពរេដបូក កម្ពុជា

ការអនុវត្ត REDD+ មានបីដំណាក់កាលដូចមានក្នុងរូបភាពខាងក្រោម ៖

ដំណាក់កាលរបស់ REDD+




ប្រភព ៖ កម្មវិធី UN-REDD


រចនាសម្ព័ន្ធកម្មវិធីUN-REDD+កម្ពុជា
គណៈកម្មាធិការជាតិ សម្រាប់ការប្រែប្រួលអាកាសធាតុ
ក្រុមទីប្រឹក្សា REDD+
ក្រុមប្រឹក្សាយោបល់ REDD+
ក្រុមការងារ REDD+ កម្ពុជា
ប្រធានក្រុមការងារ : FA
អនុប្រធានក្រុមការងារ : GDANC-
សមាជិក FA, GDANCP, MLMUPC, FiA, MEF, MoI, MRD, MIME
ក្រុមប្រឹក្សាប្រតិបត្តិ កម្មវិធីUN-REDD+កម្ពុជា (PEB)
ប្រធាន: ប្រធានក្រុមការងារREDD+កម្ពុជា
សហប្រធាន: UN Resident Coordinator
នាយកកម្មវិធីUN-REDD+កម្ពុជា: FA
នាយករងកម្មវិធីUN-REDD+កម្ពុជា: GDANCP
FAO, UNDP, UNEP, តំណាងដៃគូអភិវឌ្ឍ តំណាងសង្គមស៊ីវិល និង តំណាងជនជាតិដើមភាគតិច
នាយកកម្មវិធីUN-REDD+កម្ពុជា: FA
នាយករងកម្មវិធីUN-REDD+កម្ពុជា: GDANCP
លេខាធិការដ្ឋានក្រុមការងារ REDD+ កម្ពុជា
លេខាធិការ: FA
លេខាធិការរង: GDANCP
មន្ត្រីលេខាធិការដ្ឋាន: FA, GDANCP, FiA
មន្ត្រីកិច្ចសន្យាកម្មវិធី UN-REDD
ក្រុមបច្ចេកទេស ប្រឹក្សាយោបល់ និង កិច្ចការពារសុវត្ថិភាព FA, GDANCP, MRD...
ក្រុមបច្ចេកទេស បែងចែកផលប្រយោជន៍ FA, GDANCP, MEF, FiA, ...
ក្រុមបច្ចេកទេស សាកល្បង REDD+ FA, GDANCP, FiA, ...
ក្រុមបច្ចេកទេស វាស់វែង រាយការណ៍ និង ផ្ទៀងផ្ទាត់ MRV/REL FA, GDANCP, MLMUPC, FiA
UN-REDD PROGRAMME


រចនាសម្ព័ន្ធក្រុមការងារ និងលេខាធិការដ្ឋាន REDD+កម្ពុជា
គណៈកម្មាធិការជាតិ សម្រាប់ការប្រែប្រួលអាកាសធាតុ
ក្រុមទីប្រឹក្សា REDD+
ក្រុមប្រឹក្សាយោបល់ REDD+
ក្រុមការងារ REDD+ កម្ពុជា
ប្រធានក្រុមការងារ : FA
អនុប្រធានក្រុមការងារ : GDANC-
សមាជិក FA, GDANCP, MLMUPC, FiA, MEF, MoI, MRD, MIME
លេខាធិការដ្ឋានក្រុមការងារ REDD+ កម្ពុជា
ប្រធានលេខាធិការ: FA
អនុប្រធានលេខាធិការ: GDANCP
មន្ត្រីលេខាធិការដ្ឋាន: FA, GDANCP, FiA
មន្ត្រីកិច្ចសន្យាកម្មវិធី UN-REDD
ក្រុមបច្ចេកទេស កិច្ចការពារសុវត្ថិភាព FA, GDANCP, MRD...
ក្រុមបច្ចេកទេស បែងចែកផលប្រយោជន៍ FA, GDANCP, MEF, FiA, ...
ក្រុមបច្ចេកទេស សាកល្បង REDD+ FA, GDANCP, FiA, ...
ក្រុមបច្ចេកទេស វាស់វែង រាយការណ៍ និង ផ្ទៀងផ្ទាត់ MRV/REL FA, GDANCP, MLMUPC, FiA

**កម្មវិធី** REDD+ (ប្រភព: http://www.cambodia-redd.org)

រចនាសម្ព័ន្ធ REDD+ រួមមានក្រុម និងក្រុមបច្ចេកទេសផ្សេងៗដែលតាមរយៈការរៀបចំនូវផែនទីបង្ហាញផ្លូវបានឯកភាពគ្នាដើម្បីធ្វើអោយប្រាកដថាមានការឯកភាពជារួម និងមានតម្លាភាពក្នុងដំណើរការនៃការត្រៀមលក្ខណៈក្នុងប្រទេសកម្ពុជា ។ ខាងក្រោមនេះគឺជាព័ត៌មានលំអិតអំពីក្រុមការងារ ៖

**ក្រុមការងារ REDD+ កម្ពុជា**

ក្រុមការងារ REDD+ កម្ពុជា បានសម្រេចបង្កើតជាផ្លូវការនៅ២៦ ខែកុម្ភៈ ឆ្នាំ ២០១៣ ដោយមានប្រកាសលេខ ៨៧ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

ក្រុមការងារវេ៉ដប៉ូកកម្ពុជានឹងដើរតួនាទីសំខាន់ក្នុងការសម្របសម្រួល និងជាស្ថាប័នដែលអាចធ្វើសេចក្តីសម្រេចជារួមក្នុងចំណោមស្ថាប័ននានា ។

អណ្ណត្តិរបស់ក្រុមការងារមានភារៈទទួលខុសត្រូវលើ៖

- ការគ្រប់គ្រង និងសម្របសម្រួលលើដំណើរការនៃយុទ្ធសាស្ត្រនានា និង ToRs សម្រាប់វេ៉ដប៉ូក
- ការគ្រប់គ្រង និងសម្របសម្រួលការអនុវត្តកម្មវិធីនានា
- សម្របសម្រួល និងធ្វើសេចក្តីសម្រេចចិត្តសម្រាប់ការអនុវត្តគម្រោងសាកល្បង
- ត្រួតពិនិត្យលទ្ធផលរបស់គម្រោងដើម្បីអោយប្រាកដថាគម្រោងទាំងនេះស្របទៅតាមស្ថានភាពបច្ចុប្បន្នរបស់កម្ពុជា
- រាយការណ៍ពីការអនុវត្តគម្រោងទៅដល់រដ្ឋមន្ត្រីក្រសួងកសិកម្មរៀងរាល់ខែ

ក្រុមការងារនេះដឹកនាំដោយប្រធានម្នាក់គឺអនុប្រធានរដ្ឋបាលព្រៃឈើ និងអនុប្រធានម្នាក់គឺ អគ្គនាយករងនៃរដ្ឋបាលការពារអភិរក្សធម្មជាតិក្រសួងបរិស្ថាន នៃក្រសួងបរិស្ថាន ។ សមាជិកដទៃទៀតនៃក្រុមការងារនេះមាន ៖

- អគ្គនាយករងនៃអគ្គនាយករដ្ឋបាលមូលដ្ឋាននៃក្រសួងមហាផ្ទៃ
- ប្រធាននាយកដ្ឋាននៃនាយកដ្ឋានកម្មសិទ្ធិនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- អគ្គនាយករងនៃអគ្គនាយកដ្ឋានថាមពលក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- ប្រធាននាយកដ្ឋានផ្គត់ផ្គង់ទឹកនៃក្រសួងអភិវឌ្ឍន៍ជនបទ )MRD)
- ប្រធានស្តីទីនៃនាយកដ្ឋានអភិរក្សជលផល នៃរដ្ឋបាលជលផល (Fi A)
- អគ្គនាយករងបច្ចេកទេសនៃក្រសួងបរិស្ថាន
- ប្រធាននាយកដ្ឋាន នៃនាយកដ្ឋានសត្វព្រៃនិងជីវចម្រុះនៃរដ្ឋបាលព្រៃឈើ
- ប្រធានការិយាល័យអភិរក្សទ្រព្យសម្បត្តិរបស់រដ្ឋ នាយកដ្ឋានអភិរក្សដីនៃអគ្គនាយកដ្ឋានដី និងភូមិសាស្ត្រនៃក្រសួងដែនដីនគររូបនីយកម្ម និងសំណង់ (MLMUPC)

### *លេខាធិការដ្ឋាន នៃក្រុមការងារ REDD+ (REDD+ Taskforce Secretariat)*

លេខាធិការដ្ឋាននៃក្រុមការងារ REDD+ កម្ពុជា អនុវត្តមុខងារជាអង្គភាពគ្រប់គ្រងកម្មវិធី REDD+ កម្ពុជា និងមាន ភារៈទទួលខុសត្រូវលើការគ្រប់គ្រងជារួមសម្រាប់ប្រតិបត្តិការងារប្រចាំថ្ងៃនៃកម្មវិធីនេះ ។ លេខាធិការដ្ឋានមានមូលដ្ឋាននៅរដ្ឋបាលព្រៃឈើ ហើយមានមន្ត្រីដែលបានតែងតាំងមកពីរដ្ឋបាលព្រៃឈើ GDANCP និង FIiA និងទីប្រឹក្សារយៈពេលវែងដែល ជ្រើសរើសដោយនាយដ្ឋានដៃគូដែលពាក់ព័ន្ធ ។

### *ក្រុមប្រឹក្សាយោបល់*

ក្រុមប្រឹក្សាយោបល់នេះត្រូវបានស្នើឡើងនៅក្នុងផែនទីបង្ហាញផ្លូវក្នុងដំណាក់កាលត្រៀមលក្ខណៈរបស់ REDD+ កម្ពុជា គឺជាស្ថាប័នមួយក្នុងការផ្តល់នូវយោបល់ដល់ក្រុមការងារ REDD+ លើដំណើរការត្រៀមលក្ខណៈ និងផ្តល់ជាវេទិកាក្នុងការបង្ហាញនូវទស្សនៈនានារបស់ក្រុមអ្នកពាក់ព័ន្ធ ។ ក្រុមនេះបង្កើតឡើងក្នុងគោលបំណងអោយមានការទទួលខុសត្រូវជាអ្នកភ្ជាប់ទំនាក់ទំនងរវាងកម្មវិធី REDD+ កម្ពុជា និងបណ្តាញរបស់ក្រុមអ្នកពាក់ព័ន្ធនានា ។

ក្រុមប្រឹក្សាយោបល់ មានសមាជិកសរុបចំនួន ១៨រូបដែលមានតំណាងពីររូបមកពីតំណាងអ្នកពាក់ព័ន្ធចំនួន៩ក្រុម។ ក្រុមនេះបានដកស្រង់ចេញពីផែនទីបង្ហាញផ្លូវ និងឯកសាររបស់កម្មវិធី UN-REDD កម្ពុជា និងដោយផ្អែកលើការពិភាក្សាជាមួយនឹងអ្នកពាក់ព័ន្ធនានា ។ ក្រុមទាំង ៩នេះរួមមាន ៖

- គ្រឹះស្ថានអប់រំ
- អង្គការអន្តរជាតិ
- អង្គការជាតិ
- ជនជាតិដើមភាគតិច
- សង្គមស៊ីវិល
- ក្រុមហ៊ុនឯកជន
- ក្រុមសហគមន៍ព្រៃឈើ
- ក្រុមសហគមន៍តំបន់ការពារធម្មជាតិ និង
- ក្រុមសហគមន៍នេសាទ

# ក្រុមការងារបច្ចេកទេសចែករំលែកផលប្រយោជន៍រេដបូក
(REDD+ Benefit Sharing Technical Team)

## លក្ខខណ្ឌការងារ

### ១. សាវតា

យន្តការអនាគតសម្រាប់ការកាត់បន្ថយការបញ្ចេញឧស្ម័នដែលបណ្តាលមកពីការការបាត់បង់ និងរិចរឹលព្រៃឈើ (រេដ+) ដែលកំពុងរៀបចំតាមរយៈអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (UNFCCC) នឹងផ្តល់ឱកាសដល់កិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជា ដើម្បីកាត់បន្ថយកម្រិតនៃការរិចរឹលព្រៃឈើ និងជួយថែរក្សាការពារព្រៃធម្មជាតិ ក៏ដូចជាការបង្កើតព្រៃថ្មី។

នៅឆ្នាំ២០១០ រាជរដ្ឋាភិបាលកម្ពុជា បានរៀបចំដំណើរការផែនការត្រៀមលក្ខណៈសម្រាប់រេដ+ ដែលនាំទៅដល់ ការបង្កើតសំណើផែនការត្រៀមលក្ខណៈសម្រាប់រេដ+នៅកម្ពុជា (ផែនទីបង្ហាញផ្លូវ)។ ឯកសារនេះបង្ហាញថាតើកម្ពុជានឹងបង្កើតគោលនយោបាយ និងវិធានការអ្វីខ្លះដើម្បីត្រៀមលក្ខណៈជាស្រេចសម្រាប់ រេដ+។

សមាសភាគសំខាន់ដើម្បីត្រៀមលក្ខណៈជាស្រេចសម្រាប់រេដ+ គឺត្រូវមានប្រព័ន្ធចែករំលែកការទទួលផលប្រយោជន៍ជាវិជ្ជមាន សម្រាប់លទ្ធផលដែលសម្រេចបាន ក្នុងការកាត់បន្ថយការបញ្ចេញ ឬ ពង្រឹងការស្រូបយកឧស្ម័ន ដែលអាចរាយការណ៍បានតាមរបាយការណ៍ និងការផ្ទៀងផ្ទាត់ ដែលស្របតាមដំណើរការរបស់ UNFCCC ដែលបច្ចុប្បន្ននេះ នៅមិនទាន់បានសម្រេចនៅឡើយ នៅក្នុងការចរចារជាលក្ខណៈអន្តរជាតិ។ ផលប្រយោជន៍ ឬ ការលើកទឹកចិត្តអាចយល់ថាទាំងសាច់ប្រាក់ និងមិនមែនសាច់ប្រាក់ដូចជា ការធ្វើឲ្យប្រសើរឡើងនូវសិទ្ធិ និងបន្តឲ្យប្រើប្រាស់ធនធានជាដើម។

ប្រព័ន្ធចែករំលែកផលប្រយោជន៍នេះ ត្រូវមានសមធ៌ម ផ្តល់ការលើកទឹកចិត្តដល់ការចូលរួម មានតម្លាភាព និង មានប្រសិទ្ធិភាព។ ប្រព័ន្ធចែករំលែកផលប្រយោជន៍នេះ ត្រូវយកចិត្តទុកដាក់លើបទពិសោធន៍ដែលធ្លាប់បានអនុវត្តនាពេលបច្ចុប្បន្ន និងកន្លងមកនៅកម្ពុជា ក៏ប៉ុន្តែអាចនឹងមានផលវិបាក ដល់វិធីសាស្ត្រអនុវត្តនៅថ្នាក់ក្រោមជាតិ ដែលកើតចេញពីការសាកល្បងគម្រោងផ្តល់ហិរញ្ញប្បទាន តាមរយៈទីផ្សារកាបូនស្ម័គ្រចិត្ត ដែលជាវិធីសាស្ត្របណ្តោះអាសន្ន មុននឹងឈានទៅដល់ការអនុវត្តនៅថ្នាក់ជាតិ ដែលស្ថិតក្រោមក្របខ័ណ្ឌការងាររបស់ UNFCCC ។

### ២. គោលបំណង

គោលបំណងរបស់ក្រុមការងារបច្ចេកទេសចែករម្លែកផលប្រយោជន៍រេដ+ គឺជានាថាមេរៀន និងបទពិសោធន៍ស្តីពីប្រព័ន្ធចែករំលែកផលប្រយោជន៍ នាពេលបច្ចុប្បន្ន និងកន្លងមកនៅកម្ពុជា ត្រូវបានសិក្សាសម្រាប់សេចក្តីត្រូវការក្នុងបរិបទ រេដ+ និងមេរៀនជាបទពិសោធន៍ ដែលទទួលបានពីបណ្តាប្រទេសនានាត្រូវបានរួមបញ្ចូល ដើម្បីផ្តល់ជាអនុសាសន៍ដល់ការរៀបចំប្រព័ន្ធចែករំលែកផលប្រយោជន៍សម្រាប់ រេដ+ នៅកម្ពុជា ។

## ៣. សមាជិកភាព

ក្រុមបច្ចេកទេសមានសមាជិកតំណាងមកពី៖

- ក្រសួងមហាផ្ទៃ ចំនួន១នាក់(អគ្គនាយកដ្ឋាន រដ្ឋបាលមូលដ្ឋាន)
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ចំនួន១នាក់(អគ្គនាយកដ្ឋាន ថាមពល)
- ក្រសួងអភិវឌ្ឍន៍ជនបទ ចំនួន១នាក់
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុចំនួន១នាក់
- ការិយាល័យពាក់ព័ន្ធ រដ្ឋបាលព្រៃឈើ១នាក់,
- ការិយាល័យពាក់ព័ន្ធ អគ្គនាយកដ្ឋានរដ្ឋបាលការពារអភិរក្សធម្មជាតិ ១នាក់
- ការិយាល័យពាក់ព័ន្ធ រដ្ឋបាលជលផល១នាក់
- សមាជិកក្រុមប្រឹក្សាយោបល់ រេដ+ កម្ពុជា ចំនួន៣នាក់ ដែលមានជំនាញ និងបទពិសោធន៍ពាក់ព័ន្ធ (ក្រុមប្រឹក្សាយោបល់នឹងចាត់តាំងសមាជិកក្រុមមកចូលរួម)
- លេខាធិការដ្ឋានក្រុមការងារ រេដ+ កម្ពុជា ចំនួន២នាក់ នឹងត្រូវចាត់តាំងដោយ ប្រធានលេខាធិការដ្ឋាន។

សមាជិកទាំងអស់ត្រូវចាត់តាំងតំណាងមកចូលរួមជំនួសក្នុងកិច្ចប្រជុំនានា ប្រសិនបើមានធុរៈចាំបាច់។ យោងតាមតម្រូវការជាក់ស្តែង អង្គការមិនមែនរដ្ឋាភិបាលដែលមានបទពិសោធន៍ នឹងអាចអញ្ជើញមកចូលរួមក្នុងកិច្ចប្រជុំ។

## ៤. ប្រតិបត្តិការ

ក្រុមការងារបច្ចេកទេសនេះត្រូវជួបប្រជុំប្រចាំខែ។ ប្រធានក្រុមការងារបច្ចេកទេស នឹងត្រូវជ្រើសរើសក្នុងចំណោមសមាជិកក្រុម និងអនុម័តដោយប្រធានលេខាធិការដ្ឋាន។ ប្រធានក្រុមការងារបច្ចេកទេស ជាប្រធានដឹកនាំកិច្ចប្រជុំ។ សមាជិកដែលមកពីលេខាធិការដ្ឋានម្នាក់ នឹងត្រូវតែងតាំងជាលេខាធិការ របស់ក្រុមការងារបច្ចេកទេស ។ លេខាធិការត្រូវធានាថា លិខិតអញ្ជើញចូលរួមកិច្ចប្រជុំ ដោយមានភ្ជាប់ឯកសារដែលត្រូវពិភាក្សា បានផ្ញើជូនដល់គ្រប់សមាជិក រយៈពេល១សប្តាហ៍មុនកិច្ចប្រជុំ។ លេខាធិការត្រូវផ្ញើសេចក្តីព្រាងកំណត់ ហេតុកិច្ចប្រជុំ ជូនគ្រប់សមាជិកក្នុងរយៈពេល៣ថ្ងៃបន្ទាប់ពីកិច្ចប្រជុំ។ សមាជិក (ឬអ្នកជំនួស) ទាំងអស់ត្រូវផ្តល់យោបល់លើ សេចក្តីព្រាងកំណត់ហេតុកិច្ចប្រជុំក្នុងរយៈពេល៣ថ្ងៃ បន្ទាប់មកលេខាធិការ កែសម្រួលកំណត់ហេតុកិច្ចប្រជុំតាមការផ្តល់យោបល់ និងផ្ញើកំណត់ហេតុសម្រេចជូនគ្រប់សមាជិកក្រុមការងារបច្ចេកទេស។ កំណត់ហេតុកិច្ចប្រជុំត្រូវមាន កាលបរិច្ឆេទ ពេលវេលា ទីកន្លែង ប្រធានបទជាបន្តបន្ទាប់ក្នុងកិច្ចប្រជុំ និងផ្សព្វផ្សាយជាសាធារណៈ ជូនដល់គ្រប់អ្នកពាក់ព័ន្ធតាមរយៈការដាក់នៅក្នុង គេហទំព័រ រេដ+ កម្ពុជា ។

## ៥. ការធ្វើសេចក្តីសម្រេច

ក្រុមការងារបច្ចេកទេសនេះមិនមែនជាអ្នកធ្វើសេចក្តីសម្រេចទេ ប៉ុន្តែជាអ្នកផ្តល់អនុសាសន៍ដល់ក្រុមការងាររេដ+ កម្ពុជា និង លេខាធិការដ្ឋានក្រុមការងារ រេដ+ កម្ពុជា ជារៀងរាល់ខែ។ អនុសាសន៍នានានឹងត្រូវធ្វើឡើង តាមគោលការណ៍នៃការឯកភាពមតិ។

## ៦. ការទទួលខុសត្រូវ

ក្រុមការងារបច្ចេកទេសនេះ ត្រូវធ្វើការជាមួយលេខាធិការដ្ឋានក្រុមការងារ រេដ+ កម្ពុជា ដើម្បីគាំទ្រដល់ការបង្កើតសំណើនានាពាក់ព័ន្ធនឹងប្រព័ន្ធចែករំលែកផលប្រយោជន៍ រេដ+ នៅកម្ពុជា។ ក្រុមការងារបច្ចេកទេស បង្កើតអនុសាសន៍ និងផ្តល់ជូនក្រុមការងារ រេដ+ កម្ពុជា តាមរយៈ៖

- សិក្សាពីលទ្ធភាព នៃអ្នកប្រើប្រាស់ និងអ្នកការពារ ដើម្បីធានាការបែងចែកផលប្រយោជន៍ប្រកបដោយសមធម៌
- ពិនិត្យមេរៀនជាបទពិសោធន៍ដែលទទួលបានពី គម្រោងសាកល្បងបង្ហាញ
- ពិនិត្យមេរៀនជាបទពិសោធន៍ដែលទទួលបានពី គម្រោងគ្រប់គ្រងធនធានធម្មជាតិ ដែលមានការចែករំលែកផលប្រយោជន៍
- សម្របសម្រួលជាមួយដៃគូដែលធ្វើការងារក្នុងវិស័យដូចគ្នា
- ពិនិត្យសំណើប្រព័ន្ធចែករំលែកផលប្រយោជន៍ រេដ+ នៅបណ្តាប្រទេសនានា
- ពិភាក្សាជាអ្នកឯកទេសពាក់ព័ន្ធ
- បង្កើតសំណើបឋម និងរៀបចំកិច្ចប្រឹក្សាយោបល់យ៉ាងទូលំទូលាយលើសំណើបឋមនេះ។

*ភារកិច្ចជាក់លាក់របស់ក្រុមបច្ចេកទេស៖*

- ការចូលរួមប្រជុំប្រចាំខែ
- ការពិនិត្យឯកសារ និងបទបង្ហាញនានា និងផ្តល់យោបល់ កែលម្អលើឯកសារ និងបទបង្ហាញទាំងនោះ
- ផ្តល់ជាជំនួយដល់ទីប្រឹក្សា និងបុគ្គលិក លេខាធិការដ្ឋានក្រុមការងារ រេដ+ កម្ពុជា ក្នុងការអនុវត្តកិច្ចការរបស់ពួកគេ
- ចូលរួមនៅក្នុងវគ្គបណ្តុះបណ្តាល និងសិក្ខាសាលានានា។

ដោយសារមានកិច្ចការងារជាច្រើនដែលត្រូវបំពេញ ក្រុមបច្ចេកទេសត្រូវបង្កើតផែនការការងារ និងមានកំណត់ទំហំការងារ ជាក់លាក់ដែលត្រូវសម្រេចឲ្យបាន ដោយមានការពិភាក្សាជាមួយលេខាធិការដ្ឋានក្រុមការងារ រេដ+ កម្ពុជា ដើម្បីចាត់អាទិភាពការងារ។

## ៧. ការធ្វើរបាយការណ៍

សមាជិកក្រុមបច្ចេកទេសនេះ ត្រូវទទួលខុសត្រូវធ្វើរបាយការណ៍ និងប្រឹក្សាយោបល់ជាមួយស្ថាប័នសាមី និងក្រុមគោលដៅរបស់ខ្លួន។ សមាជិកទាំងនេះអាចស្នើសុំឲ្យមានការផ្តល់ពេលវេលាជាបន្ថែមដើម្បីពិចារណាបញ្ហាជាក់លាក់នានា ប្រសិនបើយល់ថា បញ្ហាទាំងនោះមានសារៈសំខាន់ជាពិសេស ចំពោះស្ថាប័នរបស់ខ្លួន និងតម្រូវឲ្យមានការពិភាក្សាជាបន្ថែម។

ក្រុមការងារបច្ចេកទេស ត្រូវធ្វើសេចក្តីរាយការណ៍ដោយផ្ទាល់ទៅលេខាធិការដ្ឋាន ក្រុមការងាររេដ+កម្ពុជា តាមរយៈលេខាធិការ ក្រុមការងារបច្ចេកទេសនេះ។

## ៨. រយៈពេល និងថេរវេលា

សមាជិកត្រូវធ្វើការប្រមាណជា ១ថ្ងៃ ទៅ ៣ថ្ងៃ ក្នុងមួយខែ អាស្រ័យលើសកម្មភាពដែលត្រូវអនុវត្ត។ លក្ខខណ្ឌការងារនេះ អាចស្នើសុំកែសម្រួល ដោយក្រុមការងារបច្ចេកទេស និងអនុម័តដោយក្រុមការងាររេដ+កម្ពុជា។

## ៩. ថវិកាគាំទ្រ

ការគាំទ្រថវិកា នឹងផ្តល់ដោយ កម្មវិធី UN-REDD និង គម្រោង FCPF (R-PP) ដោយយោងទៅតាមថវិកាដែលបានអនុម័ត សម្រាប់ការចំណាយ នៅក្នុងអំឡុងពេលនៃការអនុវត្តកិច្ចការនានាដែលទាក់ទងនឹងតួនាទីទាំងនេះ។ ការគាំទ្រមកពីក្របខ័ណ្ឌការងារផ្សេងទៀតនឹងត្រូវពិចារណាផងដែរ៕

## ក្រុមការងារបច្ចេកទេសធានាសុវត្ថិភាពរេដ+
(REDD+safeguards Technical Team)
## លក្ខខណ្ឌការងារ

### ១. សាវតា

យន្តការអនាគតសម្រាប់ការកាត់បន្ថយការបញ្ចេញឧស្ម័នដែលបណ្តាលមកពីការការបាត់បង់ និងរិចរឹលព្រៃឈើ (រេដ+) ដែលកំពុងរៀបចំតាមរយៈអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (UNFCCC) នឹងផ្តល់ឱកាសដល់កិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជា ដើម្បីកាត់បន្ថយកម្រិតនៃការរិចរឹលព្រៃឈើ និងជួយថែរក្សាការពារព្រៃធម្មជាតិ ក៏ដូចជាការបង្កើតព្រៃថ្មី។

រាជរដ្ឋាភិបាលកម្ពុជា បានបង្ហាញនូវការគាំទ្រក្នុងការបង្កើតឲ្យមានវិធីសាស្រ្តសម្រាប់អនុវត្ត រេដ+ ដោយបានអនុម័តឲ្យមានគម្រោងសាកល្បងចំនួន២នៅឆ្នាំ២០០៨ និងឆ្នាំ២០០៩។ បន្ទាប់ពីនេះ មានគម្រោងសាកល្បងជាច្រើន បានចាប់ផ្តើមបង្កើត និងអនុវត្ត ដែលមានវឌ្ឍនភាពស្ថិតក្នុងដំណាក់កាលខុសៗគ្នា។ នៅឆ្នាំ២០១០ រាជរដ្ឋាភិបាលកម្ពុជា បានរៀបចំដំណើរការផែនការត្រៀមលក្ខណៈសម្រាប់ រេដ+ ដែលនាំទៅដល់ការបង្កើតសំណើផែនការត្រៀមលក្ខណៈសម្រាប់ រេដ+ នៅកម្ពុជា (ផែនទីបង្ហាញផ្លូវ)។ ឯកសារនេះបង្ហាញថាតើកម្ពុជានឹងបង្កើត គោលនយោបាយ និងវិធានការអ្វីខ្លះដើម្បីត្រៀមលក្ខណៈជាស្រេចសម្រាប់ រេដ+ ។

ប្រព័ន្ធធានាសុវត្ថិភាពរេដ+ (REDD+ Safeguards) ត្រូវបានបញ្ចូលនៅក្នុងកិច្ចព្រមព្រៀងកាន់គុន(Cancun Agreements) ដើម្បីធានាថា សកម្មភាពនានាក្នុងក្របខ័ណ្ឌ រេដ+ មិនបង្កផលប៉ះពាល់អវិជ្ជមានមកលើសង្គម ឬ បរិស្ថានឡើយ។ ប្រព័ន្ធធានាសុវត្ថិភាពរេដ+ ត្រូវបានចាត់ទុកជារួមថាជា គោលនយោបាយ ឬ វិធានការនានា ដែលមានគោលដៅធ្វើឲ្យមានឥទ្ធិពលដោយផ្ទាល់ ឬ ប្រយោលទៅលើ សហគមន៍ និងប្រព័ន្ធអេកូឡូស៊ី តាមរយៈការកំណត់អត្តសញ្ញាណ ការវិភាគ និងនៅទីបំផុត គឺមានមុខងារដើម្បីគ្រប់គ្រងហានិភ័យ និងឱកាសនានា។ ប្រសិនបើបានបង្កើតឡើង និងយកមកប្រើប្រាស់ដោយសមស្រប ប្រព័ន្ធធានាសុវត្ថិភាពរេដ+នេះអាចជួយ រេដ+ក្នុងការផ្តល់នូវពហុប្រយោជន៍ជាច្រើន។ នៅពេលដែលប្រព័ន្ធធានាសុវត្ថិភាពរេដ+នេះ ត្រូវបានចាត់ទុកថាជាគោលការណ៍ "មិនបង្កគ្រោះថ្នាក់" ដូច្នេះនៅពេលអនុវត្តសកម្មភាព រេដ+ នឹងផ្តល់នូវឱកាសដើម្បីទទួលផលបានច្រើនជាងល័ក្ខខណ្ឌធម្មតា នឹងសមស្របតាមគោលគំនិតអំពីពហុប្រយោជន៍ ។ ឧទាហរណ៍៖ សកម្មភាពនានាដែលទាក់ទងនឹង រេដ+ មិនត្រឹមតែការពារព្រៃឈើប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងអាចកែលម្អគុណភាពទឹក ដែលហូរចេញមកតាមទន្លេនានាពីក្នុងតំបន់នោះ និងកាត់បន្ថយហានិភ័យ នៃជំនន់ដីគំហុកបណ្តាលពីទឹកយ៉ាងច្រើនដែលហូរយ៉ាងហ័សនៅលើផ្ទៃដីផងដែរ។

កិច្ចព្រមព្រៀងកាន់គុន(Cancun Agreements)មានឧបសម្ព័ន្ធស្តីពីប្រព័ន្ធធានាសុវត្ថិភាពរេដ+ចំនួន៧ ដែលត្រូវគោរព និងដោះស្រាយតាមរយៈនៃការអនុវត្ត រេដ+ ។ តាមសេចក្តីសម្រេចនៃកិច្ចព្រមព្រៀងស្តីពី រេដ+ នៅកូបទី១៧

(COP17)នាទីក្រុង ដឺរបែន(DURBAN) បានផ្តល់សេចក្តីណែនាំបន្ថែមអំពីប្រព័ន្ធផ្តល់ព័ត៌មាន ថាតើប្រព័ន្ធធានាសុវត្ថិភាពរេដ+ត្រូវបានគោរព និងដោះស្រាយដោយរបៀបណា។

ការផ្តួចផ្តើមជាអន្តរជាតិជាច្រើន បានបង្កើតឡើងនូវបទដ្ឋាននានាដូចជា និយមន័យ ទំហំការងារ និងវិធីសាស្ត្រសម្រាប់វាស់វែង ឬ ត្រួតពិនិត្យលើប្រព័ន្ធធានាសុវត្ថិភាពរេដ+ មានលក្ខណៈស្រដៀងគ្នានឹងបទដ្ឋាន រេដ+ ដែលមាននៅក្នុងកិច្ចព្រមព្រៀងកាន់គុនដែរ។ ដូច្នេះតម្រូវការដាក់លាក់នៃបទដ្ឋានប្រព័ន្ធធានាសុវត្ថិភាព គឺអាស្រ័យតាមប្រភព ថវិកា គាំទ្រ។ ឧទាហរណ៍៖ គោលការណ៍ និង លក្ខណៈវិនិច្ឆ័យ បរិស្ថាន-សង្គម(SEPC) របស់កម្មវិធី UN-REDD ការផ្ទៀងផ្ទាត់បទដ្ឋានកាបូន (VCS) សម្ព័ន្ធសហគមន៍ស្តីពីអាកាសធាតុ និងជីវចម្រុះ(CCBA) ការសិក្សាពីយុទ្ធសាស្ត្របរិស្ថាន-សង្គម (SESA)។

ប្រទេសនីមួយៗ ត្រូវបង្កើតប្រព័ន្ធធានាសុវត្ថិភាពបរិស្ថាន-សង្គម ឲ្យបានសមស្រប និងមានវិធីសាស្ត្រដើម្បីធានាថា ពហុប្រយោជន៍ ត្រូវបានដាក់បញ្ចូលឲ្យមានសង្គតិភាពជាមួយកិច្ចព្រមព្រៀងជាអន្តរជាតិ ដំណើរការត្រូវមានការប្រឹក្សាយោបល់ឲ្យបានទូលំទូលាយ និងមានការទទួលស្គាល់ជាសាធារណៈ និងបានកាត់បន្ថយជាអតិបរមានូវហានិភ័យទៅដល់បរិស្ថាន-សង្គម និងអភិបាលកិច្ច និងស្របពេលជាមួយគ្នានេះ អាចបញ្ចៀសបាននូវការចំណាយខ្ពស់ក្នុងពេលអនុវត្ត។

ការបង្កើត រេដ+ នៅកម្ពុជា នឹងមានផលប៉ះពាល់ទៅលើអ្នកជាប់ពាក់ព័ន្ធជាច្រើន។ ផែនការប្រឹក្សាយោបល់និងការចូលរួម ត្រូវបានបង្កើតឡើង នៅក្នុងដំណើការបង្កើតផែនទីបង្ហាញផ្លូវ រេដ+ កម្ពុជា។ ផែនការនេះនឹងត្រូវអភិវឌ្ឍន៍បន្ថែមទៀតដើម្បីអនុញ្ញាតឲ្យអ្នកជាប់ពាក់ព័ន្ធអាចចូលរួមចាត់ចែង ក្នុងដំណើការត្រៀមលក្ខណៈសម្រាប់ការអនុវត្ត រេដ+ និងផ្តល់ឲ្យអ្នកពាក់ព័ន្ធ ទទួលបានព័ត៌មានអំពី រេដ+ និងដំណើការត្រៀមលក្ខណៈសម្រាប់ការអនុវត្ត រេដ+ ។

ការចូលរួមរបស់អ្នកពាក់ព័ន្ធ គឺជាប្រព័ន្ធធានាសុវត្ថិភាពមួយ នៅក្នុងកិច្ចព្រមព្រៀងកាន់គុណផងដែរ។

## ២. គោលបំណង

គោលបំណងរបស់ក្រុមការងារបច្ចេកទេសស្តីពីប្រព័ន្ធធានាសុវត្ថិភាពរេដ+គឺគាំទ្រការសិក្សា និងបង្កើតវិធីសាស្ត្រសម្រាប់ប្រព័ន្ធធានាសុវត្ថិភាពរេដ+ដោយរួមបញ្ចូល ការប្រឹក្សាយោបល់ជាមួយអ្នកពាក់ព័ន្ធ និងការចូលរួម ទៅក្នុងកម្មវិធី រេដ+ កម្ពុជា ។

## ៣. សមាជិកភាព

ក្រុមការងារបច្ចេកទេសប្រព័ន្ធធានាសុវត្ថិភាពមានសមាជិកមកពី៖

- ក្រសួងមហាផ្ទៃ ចំនួន១នាក់(អគ្គនាយកដ្ឋាន រដ្ឋបាលមូលដ្ឋាន)
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ចំនួន១នាក់(អគ្គនាយកដ្ឋាន ថាមពល)
- ក្រសួងអភិវឌ្ឍន៍ជនបទ ចំនួន១នាក់
- ការិយាល័យពាក់ព័ន្ធ រដ្ឋបាលព្រៃឈើ២នាក់,
- ការិយាល័យពាក់ព័ន្ធ អគ្គនាយកដ្ឋានរដ្ឋបាលការពារអភិរក្សធម្មជាតិ ១នាក់
- ការិយាល័យពាក់ព័ន្ធ រដ្ឋបាលជលផល១នាក់

- សមាជិកក្រុមប្រឹក្សាយោបល់ វេដ+ កម្ពុជា ចំនួន៣នាក់ ដែលមានជំនាញ និងបទពិសោធន៍ពាក់ព័ន្ធ (ក្រុមប្រឹក្សាយោបល់នឹងចាត់តាំងសមាជិកក្រុមមកចូលរួម)
- លេខាធិការដ្ឋានក្រុមការងារ វេដ+ កម្ពុជា ចំនួន២នាក់ នឹងត្រូវចាត់តាំងដោយ ប្រធានលេខាធិការដ្ឋាន។

សមាជិកទាំងអស់ត្រូវចាត់តាំងតំណាងមកចូលរួមជំនួសក្នុងកិច្ចប្រជុំនានា ប្រសិនបើមានធុរៈចាំបាច់។ យោងតាមតម្រូវការជាក់ស្តែង អង្គការមិនមែនរដ្ឋាភិបាលដែលមានបទពិសោធន៍ នឹងអាចអញ្ជើញមកចូលរួមក្នុងកិច្ចប្រជុំ។

## ៤. ប្រតិបត្តិការ

ក្រុមការងារបច្ចេកទេសប្រព័ន្ធធានាសុវត្ថិភាពវេដ+ត្រូវជួបប្រជុំប្រចាំខែ។ ប្រធានក្រុមការងារបច្ចេកទេស នឹងត្រូវជ្រើសរើសក្នុងចំណោមសមាជិកក្រុម និងអនុម័តដោយប្រធានលេខាធិការដ្ឋាន។ ប្រធានក្រុមការងារបច្ចេកទេស ជាប្រធានដឹកនាំកិច្ចប្រជុំ។ សមាជិកដែលមកពីលេខាធិការដ្ឋានម្នាក់ នឹងត្រូវតែងតាំងជាលេខាធិការ របស់ក្រុមការងារបច្ចេកទេស ។ លេខាធិការក្រុមបច្ចេកទេស ត្រូវធានាថា លិខិតអញ្ជើញចូលរួមកិច្ចប្រជុំ ដោយមានភ្ជាប់ឯកសារដែលត្រូវពិភាក្សា បានផ្ញើជូនដល់គ្រប់សមាជិករយៈពេល១សប្តាហ៍មុនកិច្ចប្រជុំ។ លេខាធិការត្រូវធ្វើសេចក្តីព្រាងកំណត់ ហេតុកិច្ចប្រជុំ ជូនគ្រប់សមាជិកក្នុងរយៈពេល៣ថ្ងៃបន្ទាប់ពីកិច្ចប្រជុំ។ សមាជិក(ឬអ្នកជំនួស)ទាំងអស់ ត្រូវផ្តល់យោបល់លើសេចក្តីព្រាងកំណត់ហេតុកិច្ចប្រជុំក្នុងរយៈពេល៣ថ្ងៃ បន្ទាប់មកលេខាធិការ កែសម្រួលកំណត់ហេតុកិច្ចប្រជុំតាមការផ្តល់យោបល់ និងធ្វើកំណត់ហេតុសម្រេចជូនគ្រប់សមាជិកក្រុមការងារបច្ចេកទេស។ កំណត់ហេតុកិច្ចប្រជុំត្រូវមាន កាលបរិច្ឆេទ ពេលវេលា ទីកន្លែង ប្រធានបទជាបន្តបន្ទាប់ក្នុងកិច្ចប្រជុំ និងផ្សព្វផ្សាយជាសាធារណៈ ជូនដល់គ្រប់អ្នកពាក់ព័ន្ធ តាមរយៈក្រុមប្រឹក្សាយោបល់ និងដាក់នៅក្នុងគេហទំព័រ វេដ+ កម្ពុជា ។ ក្រុមការងារបច្ចេកទេស នឹងមានការជួយគាំទ្របច្ចេកទេស ពីអ្នកឯកទេសអន្តរជាតិ និងទីប្រឹក្សាបច្ចេកទេសអន្តរជាតិផងដែរ។

## ៥. ការធ្វើសេចក្តីសម្រេច

ក្រុមការងារបច្ចេកទេសប្រព័ន្ធធានាសុវត្ថិភាពវេដ+នេះមិនមែនជាអ្នកធ្វើសេចក្តីសម្រេចទេ ប៉ុន្តែជាអ្នកផ្តល់អនុសាសន៍ដល់ក្រុមការងារ វេដ+ កម្ពុជា និង លេខាធិការដ្ឋានក្រុមការងារ វេដ+ កម្ពុជា ជារៀងរាល់ខែ។ អនុសាសន៍នានានឹងត្រូវធ្វើឡើងតាមគោលការណ៍នៃការឯកភាពមតិ។

## ៦. ការទទួលខុសត្រូវ

ក្រុមការងារបច្ចេកទេសប្រព័ន្ធធានាសុវត្ថិភាពវេដ+នេះ ត្រូវធ្វើការជាមួយលេខាធិការដ្ឋានក្រុមការងារ វេដ+ កម្ពុជា ដើម្បីគាំទ្រដល់ការបង្កើតវិធីសាស្រ្តនានាសម្រាប់រៀបចំប្រព័ន្ធការពារសុវត្ថិភាពបរិស្ថាន-សង្គម ដោយរួមបញ្ចូលឲ្យមានការចូលរួមពីអ្នកពាក់ព័ន្ធឲ្យបានពេញលេញ មានប្រសិទ្ធិភាព និងធានាបាននូវពហុប្រយោជន៍។ រៀបចំដំណើរការប្រឹក្សាយោបល់ ត្រូវសម្រេចឲ្យបាននូវការគាំទ្រ និងទទួលយកជាទូទៅអំពីវិធីសាស្រ្តប្រឹក្សាយោបល់នេះ។ ការទទួលខុសត្រូវនេះរួមមាន៖

- ការរៀបចំ និងកែសម្រួលផែនការលម្អិត
- អនុវត្តសកម្មភាពបង្កើនការយល់ដឹងស្តីពីប្រព័ន្ធធានាសុវត្ថិភាពវេដ
- អនុវត្តសកម្មភាពកសាងសមត្ថភាពស្តីពីប្រព័ន្ធធានាសុវត្ថិភាពវេដ
- អនុវត្តការសិក្សា ឬ ចាត់ចែងការសិក្សា ពាក់ព័ន្ធនិងវិធីសាស្រ្តក្នុងការរៀបចំប្រព័ន្ធធានាសុវត្ថិភាពបរិស្ថាន-សង្គម ដែលមានស្រាប់នៅក្នុង និងក្រៅប្រទេស។
- អនុវត្តផ្ទាល់ ឬ ជួយសិក្សា គោលការណ៍និងលក្ខណៈវិនិច្ឆ័យប្រព័ន្ធធានាសុវត្ថិភាពវេដ ដែលមានស្រាប់

(ឧទាហរណ៍UNFCCC, UN-REDD, FCPF, CCBA and CI )

- អនុវត្តផ្ទាល់ ឬ ជួយសិក្សា បទពិសោធន៍អនុវត្តប្រព័ន្ធជានាសុវត្ថិភាព ដែលមានស្រាប់នៅក្នុង និងក្រៅប្រទេស
- អនុវត្តផ្ទាល់ ឬ ជួយវិភាគ ច្បាប់ គោលនយោបាយ វិធាននានា ដែលដោះស្រាយបញ្ហាពាក់ព័ន្ធនឹងប្រព័ន្ធជានាសុវត្ថិភាព
- អនុវត្តផ្ទាល់ ឬ ជួយចាត់ចែងការសិក្សាស្តីពីសក្តានុពលរបស់រេដ និងពហុប្រយោជន៍
- សម្របសម្រួលជាមួយដៃគូនានា (ឧទា: អង្គការមិនមែនរដ្ឋាភិបាលផ្តល់ជំនួយអន្តរជាតិ)ដែលធ្វើការងារក្នុងវិស័យដូចគ្នា
- បង្កើតសំណើស្តីពី សមាសជាតុ និងវិធីសាស្ត្រថ្នាក់ជាតិ ក្នុងការរៀបចំប្រព័ន្ធជានាសុវត្ថិភាពរេដជាតិ ដោយរួមបញ្ចូលបញ្ហា FPIC និងពហុប្រយោជន៍
- បង្កើតសំណើស្តីពី ដំណើរការ វិធាន និងនិតិវិធីជាក់លាក់ ក្នុងការដោះស្រាយបញ្ហា ពាក់ព័ន្ធនឹងសមាសជាតុនានានៅក្នុងប្រព័ន្ធជានាសុវត្ថិភាពរេដ(ដូចជាបញ្ហា FPIC) ដែលបានកំណត់ខាងលើ
- បង្កើតសំណើស្តីពីការត្រួតពិនិត្យ និងរាយការណ៍ ថាតើប្រព័ន្ធជានាសុវត្ថិភាពរេដបានដោះស្រាយ និងគោរពដោយរបៀបណា ដោយយោងតាមកិច្ចព្រមព្រៀង UNFCCC
- បង្កើតសំណើស្តីពីយន្តការដោះស្រាយទំនាស់ ដើម្បីកំណត់ និងដោះស្រាយ នូវទំនាស់ដែលកើតមានឡើងដោយសាររេដឲ្យមានប្រសិទ្ធភាព
- ផ្តល់ការណែនាំបច្ចេកទេស សម្រាប់ការអនុវត្តប្រព័ន្ធជានាសុវត្ថិភាពរេដជាតិ ដោយរួមបញ្ចូលទាំងការត្រួតពិនិត្យ និងការរាយការណ៍
- គ្រោងឡើងនូវដំណើរការប្រឹក្សាយោបល់ ពាក់ព័ន្ធនឹងសមាជាតុនានា ដោយផ្អែកលើយន្តការប្រឹក្សាយោបល់រេដដែលមានស្រាប់នៅកម្ពុជា ដោយធានាឲ្យបាននូវការចូលរួមយ៉ាងទូលំទូលាយពីគ្រប់ភាគីពាក់ព័ន្ធ
- ផ្អែកតាមមតិយោបល់ដែលទទួលបានពីដំណើរការប្រឹក្សាយោបល់ ដាក់ជូនក្រុមការងាររេដ+កម្ពុជា នូវសំណើប្រព័ន្ធជានាសុវត្ថិភាពរេដជាតិ និងវិធាននានាដើម្បីធានាពហុប្រយោជន៍ ដោយរួមបញ្ចូលទាំងប្រព័ន្ធផ្តល់ព័ត៌មានថាតើប្រព័ន្ធជានាសុវត្ថិភាពរេដ ដោះស្រាយដោយរបៀបណា និងថាតើប្រព័ន្ធជានាសុវត្ថិភាពរេដ គោរពតាមគោលការណ៍ណែនាំ ដែលបាន ព្រមព្រៀង នៅក្នុងអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (UNFCCC) ដែរឬទេ។

*ភារកិច្ចជាក់លាក់របស់ក្រុមបច្ចេកទេស៖*

- ការចូលរួមប្រជុំប្រចាំខែ
- ការពិនិត្យឯកសារ និងបទបង្ហាញនានា និងផ្តល់យោបល់ កែលម្អលើឯកសារ និងបទបង្ហាញទាំងនោះ
- ផ្តល់ការណែនាំ និងជំនួយដល់ទីប្រឹក្សា និងបុគ្គលិកលេខាធិការដ្ឋានក្នុងការសិក្សា និងការព្រាងសំណើ
- ចូលរួមនៅក្នុងវគ្គបណ្តុះបណ្តាល និងសិក្ខាសាលានានា។

ដោយសារមានកិច្ចការងារជាច្រើនដែលត្រូវបំពេញ ក្រុមបច្ចេកទេសត្រូវបង្កើតផែនការការងារ និងមានកំណត់ទំហំការងារ ដាក់លាក់ដែលត្រូវសម្រេចឲ្យបាន ដោយមានការពិភាក្សាជាមួយលេខាធិការដ្ឋានក្រុមការងារ រេដ+ កម្ពុជា ដើម្បីចាត់អាទិភាពការងារ។

## ៧. ការធ្វើរបាយការណ៍

សមាជិកក្រុមការងារបច្ចេកទេសនេះ ត្រូវទទួលខុសត្រូវធ្វើរបាយការណ៍ និងប្រឹក្សាយោបល់ជាមួយស្ថាប័នសាមី និង

ក្រុមគោលដៅរបស់ខ្លួន។ សមាជិកទាំងនេះអាចស្នើសុំឲ្យមានការផ្តល់ពេលវេលាជាបន្ថែមដើម្បីពិចារណាបញ្ហាជាក់លាក់នានា ប្រសិនបើយល់ថា បញ្ហាទាំងនោះមានសារៈសំខាន់ជាពិសេស ចំពោះស្ថាប័នរបស់ខ្លួន និងតម្រូវឲ្យមានការពិភាក្សាជាបន្ថែម។

ក្រុមការងារបច្ចេកទេសប្រព័ន្ធជានាសុវត្ថិភាពរេដ+ ត្រូវធ្វើសេចក្តីរាយការណ៍ដោយផ្ទាល់ទៅលេខាធិការដ្ឋានក្រុមការងារ រេដ+ កម្ពុជា តាមរយៈលេខាធិការ ក្រុមបច្ចេកទេសនេះ។

## ៨. រយៈពេល និងថេរវេលា

សមាជិកត្រូវធ្វើការរវាង ៣ ទៅ ៥ ថ្ងៃក្នុងមួយខែ អាស្រ័យលើសកម្មភាពដែលត្រូវអនុវត្ត។ ល័ក្ខខ័ណ្ឌប្រតិបត្តិនេះ អាចនឹងកែសម្រួលនៅ ខែឧសភា ឆ្នាំ២០១៥។

## ៩. ថវិកាគាំទ្រ

ការគាំទ្រថវិកា នឹងផ្តល់ដោយ កម្មវិធី UN-REDD និង គម្រោង FCPF (R-PP) ដោយយោងទៅតាមថវិកាដែលបានអនុម័ត សម្រាប់ការចំណាយ នៅក្នុងអំឡុងពេលនៃការអនុវត្តកិច្ចការនានាដែលទាក់ទងនឹងតួនាទីទាំងនេះ។ ការគាំទ្រមកពីក្របខ័ណ្ឌការងារផ្សេងទៀតនឹងត្រូវពិចារណាផងដែរ៕

# ក្រុមការងារបច្ចេកទេសអនុវត្តគម្រោងគំរូរេដបូក

(REDD+ Demonstration Technical Team)

## ១. សាវតា

យន្តការអនាគតសម្រាប់ការកាត់បន្ថយការបញ្ចេញឧស្ម័នដែលបណ្តាលមកពីការការបាត់បង់ និងរិចរឹលព្រៃឈើ(រេដ+) ដែលកំពុងរៀបចំតាមរយៈអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (UNFCCC) នឹងផ្តល់ឱកាសដល់កិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជា ដើម្បីកាត់បន្ថយកម្រិតនៃការរិចរឹលព្រៃឈើ និងជួយថែរក្សាការពារព្រៃធម្មជាតិ ក៏ដូចជាការបង្កើតព្រៃថ្មី។

រាជរដ្ឋាភិបាលកម្ពុជា បានបង្ហាញនូវការគាំទ្រក្នុងការបង្កើតឲ្យមានវិធីសាស្រ្តសម្រាប់អនុវត្ត រេដ+ ដោយបានអនុម័តឲ្យមានគម្រោងសាកល្បងចំនួន២នៅឆ្នាំ២០០៨ និងឆ្នាំ២០០៩។ បន្ទាប់ពីនេះ មានគម្រោងសាកល្បងជាច្រើន បានចាប់ផ្តើមបង្កើត និងអនុវត្ត ដែលមានវឌ្ឍនភាពស្ថិតក្នុងដំណាក់កាលខុសៗគ្នា។ នៅឆ្នាំ២០១០ រាជរដ្ឋាភិបាលកម្ពុជា បានរៀបចំដំណើរការផែនការត្រៀមលក្ខណៈសម្រាប់ រេដ+ ដែលនាំទៅដល់ ការបង្កើតសំណើផែនការត្រៀមលក្ខណៈសម្រាប់ រេដ+នៅកម្ពុជា (ផែនទីបង្ហាញផ្លូវ)។ ឯកសារនេះបង្ហាញថាតើកម្ពុជានឹងបង្កើត គោលនយោបាយ និងវិធានការអ្វីខ្លះដើម្បីត្រៀមលក្ខណៈជាស្រេចសម្រាប់ រេដ+។

យោងតាមគោលបំណងរបស់ UNFCCC, ការកាត់បន្ថយការបញ្ចេញឧស្ម័នដែលបណ្តាលមកពីការការបាត់បង់ និងរិចរឹលព្រៃឈើ(រេដ+) គឺជាការអនុវត្តនៅកម្រិតជាតិ ប៉ុន្តែព្រមពេលជាមួយគ្នានេះ ក៏អនុញ្ញាតឲ្យមានការអនុវត្ត រេដ+ ផងដែរនៅកម្រិតថ្នាក់ក្រោមជាតិ ទៅតាមវិធានការបណ្តោះអាសន្ន និងរីកចម្រើនឈានដល់ការអនុវត្តនៅកម្រិតជាតិ។ ស្របពេលជាមួយគ្នានេះ បទដ្ឋានកាបូនជាច្រើន ដែលហៅថាទីផ្សារកាបូនស្ម័គ្រចិត្ត បានគ្រប់គ្រង និងប្រើជារបៀបសម្រាប់អនុវត្តនៅថ្នាក់គម្រោង។វិធីសាស្រ្តទាំងបីបែបនេះ មានការលំបាក និងឱកាសផ្សេងៗគ្នា ដែលតម្រូវឲ្យបណ្តាប្រទេសនីមួយៗ ត្រូវវិភាគ ថ្លឹងថ្លែងពិចារណា ដោយផ្អែកលើកាលៈទេសៈ និងសមត្ថភាព ដើម្បីសម្រេចជ្រើសរើសយកវិធីសាស្រ្តណាមួយដែលប្រសើរបំផុត។

ដោយរួមបញ្ចូលការអនុវត្តនៅកម្រិតជាតិ និងកម្រិតថ្នាក់ក្រោមជាតិ ត្រូវបានស្នើឡើងនៅក្នុងការចរចារជាអន្តរជាតិ ថាជាមធ្យោបាយក្នុងការប្រចាប់បញ្ចូលសកម្មភាពនៅថ្នាក់ក្រោមជាតិ ទៅក្នុងក្របខ័ណ្ឌគណនីជាតិ តាមរយៈ“ វិធីសាស្រ្តសំបុកសត្វ” (“ nested approach” )។ ក្នុងគោលបំណងធ្វើឲ្យបានប្រសើរបំផុត វិធីសាស្រ្តនេះនឹងរួមបញ្ចូលឲ្យមានអន្តរកាលនៅក្នុងគណនីរបស់ជាតិ ដែលនៅក្នុងពេលនេះអនុញ្ញាតឲ្យមានឥណទានសម្រាប់សកម្មភាពគម្រោងជាលក្ខណៈបុគ្គល ដែលជាវិធីសាស្រ្តកណ្តាល ដើម្បីជៀសវាងការថយចុះ។ ជាមួយគ្នានេះ បទដ្ឋានកាបូនទីផ្សារស្ម័គ្រចិត្ត ក៏នឹងបង្កើតវិធីសាស្រ្តសំបុកសត្វផងដែរ សម្រាប់គម្រោងជាលក្ខណៈបុគ្គល នៅក្នុងគណនី ថ្នាក់ក្រោមជាតិ(តាមដែនយុត្តាធិការ)។ តារាងដែលបានពីការសិក្សាឯកសារ បង្ហាញពីគុណសម្បត្តិ និងគុណវិបត្តិ ដូចមានបង្ហាញក្នុងឧបសម្ព័ន្ធ១។

បញ្ហាកាន់តែស្មុគស្មាញបន្ថែមទៀតនោះ ប្រទេសនានាត្រូវសម្រេចពីកំរិតនៃការអនុវត្ត ដោយមិនផ្តល់ព័ត៌មានពីអ្វីដែលត្រូវទាមទារក្នុងការផ្តល់ហិរញ្ញប្បទានសម្រាប់ការអនុវត្តរេដ+ នាពេលអនាគត ដោយសារតែនាពេលបច្ចុប្បន្ន ការចរចារអំពីរេដ+ កំពុងតែបន្ត និងស្របពេលជាមួយគ្នានេះ ទីផ្សារកាបូនស្ម័គ្រចិត្តនៅថ្នាក់តំបន់កំពុងអភិវឌ្ឍន៍។ ភាពមិនច្បាស់លាស់ និងគោលការណ៍ណែនាំដែលមានស្រាប់របស់ UNFCCC ស្តីពីការអនុវត្តនៅកម្រិតថ្នាក់ក្រោមជាតិ បានបញ្ជាក់ពីសារសំខាន់នៃការបង្កើតប្រព័ន្ធមួយ ដែលមានភាពទន់ភ្លន់សម្រាប់វាស់វែង ការបូន និងកំណត់កំរិតយោង ក្នុងទម្រង់ដែលអនុញ្ញាតឲ្យមានទំនាក់ទំនងនឹងការត្រួតពិនិត្យ និងការរាយការណ៍នៅថ្នាក់ជាតិ ដោយមិនគិតពីកំរិតនៃការអនុវត្តមានការចូលចិត្តឡើយ។

ប្រសិនបើ រេដ+ នៅកម្ពុជា មានការវិវឌ្ឍន៍ប្រកបដោយភាពស័ក្តិសិទ្ធិ និងមានប្រសិទ្ធិភាព ជាការសំខាន់ណាស់ដែលព័ត៌មាន និងមេរៀនជាបទពិសោធន៍ ដែលបានមកពីគម្រោងសាកល្បង ក៏ដូចជាព័ត៌មានស្តីពីការអនុវត្ត រេដ+ តាមទម្រង់ផ្សេងៗនៅក្នុងប្រទេសនានា ត្រូវបានចែករំលែក និងវិភាគ ដើម្បីជួយដល់ការសម្រេចចិត្ត ថាតើ រេដ+ នៅកម្ពុជាត្រូវអនុវត្តដោយរបៀបណា ។

## ២. គោលបំណង

គោលបំណងរបស់ក្រុមការងារបច្ចេកទេសស្តីពីការអនុវត្តគម្រោងគំរូ គឺជានាថាមេរៀន និងបទពិសោធន៍ ដែលបានមកពីការអនុវត្តគម្រោងគំរូ ត្រូវបានកត់ត្រា និងវិភាគ ដើម្បីគាំទ្រដល់ការបង្កើតវិធីសាស្រ្ត សម្រាប់អនុវត្តនៅថ្នាក់ក្រោមជាតិ ដែលជាផ្នែកមួយនៃកម្មវិធីរេដ+ថ្នាក់ជាតិ។ ក្រុមការងារបច្ចេកទេសអនុវត្តគម្រោងគំរូ ត្រូវគាំទ្រដល់ការបង្កើតគោលការណ៍ណែនាំ សម្រាប់វិធីសាស្រ្តអនុវត្តនៅថ្នាក់ក្រោមជាតិ ដែលជាផ្នែកមួយនៃវិធីសាស្រ្តសំបុកសត្វ នៅក្នុងក្របខ័ណ្ឌការងារថ្នាក់ជាតិ ដោយរួមបញ្ចូលទាំងអនុសាសន៍សម្រាប់អនុវត្តគម្រោងគំរូផងដែរ ។

## ៣. សមាជិកភាព

ក្រុមការងារបច្ចេកទេសអនុវត្តគម្រោងគំរូមានសមាជិកមកពី៖

- ក្រសួងមហាផ្ទៃ ចំនួន១នាក់(អគ្គនាយកដ្ឋាន រដ្ឋបាលមូលដ្ឋាន)
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ចំនួន១នាក់(អគ្គនាយកដ្ឋាន ថាមពល)
- ក្រសួងអភិវឌ្ឍន៍ជនបទ ចំនួន១នាក់
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ចំនួន១នាក់
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុចំនួន១នាក់
- ការិយាល័យពាក់ព័ន្ធ រដ្ឋបាលព្រៃឈើ១នាក់,
- ការិយាល័យពាក់ព័ន្ធ អគ្គនាយកដ្ឋានរដ្ឋបាលការពារអភិរក្សធម្មជាតិ ១នាក់
- ការិយាល័យពាក់ព័ន្ធ រដ្ឋបាលជលផល១នាក់
- សមាជិកក្រុមប្រឹក្សាយោបល់ រេដ+ កម្ពុជា ចំនួន៣នាក់ ដែលមានជំនាញ និងបទពិសោធន៍ពាក់ព័ន្ធ (ក្រុមប្រឹក្សាយោបល់នឹងចាត់តាំងសមាជិកក្រុមមកចូលរួម)
- លេខាធិការដ្ឋានក្រុមការងារ រេដ+ កម្ពុជា ចំនួន២នាក់ នឹងត្រូវចាត់តាំងដោយ ប្រធានលេខាធិការដ្ឋាន។

សមាជិកទាំងអស់ត្រូវចាត់តាំងតំណាងមកចូលរួមជំនួសក្នុងកិច្ចប្រជុំនានា ប្រសិនបើមានធុរៈចាំបាច់។ យោងតាមតម្រូវការជាក់ស្តែង អង្គការមិនមែនរដ្ឋាភិបាលដែលមានបទពិសោធន៍ នឹងអាចអញ្ជើញមកចូលរួមក្នុងកិច្ចប្រជុំ។

## ៤. ប្រតិបត្តិការ

ក្រុមការងារបច្ចេកទេសអនុវត្តគម្រោងគំរូរេដ+ត្រូវជួបប្រជុំប្រចាំខែ។ ប្រធានក្រុមការងារបច្ចេកទេស នឹងត្រូវជ្រើសរើសក្នុងចំណោមសមាជិកក្រុម និងអនុម័តដោយប្រធានលេខាធិការដ្ឋាន។ ប្រធានក្រុមការងារបច្ចេកទេស ជាប្រធានដឹកនាំកិច្ចប្រជុំ។ សមាជិកដែលមកពីលេខាធិការដ្ឋានម្នាក់ នឹងត្រូវតែងតាំងជាលេខាធិការ របស់ក្រុមការងារបច្ចេកទេស ។ លេខាធិការក្រុមបច្ចេកទេសអនុវត្តគម្រោងគំរូរេដ+ ត្រូវជានាថាលិខិតអញ្ជើញចូលរួមកិច្ចប្រជុំដោយមានភ្ជាប់ឯកសារដែលត្រូវពិភាក្សា បានផ្ញើជូនដល់គ្រប់សមាជិក រយៈពេល១សប្តាហ៍មុនកិច្ចប្រជុំ។ លេខាធិការត្រូវផ្ញើសេចក្តីព្រាងកំណត់ ហេតុកិច្ចប្រជុំជូនគ្រប់សមាជិកក្នុងរយៈពេល៣ថ្ងៃបន្ទាប់ពីកិច្ចប្រជុំ។ សមាជិកទាំងអស់ត្រូវផ្តល់យោបល់លើសេចក្តីព្រាងកំណត់ហេតុ កិច្ចប្រជុំក្នុងរយៈពេល៣ថ្ងៃ បន្ទាប់មកលេខាធិការ កែសម្រួលកំណត់ហេតុកិច្ចប្រជុំតាមការផ្តល់យោបល់ និងផ្ញើកំណត់ហេតុសម្រេចជូនគ្រប់សមាជិកក្រុមបច្ចេកទេស។ កំណត់ហេតុកិច្ចប្រជុំត្រូវមាន កាលបរិច្ឆេទ ពេលវេលា ទីកន្លែង ប្រធានបទជាបន្តបន្ទាប់ក្នុងកិច្ចប្រជុំ និងផ្សព្វផ្សាយជាសាធារណៈ ជូនដល់គ្រប់អ្នកពាក់ព័ន្ធ តាមរយៈក្រុមប្រឹក្សាយោបល់ និងដាក់នៅក្នុងគេហទំព័ររេដ+កម្ពុជា។ ក្រុមការងារបច្ចេកទេសអនុវត្តគម្រោងគំរូរេដ+ នឹងមានការជួយគាំទ្របច្ចេកទេស ពីអ្នកឯកទេសអន្តរជាតិ និងទីប្រឹក្សាបច្ចេកទេសជាតិ និងអន្តរជាតិផងដែរ។

## ៥. ការធ្វើសេចក្តីសម្រេច

ក្រុមការងារបច្ចេកទេសអនុវត្តគម្រោងគំរូនេះមិនមែនជាអ្នកធ្វើសេចក្តីសម្រេចទេ ប៉ុន្តែជាអ្នកផ្តល់អនុសាសន៍ដល់ក្រុមការងារ រេដ+ កម្ពុជា និង លេខាធិការដ្ឋានក្រុមការងារ រេដ+ កម្ពុជា ជារៀងរាល់ខែ។ អនុសាសន៍នានានឹងត្រូវធ្វើឡើង តាមគោលការណ៍នៃការឯកភាពមតិ។

## ៦. ការទទួលខុសត្រូវ

ក្រុមការងារបច្ចេកទេសអនុវត្តគម្រោងគំរូនេះ ត្រូវធ្វើការជាមួយលេខាធិការដ្ឋានក្រុមការងាររេដ+កម្ពុជា ដើម្បីគាំទ្រដល់ការបង្កើតគោលការណ៍ណែនាំ និងវិធីសាស្ត្រ សម្រាប់ការអនុវត្តគម្រោងគំរូនៅថ្នាក់ក្រោមជាតិ ដោយរួមបញ្ចូលទាំងការជ្រើសរើសតំបន់ សម្រាប់ការអនុវត្តគម្រោងគំរូផងដែរ។ ការបង្កើតគោលការណ៍ណែនាំ និងវិធីសាស្ត្រ នេះត្រូវផ្អែកលើមូលដ្ឋាននៃមេរៀន និងបទពិសោធន៍ ដែលដកស្រង់ចេញពីការអនុវត្តគម្រោងគំរូដែលមានស្រាប់។ ការងារបច្ចេកទេសរួមមាន៖

- អនុវត្តដោយផ្ទាល់ ឬ ចាត់ចែងឲ្យមានការសិក្សា ពីការអនុវត្តគម្រោងគំរូនៅក្នុង និងក្រៅប្រទេស និងវិធីសាស្ត្រអនុវត្តនៅថ្នាក់ក្រោមជាតិ
- សម្របសម្រួលជាមួយដៃគូដែលធ្វើការងារក្នុងវិស័យដូចគ្នា
- បង្កើតអនុសាសន៍សម្រាប់សកម្មភាពអនុវត្តគម្រោងគំរូរេដ+
- អនុវត្តដោយផ្ទាល់ ឬ ចាត់ចែងឲ្យមានការសិក្សា ពីបទពិសោធន៍ដែលមានស្រាប់សម្រាប់ការចុះបញ្ជី
- បង្កើតអនុសាសន៍សម្រាប់បែបបទនៃការចុះបញ្ជី រេដ+ នៅថ្នាក់ជាតិ
- ប្រឹក្សាយោបល់ជាមួយក្រុមបច្ចេកទេសដទៃទៀតនៅពេលដែលមានការពាក់ព័ន្ធ

ដើម្បីជៀសវាងបញ្ហាអនុវត្តការងារត្រួតលើគ្នា ជាការចាំបាច់ ក្រុមការងារបច្ចេកទេសអនុវត្តគម្រោងគំរូ ត្រូវធ្វើការ និងសម្របសម្រួលជាមួយ ក្រុមបច្ចេកទេសបីដទៃទៀត ដែលកំពុងដឹកនាំ និងបំពេញការងារលើ៖ ១)ការចែករំលែកផលប្រយោជន៍ ២)ប្រព័ន្ធធានាសុវត្ថិភាព និង ៣) ត្រួតពិនិត្យ រាយការណ៍ និងផ្ទៀងផ្ទាត់កំរិតយោង នៅថ្នាក់ជាតិ ។ ភារកិច្ចជាក់លាក់របស់ក្រុមនេះត្រូវពិចារណាថាតើ សមាសភាគទាំងអស់អាចអនុវត្តវិធីសាស្ត្រដោយរបៀបណានៅថ្នាក់ក្រោមជាតិ និង

បន្ទាប់មកវិធីសាស្រ្តអនុវត្តនៅថ្នាក់ជាតិ។

ក្រុមការងារបច្ចេកទេសអនុវត្តគម្រោងគំរូនឹងផ្តល់អនុសាសន៍ដល់ក្រុមការងារ រេដ+ កម្ពុជាតាមរយៈ

- ពិនិត្យរបាយការណ៍គម្រោងសាកល្បង រេដ+ និងឯកសារផ្សេងៗ
- ពិភាក្សាជាមួយអ្នកគ្រប់គ្រងគម្រោង និងអ្នកពាក់ព័ន្ធនឹងការគាំទ្រកម្មវិធី រេដ+
- ចុះពិនិត្យដល់ទីវាលប្រសិនបើមានការចាំបាច់

*<u>ភារកិច្ចជាក់លាក់របស់ក្រុមបច្ចេកទេស៖</u>*

- ការចូលរួមប្រជុំប្រចាំខែ
- ការពិនិត្យឯកសារ និងបទបង្ហាញនានា និងផ្តល់យោបល់ កែលម្អលើឯកសារ និងបទបង្ហាញទាំងនោះ
- ផ្តល់ជាជំនួយដល់ទីប្រឹក្សា និងបុគ្គលិក លេខាធិការដ្ឋានក្រុមការងារ រេដ+ កម្ពុជា ក្នុងការអនុវត្តកិច្ចការរបស់ពួកគេ
- ចូលរួមនៅក្នុងវគ្គបណ្តុះបណ្តាល និងសិក្ខាសាលានានា។

ដោយសារមានកិច្ចការងារជាច្រើនដែលត្រូវបំពេញ ក្រុមការងារបច្ចេកទេសអនុវត្តគម្រោងគំរូត្រូវបង្កើតផែនការការងារ និងមានកំណត់ទំហំការងារ ជាក់លាក់ដែលត្រូវសម្រេចឲ្យបាន ដោយមានការពិភាក្សាជាមួយលេខាធិការដ្ឋានក្រុមការងារ រេដ+ កម្ពុជា ដើម្បីចាត់អាទិភាពការងារ។

## ៧. ការធ្វើរបាយការណ៍

សមាជិកក្រុមការងារបច្ចេកទេសអនុវត្តគម្រោងគំរូនេះ ត្រូវទទួលខុសត្រូវធ្វើរបាយការណ៍និងប្រឹក្សាយោបល់ជាមួយស្ថាប័ន សាមី និងក្រុមគោលដៅរបស់ខ្លួន។ សមាជិកទាំងនេះអាចស្នើសុំឲ្យមានការផ្តល់ពេលវេលាជាបន្ថែមដើម្បីពិចារណាបញ្ហាជាក់លាក់នានា ប្រសិនបើយល់ថា បញ្ហាទាំងនោះមានសារៈសំខាន់ជាពិសេស ចំពោះស្ថាប័នរបស់ខ្លួន និងតម្រូវឲ្យមានការពិភាក្សាជាបន្ថែម។

ក្រុមការងារបច្ចេកទេសអនុវត្តគម្រោងគំរូ ត្រូវធ្វើសេចក្តីរាយការណ៍ដោយផ្ទាល់ទៅលេខាធិការដ្ឋានក្រុមការងារ រេដ+ កម្ពុជា តាមរយៈលេខាធិការ ក្រុមបច្ចេកទេសនេះ។

## ៨. រយៈពេល និងថេរវេលា

សមាជិកត្រូវធ្វើការប្រមាណជា១ថ្ងៃ ទៅ ៣ថ្ងៃ ក្នុងមួយខែ អាស្រ័យលើសកម្មភាពដែលត្រូវអនុវត្ត។ ល័ក្ខខ័ណ្ឌប្រតិបត្តិនេះអាចនឹងកែសម្រួលបានទៅតាមការស្នើសុំរបស់ក្រុមការងារបច្ចេកទេស ដោយមានការអនុម័តពីក្រុមការងារ រេដ+ កម្ពុជា។

## ៩. ថវិកាគាំទ្រ

ការគាំទ្រថវិកា នឹងផ្តល់ដោយ កម្មវិធី UN-REDD និង គម្រោង FCPF (R-PP) ដោយយោងទៅតាមថវិកាដែលបានអនុម័ត សម្រាប់ការចំណាយ នៅក្នុងអំឡុងពេលនៃការអនុវត្តកិច្ចការនានាដែលទាក់ទងនឹងតួនាទីទាំងនេះ។ ការគាំទ្រមកពីក្របខ័ណ្ឌការងារផ្សេងទៀតនឹងត្រូវពិចារណាផងដែរ៕

ក្រុមការងារបច្ចេកទេសត្រួតពិនិត្យ រាយការណ៍ ផ្ទៀងផ្ទាត់ កំរិតយោងនៃការបញ្ចេញឧស្ម័ន
(REDD+ MRV/REL Technical Team)

## ១. សាវតា

យន្តការអនាគតសម្រាប់ការកាត់បន្ថយការបញ្ចេញឧស្ម័នដែលបណ្ដាលមកពីការការបាត់បង់ និងរិចរឹលព្រៃឈើ(រេដ+) ដែលកំពុងរៀបចំតាមរយៈអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្ដីពីការប្រែប្រួលអាកាសធាតុ (UNFCCC) នឹងផ្ដល់ឱកាសដល់កិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជា ដើម្បីកាត់បន្ថយកម្រិតនៃការរិចរឹលព្រៃឈើ និងជួយថែរក្សាការពារព្រៃធម្មជាតិ ក៏ដូចជាការបង្កើតព្រៃថ្មី។ សកម្មភាពចំនួន៥បានចុះបញ្ជីស្ថិតក្រោមយន្តការរេដ+(សន្និសិទ្ធលើកទី១៦ របស់បណ្ដាភាគី សេចក្ដីសម្រេចទី១ កថាខ័ណ្ឌទី៧០) រួមមាន៖ ១)ការកាត់បន្ថយការបញ្ចេញឧស្ម័នបណ្ដាលមកពីការការបាត់បង់ព្រៃឈើ ២)ការកាត់បន្ថយការបញ្ចេញឧស្ម័នបណ្ដាល មកពីការការបាត់បង់ និងរិចរឹលព្រៃឈើ ៣)ការអភិរក្សព្រៃកាបូនស្តុក ៤)ការគ្រប់គ្រងព្រៃឈើដោយនិរន្តរភាព ៥)ការពង្រឹងនិងពង្រីកព្រៃឈើកាបូនស្តុក។

នៅឆ្នាំ២០១០ ដោយមានការគាំទ្រពី កម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ(UNDP) និងអង្គការស្បៀងនិងកសិកម្មសហប្រជាជាតិ(FAO)ប្រចាំកម្ពុជា រាជរដ្ឋាភិបាលកម្ពុជា បានរៀបចំដំណើរការផែនការត្រៀមលក្ខណៈសម្រាប់ រេដ+ ដែលនាំទៅដល់ ការបង្កើតសំណើផែនការត្រៀមលក្ខណៈសម្រាប់ រេដ+នៅកម្ពុជា (ផែនទីបង្ហាញផ្លូវ)។ ឯកសារនេះបង្ហាញថាតើកម្ពុជានឹងបង្កើតគោលនយោបាយ និងវិធានការអ្វីខ្លះដើម្បីត្រៀមលក្ខណៈជាស្រេចសម្រាប់ រេដ+។ សមាសភាគសំខាន់ដើម្បីត្រៀមលក្ខណៈ ជាស្រេចសម្រាប់ រេដ+ គឺត្រូវមានប្រព័ន្ធដ៏មានតម្លាភាពនៅនឹងកន្លែង មានវិធាន និងវិធីសាស្ត្រច្បាស់លាស់ សម្រាប់ការត្រួតពិនិត្យ និងចែករំលែកព័ត៌មាន។ ប្រព័ន្ធនេះត្រូវមានមុខងារពីរ ដើម្បីត្រួតពិនិត្យសកម្មភាព រេដ+ ១)មុខងារត្រួតពិនិត្យ ២)មុខងារវាស់វែង រាយការណ៍ និងផ្ទៀងផ្ទាត់។

**១)មុខងារត្រួតពិនិត្យ៖** ប្រព័ន្ធត្រួតពិនិត្យ រេដ+ ទាមទារឲ្យមានការប៉ាន់ប្រមាណតំបន់ព្រៃឈើ ដែលមានការប្រែប្រួលតាមពេលវេលា ដើម្បីប៉ាន់ប្រមាណថាតើ រេដ+ ទទួលបានលទ្ធផលជាវិជ្ជមានឬយ៉ាងណា? កម្ពុជាអាចប្រើប្រាស់ប្រព័ន្ធក្នុងស្រុក ដើម្បីវាយតម្លៃ គោលនយោបាយស្តារព្រៃឈើឡើងវិញ។

**២)មុខងារវាស់វែង រាយការណ៍ និងផ្ទៀងផ្ទាត់៖** សម្រាប់ រេដ+ ដើម្បីវាស់វែង ការបញ្ចេញ ឬ ការស្រូបយកឧស្ម័នដោយព្រៃឈើ និងការប្រែប្រួលការប្រើប្រាស់ដី ក៏ដូចជាការរាយការណ៍ពីការបញ្ចេញឧស្ម័ន (ឬការកាត់បន្ថយដោយសារសកម្មភាព រេដ+) ជូន UNFCCC ដើម្បីធ្វើសារពើភ័ណ្ឌពីការបញ្ចេញឧស្ម័ន និងពិនិត្យផ្ទៀងផ្ទាត់។ ដើម្បីឲ្យប្រព័ន្ធផ្អែកលើមូលដ្ឋាននៃលទ្ធផល ការបញ្ចេញនិង ការស្រូបយកឧស្ម័នដោយព្រៃឈើ និងការប្រែប្រួលការប្រើប្រាស់ដី ស្ថិតក្រោមសកម្មភាពទាំង៥របស់ រេដ+ គឺត្រូវធ្វើការប្រៀបធៀបជាមួយនិងទិន្នន័យដើម គឺកំរិតយោងនៃព្រៃឈើ (Forest Reference Levels) ឬ កំរិតយោងនៃការបញ្ចេញឧស្ម័ន (Reference Emission Levels)។

## ២. គោលបំណង

គោលបំណងរបស់ក្រុមការងារបច្ចេកទេសត្រួតពិនិត្យ រាយការណ៍ ផ្ទៀងផ្ទាត់ កំរិតយោងនៃការបញ្ចេញឧស្ម័ន (MRV/REL Technical Team) គឺជានាថាសមត្ថភាព បច្ចេកទេសពាក់ព័ន្ធនឹង រេដ+ បានផ្តល់ជូនស្ថាប័នក្រុមការងាររេដ+ លេខាធិការដ្ឋានរេដ+ និងសមាសភាគសំខាន់ៗរបស់រេដ+ ដើម្បីបំពេញមុខងារ ប្រកបដោយតម្លាភាព សង្គតិភាព ត្រួតពិនិត្យដោយគ្មានលំអៀង និងមានប្រព័ន្ធត្រួតពិនិត្យ រាយការណ៍ ផ្ទៀងផ្ទាត់ កំរិតយោងនៃការបញ្ចេញឧស្ម័ន ។

## ៣. ភារទទួលខុសត្រូវ

ការទទួលខុសត្រូវជាក់លាក់របស់ក្រុមបច្ចេកទេសត្រួតពិនិត្យ រាយការណ៍ ផ្ទៀងផ្ទាត់ កំរិតយោងនៃការបញ្ចេញឧស្ម័ន (MRV/ REL Technical Team) គឺ ៖

- បង្កើតចំណាត់ថ្នាក់ព្រៃឈើជាតិ
- បង្កើតប្រព័ន្ធមួយសម្រាប់កម្ពុជា ដែលបំពេញមុខងារ ត្រួតពិនិត្យ រាយការណ៍ ផ្ទៀងផ្ទាត់ កំរិតយោង រេដនៅកម្ពុជា
- បង្កើតប្រព័ន្ធវាយតម្លៃគម្របព្រៃឈើជាតិ ដោយផ្កាយរណប (design the satellite forest monitoring system) ដើម្បីជួយគាំទ្រដល់ការបង្កើតទិន្នន័យពាក់ព័ន្ធនឹងសកម្មភាពព្រៃឈើ ឲ្យស្របតាមការទាមទារសំណាកគំរូរបស់សារពើភ័ណ្ឌឧស្ម័នផ្ទះកញ្ចក់
- បង្កើតគំរូសារពើភ័ណ្ឌព្រៃឈើជាតិ ដើម្បីបង្កើតជាកត្តាសម្រាប់គណនាសកម្មភាពនានាដែលពាក់ព័ន្ធនឹងការបញ្ចេញ និងការស្រូបឧស្ម័ន ដែលបណ្តាលមកពីការការបាត់បង់ និងរិចរឹលព្រៃឈើ
- បង្កើតរយៈពេលយោង (reference period)
- បង្កើតកំរិតយោងថ្នាក់ជាតិ (National reference levels)
- បង្កើតកំរិតយោងក្របខ័ណ្ឌការងារ សម្រាប់គណនីនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- បង្កើតហេដ្ឋារចនាសម្ព័ន្ធបច្ចេកទេស ដើម្បីរៀបចំអនុវត្តប្រព័ន្ធវាស់វែង រាយការណ៍ និងផ្ទៀងផ្ទាត់ព្រៃឈើ
- កំណត់ស្ថាប័នទទួលខុសត្រូវក្នុងការត្រួតពិនិត្យ វាស់វែង រាយការណ៍ និងផ្ទៀងផ្ទាត់ ការកាត់បន្ថយការបញ្ចេញឧស្ម័នដែលបណ្តាល មកពីការការបាត់បង់ និងរិចរឹលព្រៃឈើ
- រក្សាទិន្នន័យដើមសម្រាប់ការត្រួតពិនិត្យ វាស់វែង រាយការណ៍ និងផ្ទៀងផ្ទាត់ ព្រៃឈើ
- សម្របសម្រួលដល់ការប្រើប្រាស់ និងចែកចាយទិន្នន័យដល់អ្នកពាក់ព័ន្ធ ត្រួតពិនិត្យ QC/QA និងផ្ទៀងផ្ទាត់។
- រៀបចំការធ្វើសារពើភ័ណ្ឌឧស្ម័នផ្ទះកញ្ចក់(GHG) ជាបណ្តោះអាសន្ន ដែលពាក់ព័ន្ធនិង ការប្រើប្រាស់ដី ការផ្លាស់ប្តូរការប្រើប្រាស់ដី និងព្រៃឈើ (LULUCF) ។
- បង្កើតផែនការអនុវត្តប្រចាំត្រីមាស និងប្រចាំឆ្នាំ និងកែសម្រួលផែនការ សម្រាប់ការគ្រប់គ្រងទិន្នន័យ
- បំពេញកាតាព្វកិច្ចដទៃទៀតដែលពាក់ព័ន្ធនឹងការបង្កើត និងការអភិវឌ្ឍន៍ប្រព័ន្ធ ត្រួតពិនិត្យ វាស់វែង រាយការណ៍ និងផ្ទៀងផ្ទាត់ ការកាត់បន្ថយការបញ្ចេញឧស្ម័នដែលបណ្តាល មកពីការការបាត់បង់ និងរិចរឹលព្រៃឈើ។

ភារកិច្ចនិងការទទួលខុសត្រូវជាក់លាក់របស់សមាជិកនីមួយៗរួមមានៈ

- ចូលរួមក្នុងកិច្ចប្រជុំប្រចាំខែ

- ពិនិត្យឯកសារ ធ្វើបទបង្ហាញ និងផ្តល់យោបល់ លើឯកសារទាំងនោះ
- ផ្តល់ការណែនាំ និងផ្តល់ជំនួយដល់ទីប្រឹក្សា និងផ្តល់ការគាំទ្រដល់មន្ត្រីលេខាធិការដ្ឋានក្នុងការបំពេញការងារ
- ចូលរួមក្នុងវគ្គបណ្តុះបណ្តាល និងសិក្ខាសាលា

## ៤. សមាជិកភាព

ក្រុមការងារបច្ចេកទេសត្រួតពិនិត្យ រាយការណ៍ ផ្ទៀងផ្ទាត់ កំរិតយោងនៃការបញ្ចេញឧស្ម័ន មានសមាជិកមកពី៖៖

- ការិយាល័យពាក់ព័ន្ធ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងបរិស្ថាននិងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ចំនួន១នាក់(អគ្គនាយកដ្ឋាន ថាមពល)
- សមាជិកក្រុមប្រឹក្សាយោបល់ រេដ+ កម្ពុជា ចំនួន៥នាក់ ដែលមានជំនាញ និងបទពិសោធន៍ពាក់ព័ន្ធ ចាត់តាំងដោយ ក្រុមប្រឹក្សាយោបល់ និងអនុម័តដោយប្រធានលេខាធិការដ្ឋាន
- លេខាធិការដ្ឋានក្រុមការងារ រេដ+ កម្ពុជា ចំនួន២នាក់ នឹងត្រូវចាត់តាំងដោយ ប្រធានលេខាធិការដ្ឋាន
- ប្រសិនបើមានការចាំបាច់ ប្រធានក្រុមការងារបច្ចេកទេសនេះ អាចស្នើសុំសមាជិកបន្ថែមមកចូលរួម។

សមាជិកទាំងអស់ត្រូវចាត់តាំងតំណាងមកចូលរួមជំនួសក្នុងកិច្ចប្រជុំនានា ប្រសិនបើមានធុរៈចាំបាច់។ តំណាងបន្ថែមរួមមាន អ្នកពាក់ព័ន្ធមកពីអង្គការមិនមែនរដ្ឋាភិបាល អាចអញ្ជើញចូលរួមក្នុងកិច្ចប្រជុំតាមការចាំបាច់។

## ៥. ប្រតិបត្តិការ

ដោយសារមានការងារច្រើន ក្រុមបច្ចេកទេសនេះត្រូវរៀបចំផែនការការងារ ដែលមានគោលដៅច្បាស់លាស់ ដោយមានការប្រឹក្សាយោបល់ជាមួយលេខាធិការដ្ឋាន និងព្រមព្រៀងលើការទទួលខុសត្រូវរបស់សមាជិកម្នាក់ៗ ក្នុងការគាំទ្រលើផ្នែកបច្ចេកទេស ជាក់លាក់ និងផ្តល់ប្រឹក្សាលើការងារ ដើម្បីចាត់អាទិភាពឲ្យមានប្រសិទ្ធិភាពការងារ។ ក្រុមបច្ចេកទេសនេះត្រូវជួបប្រជុំប្រចាំខែ។លេខាធិការក្រុមបច្ចេកទេស ត្រូវជានាថាលិខិតអញ្ជើញចូលរួមកិច្ចប្រជុំដោយមានភ្ជាប់ឯកសារដែលត្រូវពិភាក្សាបានផ្ញើជូនដល់គ្រប់សមាជិកមុនកិច្ចប្រជុំ។ លេខាធិការត្រូវផ្ញើសេចក្តីព្រាងកំណត់ហេតុកិច្ចប្រជុំ ជូនគ្រប់សមាជិកក្នុងរយៈពេល៣ថ្ងៃបន្ទាប់ពីកិច្ចប្រជុំ។ សមាជិកទាំងអស់ត្រូវផ្តល់យោបល់លើសេចក្តីព្រាងកំណត់ហេតុ កិច្ចប្រជុំក្នុងរយៈពេល៣ថ្ងៃបន្ទាប់មកលេខាធិការ កែសម្រួលកំណត់ ហេតុកិច្ចប្រជុំតាមការផ្តល់យោបល់ និងផ្ញើកំណត់ហេតុសម្រេចជូនគ្រប់សមាជិកក្រុមបច្ចេកទេស។ ក្រុមការងារបច្ចេកទេស នឹងមានការជួយគាំទ្របច្ចេកទេស ពីអ្នកឯកទេសអន្តរជាតិ និងទីប្រឹក្សាបច្ចេកទេសអន្តរជាតិផងដែរ។

## ៦. ការធ្វើសេចក្តីសម្រេច

ក្រុមបច្ចេកទេសនេះមិនមែនជាអ្នកធ្វើសេចក្តីសម្រេចទេ ប៉ុន្តែជាអ្នកផ្តល់អនុសាសន៍ដល់ក្រុមការងារ រេដ+ កម្ពុជា និងលេខា ធិការដ្ឋានក្រុមការងារ រេដ+ កម្ពុជា ជារៀងរាល់ខែ។ អនុសាសន៍នានានឹងត្រូវធ្វើឡើង តាមគោលការណ៍នៃការឯកភាពមតិ។

## ៧. ការធ្វើរបាយការណ៍

សមាជិកក្រុមបច្ចេកទេសនេះ ត្រូវទទួលខុសត្រូវធ្វើរបាយការណ៍ និងប្រឹក្សាយោបល់ជាមួយស្ថាប័នសាមី និងក្រុមគោលដៅរបស់ខ្លួន។ លេខាធិការដ្ឋានក្រុមការងារ រេដ+ កម្ពុជាទទួលខុសត្រូវធ្វើរបាយការណ៍ក្រុមការងារ រេដ+ កម្ពុជា ដែលជាថ្នាក់គ្រប់គ្រង របស់ខ្លួន។

## ៨. រយៈពេល និងថេរវេលា

សមាជិកត្រូវធ្វើការប្រមាណ ១ថ្ងៃ ទៅ ៣ថ្ងៃ ក្នុងមួយខែ អាស្រ័យលើសកម្មភាពដែលត្រូវអនុវត្ត។

## ៩. ថវិកាគាំទ្រ

ការគាំទ្រថវិកា នឹងផ្តល់ដោយ កម្មវិធី UN-REDD និង គម្រោង FCPF (R-PP) ដោយយោងទៅតាមថវិកាដែលបានអនុម័ត សម្រាប់ការចំណាយ នៅក្នុងអំឡុងពេលនៃការអនុវត្តកិច្ចការនានាដែលទាក់ទងនឹងតួនាទីទាំងនេះ។ ការគាំទ្រមកពីក្របខ័ណ្ឌការងារផ្សេងទៀតនឹងត្រូវពិចារណាផងដែរ៕

## គណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ

រាជរដ្ឋាភិបាលកម្ពុជាបានបង្កើតគណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ (NCCC) ក្នុងឆ្នាំ២០០៦។ សមាសភាពរបស់ NCCC គឺជាមន្ត្រីជាន់ខ្ពស់ដែលជាអ្នកធ្វើសេចក្តីសម្រេចចិត្តមកពីក្រសួងចំនួន ២០ ហើយដើរតួនាទីជាអ្នកធ្វើសេចក្តីសម្រេចចិត្តដោយធ្វើការសម្របសម្រួលក្នុងការរៀបចំនិងអនុវត្តគោលនយោបាយ ផែនការនានា និងវិធានការនានាដើម្បីដោះស្រាយបញ្ហានៃការប្រែប្រួលអាកាសធាតុក្នុងប្រទេសកម្ពុជា ។ នាយករដ្ឋមន្ត្រីមានតួនាទីប្រធានកិត្តិយសនៃណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុនេះដោយមានអនុក្រឹត្យ លេខ ១៧៤ ចុះថ្ងៃទី ១៤ ខែតុលា ឆ្នាំ ២០០៩ ។

## រចនាសម្ព័ន្ធនៃការគ្រប់គ្រងព្រៃឈើនៅកម្ពុជា

ប្រភព ៖ Cambodia Readiness Preparation Proposal, 2011

**រដ្ឋបាលព្រៃឈើ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ៖**

*ព្រៃបម្រុងទុកអចិន្ត្រៃយ៍ (កម្មសិទ្ធិសាធារណៈរបស់រដ្ឋ) ៖*

- ព្រៃផលិតកម្ម ដែលរួមទាំង
    - សហគមន៍ព្រៃឈើ
    - ព្រៃសម្បទាន
- ព្រៃការពារ
- ព្រៃសម្រាប់ប្រើប្រាស់ក្នុងគោលបំណងផ្សេងទៀត (ដែលអាចបម្លែងទៅជា*កម្មសិទ្ធិឯកជនរបស់រដ្ឋ* សម្រាប់ការប្រើ ប្រាស់តាមទម្រង់ផ្សេងទៀត ដូចជា ដីសម្បទានសេដ្ឋកិច្ច ឬ ដីសម្បទានសង្គមកិច្ច)

*ព្រៃឯកជន (កម្មសិទ្ធិឯកជន) ដែលរួមទាំង ៖*

- ព្រៃដែលជាកម្មសិទ្ធិរបស់ឯកជន

  *(ព្រៃបម្រុងទុកអចិន្ត្រៃយ៍ និងព្រៃឯកជន រួមជាមួយគ្នា គឺជាផ្នែកមួយនៃសម្បត្តិព្រៃឈើអចិន្ត្រៃយ៍)*

**ក្រសួងបរិស្ថាន ៖**

*តំបន់ការពារធម្មជាតិ (កម្មសិទ្ធិសាធារណៈរបស់រដ្ឋ) ដែលរួមទាំង ៖*

- សហគមន៍តំបន់ការពារធម្មជាតិ
- ព្រៃលិចទឹក និងព្រៃកោងកាង ដែលស្ថិត*នៅក្នុង*តំបន់ការពារធម្មជាតិ។

**រដ្ឋបាលជលផល នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ៖**

*ព្រៃលិចទឹក និងព្រៃកោងកាង នៅក្នុងដែននេសាទ (កម្មសិទ្ធិសាធារណៈរបស់រដ្ឋ)* និងក្រៅ *តំបន់ការពារធម្មជាតិ[6], ដែលរួមទាំង ៖*

- សហគមន៍នេសាទ
- ឡូត៍នេសាទ
- តំបន់ការពារ និងអភិរក្សធនធានជលផល

**អាជ្ញាធរអប្សរា និងអាជ្ញាធរប្រាសាទដទៃទៀត ៖**

*តំបន់ព្រៃនៅជុំវិញព្រះវិហារ (កម្មសិទ្ធិសាធារណៈរបស់រដ្ឋ)*

**ជនជាតិដើមភាគតិច ៖**

[6] តំបន់ការពារធម្មជាតិ រួមមាន តំបន់ស្នូលនៃឋបនីយជីវមណ្ឌលបឹងទន្លេសាប ប៉ុន្តែមិនរាប់បញ្ចូលតំបន់ប្រើប្រាស់ដោយនិរន្តរភាព ឬ អន្តរតំបន់ឡើយ (ច្បាប់ស្តីពីតំបន់ការពារធម្មជាតិ ឆ្នាំ២០០៨)។

*ធនធានព្រៃឈើនៅក្នុងដីរបស់ជនជាតិដើមភាគតិច ដែលបានចុះបញ្ជីជាកម្មសិទ្ធិសមូហភាព (កម្មសិទ្ធិសាធារណៈរបស់រដ្ឋ)*

ផែនការ និងគោលនយោបាយពាក់ព័ន្ធតាមវិស័យគឺ៖

- កម្មវិធីព្រៃឈើជាតិ (២០១០) សម្រាប់សម្បត្តិព្រៃឈើអចិន្ត្រៃយ៍
- ផែនការយុទ្ធសាស្ត្រជាតិគ្រប់គ្រងតំបន់ការពារធម្មជាតិ សម្រាប់តំបន់ការពារធម្មជាតិ (ត្រូវរៀបចំ) ដោយផ្អែកលើច្បាប់ ស្តីពីតំបន់ការពារធម្មជាតិ ឆ្នាំ ២០០៨
- ក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រសម្រាប់វិស័យជលផល (២០១០-២០១៩) សម្រាប់ដែននេសាទ និងផែនការសកម្មភាពអភិវឌ្ឍន៍វិស័យជលផលរយៈពេលបីឆ្នាំ

ផែនការទាំងនេះត្រូវបានរាជរដ្ឋាភិបាលរៀបចំឡើង ដោយផ្អែកលើកំណែទម្រង់រយៈពេលវែងនៃគោលនយោបាយ និងច្បាប់ និងការពិគ្រោះយោបល់ទូលំទូលាយ។

## កម្មសិទ្ធិសាធារណៈ, កម្មសិទ្ធិឯកជនរបស់រដ្ឋ និងកម្មសិទ្ធិឯកជន

**កម្មសិទ្ធិរដ្ឋ**

**ដីឯកជន** - ដីព្រៃឯកជន

**កម្មសិទ្ធិសាធារណៈរបស់រដ្ឋ** (រដ្ឋាភិបាលមិនអាចលក់ តែអាចជួល)

- ព្រៃធម្មជាតិ និងផ្លូវទឹក
- តំបន់ការពារធម្មជាតិ
- ព្រៃបម្រុងទុកអចិន្ត្រៃយ៍
- អគាររដ្ឋបាល
- ផ្លូវសាធារណៈ ផ្លូវថ្នើរជើង និងព្រលានយន្តហោះ
- ទីតាំងបេតិកភណ្ឌវប្បធម៌

**កម្មសិទ្ធិឯកជនរបស់រដ្ឋ** (រដ្ឋាភិបាលអាចលក់)

- ដីនៅសល់ ឬ ដីទុកចោលទំនេរ
- ដីសម្បទានសង្គមកិច្ច
- ដីសម្បទានសេដ្ឋកិច្ច ដែលរួមទាំង ចំការកសិ-ឧស្សាហកម្ម (ដូងប្រេង កៅស៊ូ។ល។)

**ដីកម្មសិទ្ធិសមូហភាព៖ ដីវត្ត ដីសហគមន៍ជនជាតិដើមភាគតិច**

## ធនធានព្រៃឈើនៃព្រះរាជាណាចក្រកម្ពុជា

ការគ្រប់គ្រងធនធានព្រៃឈើ ស្ថិតនៅក្រោមដែនសមត្ថកិច្ចជាទូទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ លើកលែងតំបន់ការពារធម្មជាតិ ដែលស្ថិតក្រោមសមត្ថកិច្ចរបស់ក្រសួងបរិស្ថាន

**ធនធានព្រៃឈើនៅក្នុងតំបន់ការពារធម្មជាតិ**

កម្មសិទ្ធិសាធារណៈរបស់រដ្ឋ *នៅក្រោមដែនសមត្ថកិច្ចរបស់ MoE*

- បែងចែកជាតំបន់ស្នូល តំបន់អភិរក្ស តំបន់ប្រើប្រាស់ដោយនិរន្តរភាព និងតំបន់សហគមន៍ ដែលរួមទាំង សហគមន៍តំបន់ការពារធម្មជាតិ (នៅក្នុងតំបន់ប្រើប្រាស់ដោយនិរន្តរភាព)

**ដីព្រៃឈើក្នុងទីតាំងបេតិកភណ្ឌវប្បធម៌**

កម្មសិទ្ធិសាធារណៈរបស់រដ្ឋ

*នៅក្រោមសមត្ថកិច្ចរបស់អាជ្ញាធរអប្សរា អាជ្ញាធរប្រាសាទព្រះវិហារ ។ល។*

**ព្រៃលិចទឹក និងព្រៃកោងកាង (ក្រៅតំបន់ការពារធម្មជាតិ)**

*នៅក្រោមសមត្ថកិច្ចរបស់រដ្ឋបាលជលផល នៃ MAFF*

**ធនធានចំការឈើនៅលើដីកសិកម្ម**

- កសិ-ឧស្សាហកម្ម៖ ដូងប្រេង កៅស៊ូ ។ល។

**សម្បត្តិព្រៃឈើអចិន្ត្រៃយ៍ - ព្រៃបម្រុងទុកអចិន្ត្រៃយ៍ និងដីព្រៃឯកជន** *នៅក្រោមសមត្ថកិច្ចរបស់ MAFF/FA* ធនធានព្រៃឈើដែលលូតលាស់ដោយខ្លួនឯង និងព្រៃដាំ

**ព្រៃបម្រុងទុកអចិន្ត្រៃយ៍**

កម្មសិទ្ធិសាធារណៈរបស់រដ្ឋ

*គ្រប់គ្រងដោយរដ្ឋបាលព្រៃឈើ*

**ព្រៃផលិតកម្ម**

តំបន់ព្រៃផលិតកម្មដែលស្ថិតក្រោមការគ្រប់គ្រងដោយនិរន្តរភាព តំបន់សហគមន៍ព្រៃឈើ

**ព្រៃការពារ**

**ព្រៃសម្រាប់ប្រើប្រាស់ក្នុងគោលបំណងផ្សេងៗ** ដីព្រៃរបស់រដ្ឋ ដែលនៅទំនេរ/រេចរឹល ។ ជំពូកដីបណ្តោះអាសន្ន ។ *ទំនងបំផុតថានឹងប្រើប្រាស់ជាដីសម្បទានសង្គមកិច្ច/សេដ្ឋកិច្ច ក្រោយចាត់ថ្នាក់ឡើងវិញជាកម្មសិទ្ធិឯកជនរបស់រដ្ឋ*

**ព្រៃឯកជន** កម្មសិទ្ធិឯកជន

*គ្រប់គ្រងដោយរដ្ឋបាលព្រៃឈើ*

រួមមាន៖

ចំការឈើ ព្រៃឈើស្តារឡើងវិញ

**ធនធានព្រៃឈើនៅលើដីជនជាតិដើម**

កម្មសិទ្ធិសមូហភាព នៅក្រោមឈ្មោះសហគមន៍, រដ្ឋបាលព្រៃឈើគ្រប់គ្រងលើការប្រើប្រាស់

*កំហិតលើការផ្ទេរសិទ្ធិ*

រូបទី ៣៖ ការទទួលខុសត្រូវនៅថ្នាក់ជាតិសម្រាប់ការត្រៀមលក្ខណៈដើម្បីរ៉េដបូកនៅកម្ពុជា

**RGC/គណៈរដ្ឋមន្ត្រី**

- គ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋទាំងអស់
- អនុម័តផែនការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ
- ផ្ទេរ ចាត់ថ្នាក់ឡើងវិញ និងតែងតាំងអាជ្ញាធរគ្រប់គ្រងសម្បត្តិរដ្ឋ

**ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

- រក្សាសារពើភណ្ឌសម្បត្តិរដ្ឋ
- ភ្នាក់ងារប្រតិបត្តិនៃរាជរដ្ឋាភិបាលកម្ពុជាក្នុងការគ្រប់គ្រងសម្បត្តិរដ្ឋ ដែលរួមទាំង ការផ្ទេរ លក់ ជួល សម្បទាន ។ល។
- គ្រប់គ្រងផលចំណូលរដ្ឋ
- សហប្រធានមូលនិធិរបស់រដ្ឋ

*ច្បាប់ស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឆ្នាំ ២០០៨,អនុក្រឹត្យលេខ១២៩ ឆ្នាំ ២០០៦, អនុក្រឹត្យលេខ ៤ ឆ្នាំ ២០០០*

**ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

- គ្រប់គ្រងកិច្ចការរដ្ឋបាលសុរិយាដីលើដីរបស់រដ្ឋ
- ផ្តល់កម្មសិទ្ធិ/ប័ណ្ណកម្មសិទ្ធិសម្រាប់អចលនទ្រព្យ
- គ្រប់គ្រងផែនទីរបស់កម្ពុជា

*ច្បាប់ភូមិបាល ឆ្នាំ ២០០១, អនុក្រឹត្យលេខ ៦២ ឆ្នាំ ១៩៩៩*

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

- ដែនសមត្ថកិច្ចទូទៅលើព្រៃឈើ និងធនធានព្រៃឈើ (ការគ្រប់គ្រងតំបន់ការពារធម្មជាតិស្ថិតនៅក្រោមក្រសួងបរិស្ថាន)
- ចុះបញ្ជីសម្បត្តិព្រៃឈើអចិន្ត្រៃយ៍

**<u>រដ្ឋបាលព្រៃឈើ</u>**

- ទទួលខុសត្រូវលើសម្បត្តិព្រៃឈើអចិន្ត្រៃយ៍
- បង្កើតនិងអនុវត្តកម្មវិធីព្រៃឈើជាតិ(រួមទាំងសហគមន៍ព្រៃឈើ)
- សិក្សានិងប្រមូលទិន្នន័យអំពីព្រៃឈើរដ្ឋទាំងអស់
- ធ្វើការវាយតម្លៃស្តុកកាបូនព្រៃឈើជាតិ
- បង្កើតពាណិជ្ជកម្មកាបូនព្រៃឈើ
- ស្តារព្រៃឈើឡើងវិញ

**<u>រដ្ឋបាលជលផល</u>**

- ទទួលខុសត្រូវលើតំបន់ព្រៃលិចទឹក និងព្រៃកោងកាង
- បង្កើតនិងអនុវត្តផែនការជលផលជាតិ(រួមទាំង សហគមន៍នេសាទ)

*ច្បាប់ស្តីពីព្រៃឈើ ឆ្នាំ ២០០២, អនុក្រឹត្យលេខ ១៨៨ ឆ្នាំ ២០០៨, ច្បាប់ស្តីពីជលផល ឆ្នាំ ២០០៦*

**ក្រសួងមហាផ្ទៃ (រួមទាំង NCDD)**

- រដ្ឋបាលថ្នាក់ក្រោមជាតិ (ខេត្ត/ស្រុក/ឃុំ)
- ផែនការ និងមូលនិធិអភិវឌ្ឍន៍ឃុំ, កំណត់មុខងារដែលត្រូវផ្ទេរទៅថ្នាក់ក្រោមជាតិ (NCDD)

*ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ស្រុក ខណ្ឌ ក្រុង ឃុំ សង្កាត់*

**ក្រសួងបរិស្ថាន**

- ការគ្រប់គ្រងតំបន់ការពារធម្មជាតិ
- ពិនិត្យការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន
- ស្ថាប័នជាតិបណ្តោះអាសន្នទទួលបន្ទុកយន្តការអភិវឌ្ឍន៍ស្អាត

**<u>អគ្គនាយកដ្ឋាន (GDANCP):</u>**

- កសាងនិងអនុវត្តផែនការយុទ្ធសាស្ត្រជាតិគ្រប់គ្រងតំបន់ការពារធម្មជាតិ
- ទទួលខុសត្រូវលើអនុសញ្ញាបរិស្ថានអន្តរជាតិ

**<u>នាយកដ្ឋានប្រែប្រួលអាកាសធាតុនៃ GDANCP:</u>**

- សហការជាមួយស្ថាប័នពាក់ព័ន្ធដើម្បីកសាងយុទ្ធសាស្ត្រជាតិប្រែប្រួលអាកាសធាតុ, និងគោលនយោបាយឥណទានកាបូន, គ្រប់គ្រងមូលនិធិប្រែប្រួលអាកាសធាតុ, លេខាធិការដ្ឋាននៃNCCC
- ស្ថាប័នបង្គោលនៃ UNFCCC: ការចរចា, ការអនុវត្តសេចក្តីសម្រេចនានារបស់ UNFCCC និងរៀបចំរបាយការណ៍ជាតិសារពើភណ្ឌឧស្ម័នផ្ទះកញ្ចក់
- សម្របសម្រួលការអនុវត្តគម្រោង CDM គម្រោងឥណទានកាបូន

*ច្បាប់ស្តីពីតំបន់ការពារធម្មជាតិ ឆ្នាំ២០០៨, រាជក្រឹត្យឆ្នាំ ២១៩៩៣, អនុក្រឹត្យលេខ ៣៧ ឆ្នាំ ២០០៨, អនុក្រឹត្យលេខ ១៧៥ ឆ្នាំ២០០៩*

**ក្រសួងអភិវឌ្ឍន៍ជនបទ**

- ទទួលស្គាល់សហគមន៍ជនជាតិដើមសម្រាប់ការចុះបញ្ជីនៅក្រសួងមហាផ្ទៃ

*អនុក្រឹត្យឆ្នាំ ២០០១*

## ការត្រៀមលក្ខណៈសម្រាប់រេដបូកនៅកម្ពុជា

ប្រទេសកម្ពុជាបានរៀបចំផែនទីបង្ហាញផ្លូវសម្រាប់ការត្រៀមលក្ខណៈសម្រាប់ការអនុវត្ត REDD+ នៅឆ្នាំ២០០៩ ដល់ឆ្នាំ ២០១០ ហើយបានអនុវត្តគម្រោងសាកល្បង REDD+ លើកទី១នៅកម្ពុជា តាំងពីឆ្នាំ ២០០៨ និងបានដាក់សំណើរទៅមូលនិធិភាពជាដៃគូកាបោនព្រៃឈើ (FCPF) នៅឆ្នាំ២០០៩ ហើយក៏បានក្លាយជាប្រទេសដៃគូរបស់កម្មវិធី UN-REDD ២០០៩ ព្រមទាំងបានចុះហត្ថលេខា កម្មវិធី UN-REDD ថ្នាក់ជាតិនៅឆ្នាំ ២០១១ ។ បច្ចុប្បន្ន កម្ពុជាមានគម្រោងសាកល្បងស្តីពី REDD+ ចំនួន ៣ គម្រោង គឺ នៅ (ឧត្តរមានជ័យ សៀម៉ា និងនៅគូលែនព្រហ្មទេព)។

កម្ពុជាកំពុងស្ថិតក្នុងដំណាក់កាលទី២នៃ ដំណើរការត្រៀមលក្ខណៈសម្រាប់ការអនុវត្តផែនទីបង្ហាញផ្លូវ REDD+ នៅកម្ពុជា ។



# តម្រូវការជាមូលដ្ឋាន និងលក្ខខណ្ឌបច្ចេកទេសសម្រាប់រេដបូក

## សេចក្តីផ្តើម៖

ដើម្បីទទួលបានការផ្តល់ថវិកាពីឥណទានកាបោនក្នុងក្របខ័ណ្ឌរេដបូក ប្រទេសនីមួយៗត្រូវបំពេញឲ្យបាននូវលក្ខខ័ណ្ឌមួយចំនួន។ លក្ខខ័ណ្ឌទាំងនោះត្រូវជានាដល់ផលប្រយោជន៍ទាំងសម្រាប់ប្រទេសដែលជាអ្នកទិញ និងប្រទេសដែលជាអ្នកលក់។ មានលក្ខខ័ណ្ឌមួយចំនួនត្រូវបំពេញនៅក្នុងដំណាក់កាលត្រៀមលក្ខណៈសម្រាប់រេដបូក ឯមួយចំនួនទៀតនឹងត្រូវបំពេញនៅក្នុងដំណាក់កាលអនុវត្តកម្មវិធីរេដបូក។ ភាគច្រើននៃតម្រូវការក្នុងលក្ខខ័ណ្ឌទាំងនោះទាក់ទងនឹងរចនាសមន្ព័ន្ធស្ថាប័នសម្រាប់កម្មវិធីរេដបូក ការធានាសុវត្ថិភាពសម្រាប់សិទ្ធសហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិច ព្រមទាំងសមត្ថភាពបច្ចេកទេសនានាលើការអនុវត្តន៍ការងាររេដបូក។ ប្រទេសនានាដែលមានបំណងអនុវត្តន៍កម្មវិធីរេដបូក ត្រូវរៀបចំស្ថាប័នគ្រប់គ្រងការងារនេះ ដោយផ្អែកលើស្ថានភាពភូមិសាស្រ្ត នយោបាយ និងសង្គមនៃប្រទេសនោះ។ រីឯប្រទេសអ្នកទិញជាទូទៅ មិនត្រូវជ្រៀតជ្រែកលើកិច្ចការទាំងនេះក្នុងប្រទេសអ្នកលក់នោះទេ។ ប៉ុន្តែរាល់កិច្ចការរៀបចំស្ថាប័នរេដបូកក្នុងប្រទេសអ្នកលក់ ដាច់ខាតត្រូវតែឆ្លើយតបនឹងសន្ធិសញ្ញា និងកិច្ចព្រមព្រៀងអន្តរជាតិនានា និងក្របខ័ណ្ឌច្បាប់របស់ប្រទេសសាមីនោះ។

ប្រទេសដែលអនុវត្តន៍រេដបូកត្រូវតែបំពេញលក្ខខ័ណ្ឌដូចខាងក្រោម៖

### ១. ក្របខ័ណ្ឌច្បាប់ និងស្ថាប័នគ្រប់គ្រង

- រៀបចំយុទ្ធសាស្រ្ត គោលនយោបាយ ច្បាប់ និងផែនការ សម្រាប់ដោះស្រាយបញ្ហានៃការបាត់បង់ និងរេចរឹលព្រៃឈើ
- រៀបចមស្ថាប័នសម្រាប់គ្រប់គ្រងថវិកា ទិន្នន័យ ការចុះបញ្ជីកាបោន ការតាមដាន និងវាយតំលៃ
- រៀបចំនីតិវិធី និងយន្តការផ្លូវច្បាប់សម្រាប់ការបែងចែកផលប្រយោជន៍

### យុទ្ធសាស្រ្តជាតិស្តីពីរេដបូក

យុទ្ធសាស្រ្តជាតិស្តីពីរេដបូកដែលមានប្រសិទ្ធិភាព ត្រូវតែរួមមានដំណោះស្រាយចំពោះហេតុផលនៃការបាត់ និងរេចរឹលព្រៃឈើ។ ដោយសារមូលហេតុនៃការបាត់បង់ និងរេចរឹលព្រៃឈើខុសគ្នាពីប្រទេសមួយទៅប្រទេសមួយ ប្រទេសនីមួយៗត្រូវតែរៀបចំយុទ្ធសាស្រ្តដែលសមស្របសម្រាប់បរិបទប្រទេសរបស់គេ។ កិច្ចព្រមព្រៀងទីក្រុងកាន់គូនបានស្នើដល់ប្រទេសទាំងអស់អោយគិតពីកត្តាមួយចំនួនពេលរៀបចំយុទ្ធសាស្រ្ត ឬផែនការសកម្មភាពជាតិ។ កត្តាទាំងនោះមាន មូលហេតុនៃការបាត់បង់ និងរេចរឹលព្រៃឈើ បញ្ហាកម្មសិទ្ធិ បញ្ហាអភិបាលកិច្ចព្រៃឈើ ការគិតគូរពីកត្តាយេនឌ័រ និងការធានាសុត្ថភាព ដែលនឹងធានា

ដល់ការចូលរួមពេញលេញ និងប្រកបដោយប្រសិទ្ធិភាពរបស់អ្នកពាក់ព័ន្ធ ជនជាតិដើមភាគតិច និងសហគមន៍មូលដ្ឋាន។

**២. ទិដ្ឋភាពបច្ចេកទេស**

- រៀបចំកម្រិតគោលនៃការបំភាយឧស្ម័នពីព្រៃឈើ និងកំណត់កម្រិតគោល
- រៀបចំប្រព័ន្ធត្រួតពិនិត្យធនធានព្រៃឈើថ្នាក់ជាតិដែលមានប្រសិទ្ធិភាព
- បង្កើនសមត្ថភាពក្នុងការវាស់វែង រាយការណ៍ និងផ្ទៀងផ្ទាត់លើ ប្រភពនៃការបញ្ចេញឧស្ម័នផ្ទះកញ្ចក់តាមរយៈព្រៃឈើ និងការស្រូបយកកាបោន កម្រិតស្តុកកាបោន និងការផ្លាស់ប្តូរទំហំព្រៃ។
- រៀបចំប្រព័ន្ធមួយដែលជួយឲ្យសម្រេចបាន និងការគោរពលក្ខខ័ណ្ឌនៃការធានាសុត្ថិភាពរេដបូកទាំង៧ និងប្រព័ន្ធដែលអាចផ្តល់ព័ត៌មានពីការប្រតិបត្តិនូវលក្ខខ័ណ្ឌនៃការធានាសុត្ថិភាពរេដបូកក្នុងដំណើរការអនុវត្តសម្មភាពនានា
- រៀបចំមូលនិធិរេដបូកជាតិ ដែលអាចប្រើសម្រាប់ទទួលការទូទាត់សំណងពីរេដបូកតាមរយៈលទ្ធផល (Result based payment)
- រៀបចំយន្តការបែងចែកផលប្រយោជន៍
- ប្រសិនបើអាចរៀបចំការចុះបញ្ជីគណនីរេដបូក សម្រាប់កត់ត្រានូវកម្រិតសាយភាយឧស្ម័ន និងការទូទាត់សំណង។

## តម្រូវការបច្ចេកទេស

ការដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់តាមតម្រូវការបច្ចេកទេសជាកត្តាចាំបាច់ដើម្បីចូលរួមក្នុងដំណើរការអនុវត្តន៍រេដបូក។ ការបកស្រាយសង្ខេបពីតម្រូវការបច្ចេកទេសទាំងនេះមាននៅផ្នែកខាងក្រោម។ ការយល់ដឹងស៊ីជម្រៅពីតម្រូវការបច្ចេកទេសទាំងនេះអាចទទួលបានតាមរយៈវគ្គបណ្តុះបណ្តាល និងមេរៀនលំអិតសម្រាប់តែប្រធានបទទាំងនេះតែប៉ុណ្ណោះ។

**១. កម្រិតគោលនៃការបញ្ចេញឧស្ម័នកាបូនិច**

ដើម្បីកំណត់កម្រិតនៃការកាត់បន្ថយការសាយភាយកាបោន និងការបង្កើនកម្រិតស្តុកកាបោនទាមទារនូវការវាស់វែងពីកម្រិតស្តុក និងការបញ្ចេញកាបោននាពេលបច្ចុប្បន្ន។ នេះហៅថាកម្រិតគោលនៃការបញ្ចេញឧស្ម័នកាបូនិច។ ទំហំ និងល្បឿននៃការបាត់បង់ និងរេចរឹលព្រៃឈើក៏ត្រូវបានចាត់ទុកជាកម្រិតគោលផងដែរ។ ប្រទេសនីមួយៗត្រូវការកម្រិតគោលដើម្បីគណនាការកាត់បន្ថយការបញ្ចេញឧស្ម័នពីកាបោននៅពេលអនាគត។ កម្រិតគោលដែលប្រទេសនីមួយៗស្នើឡើង ត្រូវបញ្ជូនទៅ UNFCCC ដើម្បី ត្រួតពិនិត្យបច្ចេកទេស។ ប្រទេសនីមួយៗក៏អាចប្រើប្រាស់វិធានស្នើជាជំហានៗផងដែរ (ឧ. មិនចាំបាច់ដាក់បញ្ចូលនូវសកម្មភាព ឬប្រភពកាបោនទាំងអស់នៅដំណាក់កាលដំបូង។) ជាទូទៅមានវិធានពីរក្នុងការកំណត់កម្រិតគោល។

**កម្រិតគោលប្រវត្តិ៖** អត្រានៃការសាយភាយកាបោនពីការបាត់បង់ និងរេចរឹលព្រៃឈើ មុនពេលអនុវត្តរេដបូក ១០ឆ្នាំកន្លងមក ឬយូរជាងនេះ ហៅថាកម្រិតគោលប្រវត្តិ។

**កម្រិតគោលប្រវត្តិស្របតាមស្ថានភាពជាក់ស្តែងនៃប្រទេសមួយ៖** ប្រទេសនីមួយៗអាចស្នើការកែសម្រួលកម្រិតគោល ប្រសិនបើស្ថានភាពប្រទេសនោះស្របនឹងលក្ខខ័ណ្ឌ។ លក្ខខ័ណ្ឌនេះអាចអនុវត្តជាពិសេសសម្រាប់ ប្រទេសដែលមានល្បឿននៃការបាត់បង់ និងរេចរឹលព្រៃឈើពីអតីតកាល និងអនាគតទាប។ ក្នុងករណីនេះ កម្រិតគោល សម្រាប់យោង ផ្អែកតាមកត្តាប្រវត្តិមិនអាចប្រើប្រាស់បានទេ។ ប្រទេសដែលមានលទ្ធភាពកាត់បន្ថយការបញ្ចេញឧស្ម័នទាបជាងកម្រិតគោលរបស់ខ្លួន អាចនឹងទទួលបានការទូទាត់ ប្រសិនបើបំពេញបាននូវលក្ខខ័ណ្ឌចាំបាច់នានា។

## ២. ការវាស់វែង ការតាមដាន ការរាយការណ៍ និងការផ្ទៀងផ្ទាត់

ការតាមដានក្នុងកំឡុងពេលនីមួយៗមានសារសំខាន់ណាស់ដើម្បី ប្រមូលព័ត៌មានពីការផ្លាស់ប្តូរកម្រិតស្តុកកាបោន និងទំហំព្រៃឈើ បន្ទាប់ពីអនុវត្តកម្មវិធីរេដបូក។ បច្ចេកទេស នីតិវិធី និងវិធានក្នុងការវាស់វែងនេះ ត្រូវតែធ្វើការពិនិត្យឡើងវិញជាទៀងទាត់។

របាយការណ៍ពីការតាមដាន ត្រូវរួមមាន ដំណើរការ បច្ចេកទេស និងនីតិវិធីក្នុងការប្រមូល និងវិភាគ ទិន្នន័យ។ ការផ្ទៀងផ្ទាត់នៃរេដបូក សំដៅលើការងារពិនិត្យសុក្រិតភាពនៃទិន្នន័យ។

**និយមន័យព្រៃឈើ**

ដើម្បីកំណត់ពីការបាត់ និងរេចរឹលព្រៃឈើ ទាមទារនូវការកំណត់និយមន័យព្រៃឈើនៅថ្នាក់ជាតិ ព្រមទាំងនិយមន័យព្រៃធម្មជាតិផងដែរ ដោយសារវាចាំបាច់ក្នុងការអនុវត្តន៍វិធានការធានាសុវត្ថិភាព។ ប្រទេសកម្ពុជាមាននិមយមព្រៃឈើរួចមកហើយដែលប្រើប្រាស់ក្នុងក្របខ័ណ្ឌ CDM ក្រោមUNFCCC តែការកំណត់ និយមន័យដោយឡែកមួយសម្រាប់រេដក៏ជាការប្រសើរ។ ប្រសិនបើនិយមន័យព្រៃឈើខុសពីនិយមន័យដែលប្រើប្រាស់លើឆាកអន្តរជាតិ ឧទាហរណ៍ ការប៉ាន់ប្រមាណធនធានព្រៃឈើពិភពលោករបស់ FAO ភាពខុសគ្នានេះគួរតែពន្យល់ឲ្យច្បាស់។

## ៣. ការបែងចែកផលប្រយោជន៍

ផលប្រយោជន៍ពីរេដបូក អាចទទួលបានក្នុងរូបភាពផ្សេងៗដូចជា ធនធនព្រៃឈើកាន់តែល្អ ភាពសំបូរនៃអនុផលព្រៃឈើ ការរក្សាប្រភពទឹកស្អាត ការពារធនធានកោងកាង និងរក្សាដែននេសាទ។ ទាំងនេះត្រូវបានចាត់ទុកផលប្រយោជន៍ចំរុះ។ ផលប្រយោជន៍ខ្លះមាននៅកម្រិតសហគមន៍ ឯខ្លះទៀតបានផ្តល់ជាសេវាកម្ម ដល់តំបន់ឆ្ងាយៗ ឧ. ផ្តល់ទឹកស្អាតដល់ទីប្រជុំជន។ ការទូទាត់សំណងពីរេដបូក ជាការលើកទឹកចិត្តដល់ប្រទេសដែលបានអនុវត្តន៍រេដបូក ហើយនៅពេលនិយាយពីការបែងចែកផលប្រយោជន៍ គេតែងនិយាយពីការបែងចែកចំណូលនៃការទូទាត់សងនេះ។ តាមពិតផលប្រយោជន៍ដទៃទៀតអាចមាន

តំលៃជាងការទូទាត់សងនេះ។ បញ្ហាប្រឈមមួយចំពោះផលប្រយោជន៍ចំរុះនេះគឺថាយើងមិនបានឲ្យតំលៃវានៅពេលវាមិនទាន់បាត់បង់ ហេតុនេះវាក៏បាត់បង់ហើយជួនកាលមិនអាចស្តារឡើងវិញក៏មាន។

ភាគច្រើនយើងនិយាយពីការបែងចែកចំណូលដោយគ្រាន់តែគិតគូរការចែកចំណូលជាសាច់ប្រាក់តែប៉ុណ្ណោះ។

ការបែងចែកផលប្រយោជន៍ជាប្រធានបទមួយដែលមានការជជែកច្រើន ហើយវាមានសារសំខាន់ណាស់ក្នុងការរៀបចំយន្តការបែងចែកផលប្រយោជន៍មួយតាមរយៈដំណើរសម្រេចចិត្តមួយដែលមានតម្លាភាព។ មានករណីជាច្រើនក្នុងពេលកន្លងមកដែលអ្នកពាក់ព័ន្ធមានគំនិតខុសៗគ្នាពីការបែងចែកផលប្រយោជន៍ ហើយដែលធ្វើឲ្យការអនុវត្តរេដបូកមិនទទួលបានលទ្ធផល។ UNFCCC មិនទាន់មានគោលការបែងចែកផលប្រយោជន៍នោះទេ។ ការទូទាត់ផ្តល់នៅថ្នាក់អន្តរជាតិមានបំណងផ្តល់ការលើកទឹកចិត្តដល់ការកាត់បន្ថយ ការបញ្ចេញឧស្ម័នពីការបាត់បង់ និងរេចរឹលព្រៃឈើ និងការកាត់បន្ថយកំហាប់កាបោនពីក្នុងបរិយាកាសតាមរយៈការដាំដុះព្រៃឈើ។ ហើយប្រសិនបើគ្មានលទ្ធផលជាវិជ្ជមានទេ និងគ្មានការទូទាត់សងនោះទេ ។ ការទូទាត់សងផ្អែកលើលទ្ធផលនេះជាហេតុផលមួយដែលធ្វើឲ្យរេដបូកទទួលការចាប់អារម្មណ៍ពីប្រទេសអភិវឌ្ឍន៍។

កន្លងមកយើងមានបទពិសោធន៍តិចតួចមែនទែនលើការបែងចែកផលប្រយោជន៍ពីរេដបូក។ ប្រទេស ប្រេស៊ីល និងអេក្វាឌ័រ មានបទពិសោធន៍ខ្លះក្នុងការផ្តល់ការលើកទឹកចិត្តដល់ប្រជាជនក្នុងការការពារព្រៃឈើ ហើយប្រទេសកូស្តារីកា មានបទពិសោធន៍លើការទូទាត់សេវាកម្មបរិស្ថានដែលទាក់ទងនឹងការអភិរក្ស។ នៅក្នុងប្រទេសអភិវឌ្ឍន៍មួយចំនួនក៏មានការផ្តល់ការលើកទឹកចិត្តដល់កសិករក្នុងការដាំដុះដំណាំដែលមិនមានឥទ្ធិពលដល់ការប្រែប្រួលអាកាសធាតុ។

ប្រភេទនៃការទូទាត់ទាំងអស់ខាងលើទាក់ទងនឹងសកម្មភាពដែលកសិករ ឬសហគមន៍ត្រូវធ្វើ។ វាមិនគ្រាន់តែជាការបែងចែកផលក្នុងចំណោមអ្នកដែលរស់នៅក្នុង និងក្បែរព្រៃឈើនោះទេ។ ប្រការនេះជាការទូទាត់សំណងដើម្បីកាត់បន្ថយការបញ្ចេញឧស្ម័ន និងរក្សានិរន្តភាពនៃកិច្ចការនេះ។ ភាគច្រើនការទូរទាត់មិនបានវាស់វែងច្បាស់ពីកម្រិតនៃការកាត់បន្ថយការសាយភាយនោះទេ ដោយការធ្វើបែបនេះវាទាមទារនូវការចំណាយច្រើន។

ដើម្បីឲ្យមានប្រសិទ្ធិភាព ការបែងចែកផលប្រយោជន៍ត្រូវគិតគូពីការរួមចំណែកកាត់បន្ថយការបញ្ចេញឧស្ម័នកាបូនិច។ នេះរួមបញ្ចូលនូវការគិតគូរពីហេតុផលដែលធ្វើឲ្យបាត់បង់ និងរេចរឹលព្រៃឈើ។ ក្នុងករណីខ្លះវាទាមទារឲ្យមានការវិនិយោគលើវិស័យផ្សេងពីព្រៃឈើផងដែរ ឧ. វិស័យកសិកម្ម។

ជាការសមស្រប ត្រូវធ្វើការដោយរួមបញ្ចូលទាំងការពិចារណាលើការចំណាយនិងផលប្រយោជន៍នៃការអនុវត្ត REDD + នៅកម្ពុជា ។ ប្រសិនបើការចំណាយខ្ពស់ជាងផលប្រយោជន៍ (ច្រើន) នោះការ

ទូទាត់អាចជួយដល់ការធ្វើឱ្យមានចាប់អារម្មណ៍ក្នុងការធ្វើសកម្មភាព ។ ប្រសិនបើតម្លៃនៃអត្ថប្រយោជន៍ដែលមានស្រាប់ខ្ពស់ជាងការចំណាយ នោះប្រហែលជាមិនចាំបាច់ត្រូវការការទូទាត់សងនោះទេ ។

ការបែងចែកផលដែលសមស្របមួយអាស្រ័យថាតើអ្នកណាជាអ្នកសម្រេច និងទទួលយកនូវការសម្រេច។ សំខាន់ណាស់ក្នុងការរៀបចំយន្តការបែងចែកផលប្រយោជន៍មួយដែលមានតម្លាភាព អាចទទួលយកបានគ្រប់ភាគីពាក់ព័ន្ធ និងអាចអនុវត្តបានផ្អែកលើកត្តានៃការចំណាយ និងសមត្ថភាព។ ប្រសិនបើ ចំណូលពីរេដបូក គ្រាន់តែសម្រាប់កាត់កងចំណាយប្រតិបត្តិការ នោះវានឹងគ្មានចំណូលសម្រាប់ទូរទាត់សងលើសកម្មភាពអនុវត្តន៍រេដបូកនោះទេ។ ជាទូទៅចំណូលពីរេដបូកនឹងត្រូវប្រើប្រាស់សម្រាប់ការចំណាយលើសកម្មភាពអនុវត្តន៍រេដបូក ការតាមដាន និងរាយការណ៍ពីកម្រិតសាយភាយឧស្ម័ន និងការធានាសុត្ថិភាព។

**៤. ការបែងចែកចំណូល និងកម្មសិទ្ធិ៖** ការធានាកម្មសិទ្ធិអាចរួមចំណែកបង្កើនភាពជាម្ចាស់លើដី តែមិនមែនមានន័យថាជួយជាលក្ខខ័ណ្ឌសម្រាប់ទទួលបានចំណូលពីរេដបូកនោះទេ។ ក្នុងករណីដែលអ្នកក្រធ្វើការទន្ទ្រានដីព្រៃ នោះក្នុងសកម្មភាពរេដបូកគួរតែតែផ្តោតលើការស្វែងរកជម្រើសនៃការចិញ្ចឹមជីវិតផ្សេងសម្រាប់ពួកគេ។ ដូចនេះពួកគេអាចទទួលបានផលប្រយោជន៍ពីរេដបូកដោយមិនចាំបាច់មានកម្មសិទ្ធិ។ ដោយសារមូលហេតុចំបងនៃការបាត់បង់ និងរេចរឹលព្រៃឈើភាគច្រើនបណ្តាលមកពីវិស័យផ្សេងក្រៅពីព្រៃឈើ ការគិតគូរពីកត្តាទាំងនេះក្នុងសកម្មភាពរេដក៏ជាការចាំបាច់ផងដែរ។

**៥. បែបបទនៃការបែងចែកចំណូល៖** ជួនកាល ការបែងចែកចំណូលត្រូវបានចាត់ទុកថាជាការបែងចែកប្រាក់ ពីបុគ្គលម្នាក់ទៅម្នាក់។ ក្នុងការអនុវត្តវាអាចកើតឡើងក្នុងរូបភាពផ្សេងៗផងដែរ។ ជំនួសឲ្យការបែងចែកចំណូលឲ្យដល់បុគ្គលម្នាក់ផ្ទាល់ ចំណូលពីរេដបូកអាចប្រើប្រាស់ដើម្បីគាំទ្រដល់សកម្មភាពរួមក្នុងសហគមន៍ តួរយ៉ាងដូចជា គម្រោងចិញ្ចឹមជីវិតជាដើម។ ក្នុងករណីនេះសហគមន៍ខ្លួនឯងមានតួនាទីសំខាន់ក្នុងការសម្រេចចិត្តថាតើពួកគេចង់ធ្វើការចំនាយថវិកាពីរេដបូកតាមរបៀបណា។ បែបបទផ្សេងទៀតនៃការចំណាយអាចតាមរយៈ ការផ្តល់ការងារ ឧ. ការដាំឈើ ការស្តារព្រៃដែលរេចរឹល និងការយាមល្បាតព្រៃជាដើម។

## ៦. ការទូទាត់ផ្អែកលើលទ្ធផល

គោលការណ៍គន្លឹះនៃរេដបូកដំណាក់កាលទីបី គឺការទូទាត់សំណងតាមរយៈលទ្ធផលសកម្មភាពបន្ទាប់ពីការតាមដាន រាយការណ៍ និងផ្ទៀងផ្ទាត់។ ជាទូទៅដើម្បីទទួលបានលទ្ធផលពីការវិនិយោគទាមទារនូវការដាក់ទុនដើម្បីអនុវត្តសកម្មភាពជាមុន។ ចំពោះសហគមន៍មួយ ឬបុគ្គលម្នាក់ៗ វាមានការ

ពិបាកណាស់ក្នុងការដែលឲ្យពួកគេចូលរួមក្នុងការអនុវត្តសកម្មភាពរេដបូក ហើយរង់ចាំជាច្រើនឆ្នាំទើបអាចទទួលបានចំណូលពីរេដបូកនោះ។ ការបង្កើតមូលនិធិរេដបូកអាចឲ្យកម្ពុជាទទួលបានឋវិកាសម្រាប់អនុវត្តសកម្មភាពដែលជួយកាត់បន្ថយការបញ្ចេញឧស្ម័នពីការបាត់បង់ និងរេចរឹលព្រៃឈើ បើទោះបីជាការកាត់បន្ថយឧស្ម័នក្នុងកម្រិតជាក់ស្តែងនឹងត្រូវទូទាត់សងនៅពេលក្រោយក៏ដោយ។ ករណីនេះអាចផ្លាស់ប្តូរការបែងចែកចំណូលពីការចែកបន្ទាប់ពីទទួលចំណូល មកចែកមុនពេលទទួលចំណូល ដែលជាការប្រសើរសម្រាប់សហគមន៍ តែអាចមានហានិភ័យប្រសិនបើលទ្ធផលនៃការកាត់បន្ថយការបញ្ចេញឧស្ម័នមិនបានដូចអ្វីដែលបានរំពឹងទុក។ ដើម្បីឲ្យសកម្មភាពរេដបូកទទួលជោគជ័យ វាគួរតែអនុវត្តក្នុងកម្រិតជាតិទូទាំងប្រទេសកម្ពុជា មិនមែនតែក្នុងតំបន់ខ្លះនោះទេ។ នេះជាចំណុចខុសគ្នារវាងការចូលរួមក្នុងយន្តការរេដបូកនៅថ្នាក់អន្តរជាតិ និងការអនុវត្តន៍គម្រោងតាមរបៀបទីផ្សារកាបោនស្ម័គ្រចិត្ត។

## ៧. មូលនិធិរេដបូក និងការចុះឈ្មោះគណនីកាបោន

បច្ចុប្បន្ននេះ UNFCCC មិនទាន់តម្រូវឲ្យប្រទេសជាសមាជិកបង្កើតមូលនិធិរេដបូក ឬក៏គណនីកាបោននោះទេ ក៏ប៉ុន្តែក្នុងការចរចារពីការផ្តល់មូលនិធិសម្រាប់សកម្មភាពរេដបូក ចំណុចទាំងពីរនេះតែងតែត្រូវបានលើកឡើងមកពិភាក្សា។ ដើម្បីឲ្យប្រទេសមួយទទួលបានការទូទាត់សំណងពីសកម្មភាពរេដបូក វាជាការចាំបាច់ដែលទាមទារឲ្យមានមូលនិធិរេដបូកមួយសម្រាប់ទទួល និងបែងចែកចំណូលពីរេដបូកនេះ។

គណនីរេដបូក ប្រើសម្រាប់ធានាថា ការកាត់បន្ថយឧស្ម័នតាមរយៈរេដបូកត្រូវបានកត់ត្រាលំអិតនិងច្បាស់លាស់។ ការកាត់បន្ថយការបញ្ចេញឧស្ម័នជាសេវាកម្ម/ទំនិញមួយប្រភេទ ដែលស្តែងឡើងតាមរយៈការមិនកើតឡើងនូវការបញ្ចេញឧស្ម័ន។ វាមិនមែនជារបស់ដែលអាចវេចខ្ចប់ និងដឹកជញ្ជូនបាននោះទេ វាគ្រាន់តែអាចឯកសារលើក្រដាស ឬក្នុងម៉ាស៊ីនកុំព្យូទ័រប៉ុណ្ណោះ។ ហេតុនេះ វាទាមទារនូវគោលការណ៍តឹងរឹង សម្រាប់អ្នកមានសិទ្ធិចែកបន្តនូវកម្រិតនៃការកាត់បន្ថយការបញ្ចេញឧស្ម័ន ហើយទទួលបានការទូទាត់សំណង ព្រមទាំងទាមទារនូវការផ្សារភ្ជាប់នឹងលទ្ធផលនៃការត្រួតពិនិត្យ រាយការណ៍ និងផ្ទៀងផ្ទាត់លទ្ធផលជាក់ស្តែង។ នេះសម្រាប់ការពារនូវការរាយការណ៍ពីរដង ឬការផ្តល់ទិន្នន័យខុសពីការកាត់បន្ថយការបញ្ចេញឧស្ម័ននេះ។ UNFCCC បង្កើតគណនីកាបោនសម្រាប់វិស័យផ្សេងរួចហើយ ហើយដែលគណនីនេះអាចសមស្រប (ឬមិនសមស្រប)សម្រាប់រេដបូក។

## ៨. ការធានាសុវត្ថិភាពស្តីពីប្រព័ន្ធព័ត៌មាន

វិធានទាំង៧ស្តីពីការធានាសុវត្ថិភាព ដែលមានចែងក្នុងកិច្ចព្រមព្រៀងទីក្រុងគាន់គូន (COP16) ត្រូវតែគោរពនៅពេលអនុវត្តន៍រេដបូក (ការពន្យល់ស៊ីជម្រៅពីការធានាសុវត្ថិភាពរេដបូកនឹងមាននៅ

មេរៀនបន្ទាប់)។ ក្នុងន័យនេះការឆ្លើយតបនឹងការធានាសុវត្ថិភាពអាចពិនិត្យមើលតាមរយៈ គោលការណ៍ និងលក្ខខន្ដិកៈ ក្នុងការអនុវត្តរេដបូក។ កិច្ចព្រមព្រៀងទីក្រុងកាន់គូនក៏តម្រូវឲ្យប្រទេសនីមួយៗរៀបចំប្រព័ន្ធព័ត៌មានមួយក្នុងការចែកចាយព័ត៌មានពីការអនុវត្ត និងគោរពគោលការណ៍នៃការធានសុវត្ថិភាពក្នុងការអនុវត្តសកម្មភាពរេដបូក។

កិច្ចព្រមព្រៀងបន្ទាប់ (COP17) បានផ្ដល់គោលការណ៍ណែនាំពីការរៀបចំប្រព័ន្ធព័ត៌មានស្ដីពីការអនុវត្ត និងគោរពគោលការណ៍ធានាសុវត្ថិភាពនេះ។ ប្រព័ន្ធព័ត៌មាននេះគួរ តែ៖

- ផ្ដល់ព័ត៌មានដែលមានតម្លាភាព និងត្រឹមត្រូវដែលអាចទទួលយកបានដោយគ្រប់ភាគីពាក់ព័ន្ធ ព្រមទាំងធ្វើបច្ចុប្បន្នភាពជាទៀងទាត់
- មានតម្លាភាព និងអាចបត់បែនបានដើម្បីធានាឲ្យមានការកែលំអប្រព័ន្ធនោះ
- ផ្ដល់ព័ត៌មានពីការគោរព និងអនុវត្តគោលការណ៍ធានាសុវត្ថិភាព
- សមស្របតាមបរិបទប្រទេសនីមួយៗ ហើយអនុវត្តន៍នៅក្នុងកម្រិតជាតិ
- ប្រើប្រាស់ប្រព័ន្ធដែលមានស្រាប់ក្នុងប្រទេសនោះ ប្រសិនបើអាច

កិច្ចព្រមព្រៀងក៏សម្រេចឲ្យប្រទេសនីមួយៗផ្ដល់ព័ត៌មានសង្ខេបពីការអនុវត្ត និងគោរពគោលការណ៍ ធានាសុវត្ថិភាពក្នុងកំឡុងពេលអនុវត្តសកម្មភាពរេដបូកផងដែរ។ ព័ត៌មាននេះត្រូវផ្ញើរទៅ UNFCCC បន្ទាប់ពីចាប់ផ្ដើមអនុវត្តសកម្មភាពរេដបូក។

Angelsen A. (ed.) 2008: Moving Ahead with REDD: Issues, Options and Implication. CIFOR: Bogor.
Stephen, P. 2009: *Introductory Course on Reducing Emissions from Deforestation and Forest Degradation (REDD)*: IDSS Pvt. Ltd.
Booklet prepared by REDD+ Pilot Project-ICIMOD, FECOFUN and ANSAB.
REDD CELL- draft version of REDD Terminologies.

# ការវិភាគអ្នកពាក់ព័ន្ធ

## អ្នកណាជាអ្នកពាក់ព័ន្ធ ?

អ្នកពាក់ព័ន្ធនៃកម្មវិធីណាមួយគឺជា “បុគ្គល ក្រុម ឬស្ថាប័នដែលមានការចាប់អារម្មណ៍ មានតួនាទី ការទទួលខុសត្រូវ និងមានឥទ្ធិពលទាំងវិជ្ជមាន និងអវិជ្ជមាន ។ បុគ្គល ក្រុម ស្ថាប័ន និងសហគមន៍ដែលទទួលរងឥទ្ធិពលដោយផ្ទាល់ពីកម្មវិធី REDD+ ត្រូវបានកំណត់ថាជាអ្នកពាក់ព័ន្ធរបស់កម្មវិធី REDD+ ក្នុងកំឡុងពេលនៃការអនុវត្ត REDD+ គឺមានការរួមបញ្ចូលទាំងផ្ទាល់ និងប្រយោលនូវគ្រប់ទិដ្ឋភាព គឺទាំងទិដ្ឋភាពបច្ចេកទេស នយោបាយ សេដ្ឋកិច្ច សង្គម និងវប្បធម៌ ។ ដោយសារតែក្នុងដំណើរការនៃការអនុវត្ត REDD+ មានបញ្ចូលនូវគ្រប់ទិដ្ឋភាពដូចខាងលើ ដូច្នេះអ្នកពាក់ព័ន្ធមានផ្សេងៗគ្នាយោងទៅតាមកម្រិត និងតួនាទីរបស់អ្នកពាក់ព័ន្ធទាំងនោះ ។ តួនាទី និងសិទ្ធិរបស់ជនជាតិដើមភាគតិច ព្រមទាំងប្រជាសហគមន៍ដែលគ្រប់គ្រងធនធានព្រៃឈើ និងអនុវត្តនូវសកម្មភាពនានាសម្រាប់ការធ្វើអោយមានកាបោនស្តុកគឺខុសគ្នាពីស្ថាប័នផ្សេងៗទៀត ។ បញ្ហាក្នុងការទទួលស្គាល់នូវសិទ្ធិរបស់អ្នកពាក់ព័ន្ធទាំងនេះត្រូវបានលើកមកពិភាក្សានៅវេទិកាជាច្រើន ។ ដូច្នេះ ការវិភាគអោយបានលំអិតនូវក្រុមអ្នកពាក់ព័ន្ធទាំងនោះមានសារៈសំខាន់ណាស់សម្រាប់ការអនុវត្តរួមគ្នានៃកម្មវិធី REDD+ អោយទទួលបានជោគជ័យ និងមានតម្លាភាព ។

## សារសំខាន់នៃការវិភាគអ្នកពាក់ព័ន្ធ

ដំណើរការនៃការកំណត់អត្តសញ្ញាណនៃក្រុមដែលពាក់ព័ន្ធ (រួមបញ្ចូលទាំងអ្នកកាន់សិទ្ធិ) និងការវិភាគជាលម្អិតនៃតួនាទី ការទទួលខុសត្រូវរបស់ពួកគេ និងសិទ្ធិនេះ ត្រូវបានគេស្គាល់ថា ជាការវិភាគអ្នកពាក់ព័ន្ធ ។ ទោះបីជាមិនមានវិធីសាស្ត្រជារួមណាសម្រាប់ការវិភាគភាគីពាក់ព័ន្ធនេះក៏ដោយ មានស្ថាប័នមួយចំនួនបានអនុវត្តគម្រោងរបស់ពួកគេដោយការវិភាគអ្នកពាក់ព័ន្ធដោយការរៀបចំវិធីសាស្ត្រផ្ទាល់ខ្លួនរបស់ពួកគេ។

នៅពេលដែលរ៉េដបូកបន្តអភិវឌ្ឍ ការយល់ដឹងពីរ៉េដបូក និងដំណើរការនៃការអនុវត្តរបស់រ៉េដបូកគឺនៅតែមិនច្បាស់លាស់។ ប៉ុន្តែវាបានបង្កើនការចាប់អារម្មណ៍ខ្ពស់ក្នុងចំណោមរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាល អ្នកគ្រប់គ្រងព្រៃ សហគមន៍ដែលពឹងផ្អែកលើព្រៃឈើ និងភាគីពាក់ព័ន្ធដទៃទៀត។ ដូច្នេះវាមានតំរូវការចាំបាច់សម្រាប់ការយល់ដឹងច្បាស់លាស់នៅលើចំណាប់អារម្មណ៍ពិតប្រាកដ សិទ្ធិនិងការទទួលខុសត្រូវនិងឥទ្ធិពលរបស់ភាគីពាក់ព័ន្ធទាំងនោះ ។ ប្រសិនបើសកម្មភាពការវិភាគនិងការផ្សព្វផ្សាយមិនត្រូវបានធ្វើត្រឹមត្រូវទេនោះ នឹងមាននូវស្ថានភាពមួយដែលអាចធ្វើអោយភាគីពាក់ព័ន្ធទាំងនោះមិនបានដឹងអំពីអត្ថប្រយោជន៍ ផលប៉ះពាល់ និងឱកាសនានាហើយមានតែក្រុមអ្នកពាក់ព័ន្ធមួយចំនួនតូចដែលទទួលបានអត្ថប្រយោជន៍។

ការវិភាគអ្នកពាក់ព័ន្ធមានសារៈសំខាន់សម្រាប់ ៖

- ចែករំលែកព័ត៌មាន/ផ្តល់ដំណឹងអំពីកម្មវិធី REDD+
- កាត់បន្ថយនូវទំនាស់នានាដែលអាចកើតមានក្នុងចំណោមអ្នកពាក់ព័ន្ធ

- រៀបចំនូវដំណើរការនៃការអនុវត្ត REDD+ មួយដែលមានតម្លាភាព
- ទទួលបាននូវយោបល់កែលំអនានាក្នុងកំឡុងពេលនៃការរៀបចំ និងអនុវត្តគោលនយោបាយ និង កម្មវិធីអភិវឌ្ឍនានា
- ការឯកភាពជារួមនូវតួនាទី និងការទទួលខុសត្រូវក្នុងចំណោមអ្នកពាក់ព័ន្ធនានា
- ការរៀបចំនូវគោលនយោបាយ និងបញ្ញត្តនានាក្នុងដំណើរការដោយមានការចូលរួម
- រក្សានូវការយល់ដឹងរួមគ្នាអំពីបញ្ហា ដូចជា ប្រសិទ្ធិភាពរបស់កម្មវិធីដែលជាតម្រូវការ ។ល។

**ការវិភាគលើការចាប់អារម្មណ៍/ផលប្រយោជន៍ និងឥទ្ធិពល**

ក្នុងដំណើរការនេះ កម្រិតនៃអ្នកពាក់ព័ន្ធនានារបស់ REDD+ ដែលយើងមានការគិតគូរបាន បញ្ជាក់ច្បាស់ ហើយបញ្ជីនៃបុគ្គល ស្ថាប័ន និងក្រុមដែលជាប់ពាក់ព័ន្ធជាមួយកម្មវិធី REDD+ ត្រូវបាន រៀបចំ ។ បញ្ជីនៃអ្នកពាក់ព័ន្ធត្រូវបានចាត់ថ្នាក់ជា៤ប្រភេទដោយផ្តោតលើមូលដ្ឋាននៃផលប្រយោជន៍ ក្នុង កម្មវិធី REDD+ និងសមត្ថភាពក្នុងការធ្វើអោយមានឥទ្ធិពលដល់ការអនុវត្ត REDD+ ។

១. កម្រិតនៃការចាប់អារម្មណ៍ខ្ពស់ ប៉ុន្តែមានសមត្ថភាពទាបក្នុងការធ្វើអោយមានឥទ្ធិពលលើដំណើរការ នៃការអនុវត្ត

២. មានការចាប់អារម្មណ៍តិចតួចលើកម្មវិធី ប៉ុន្តែមានសមត្ថភាពខ្ពស់ក្នុងការធ្វើអោយមានឥទ្ធិពលក្នុង ដំណើរការនៃការអនុវត្ត

៣. មានការចាប់អារម្មណ៍ និងមានឥទ្ធិពលតិចតួចក្នុងដំណើរការនៃការអនុវត្ត

៤. ទាំងការចាប់អារម្មណ៍ និងសមត្ថភាពក្នុងការធ្វើអោយមានឥទ្ធិពលក្នុងការអនុវត្តកម្មវិធីខ្ពស់

អ្នកពាក់ព័ន្ធដែលបានលើកឡើងខាងលើគួរតែដាក់បញ្ចូលនៅក្នុងម៉ាទ្រិកដែលបានបង្ហាញក្នុងរូប ភាពខាងក្រោម និងអាចធ្វើការសិក្សា និងវិភាគ ។

| | | |
|---|---|---|
| **ឥទ្ធិពល** | **A** មានការចាប់អារម្មណ៍តិចតួចលើកម្មវិធី ប៉ុន្តែមានសមត្ថភាពខ្ពស់ក្នុងការធ្វើអោយមានឥទ្ធិពលក្នុងដំណើរការនៃការអនុវត្ត | ការចាប់អារម្មណ៍ និងសមត្ថភាពក្នុងការធ្វើអោយមានឥទ្ធិពលក្នុងការអនុវត្តកម្មវិធីខ្ពស់ **B** |
| | មានការចាប់អារម្មណ៍ និងមានឥទ្ធិពលតិចតួចក្នុងដំណើរការនៃការអនុវត្ត **C** | កម្រិតនៃការចាប់អារម្មណ៍ខ្ពស់ ប៉ុន្តែមានសមត្ថភាពទាបក្នុងការធ្វើអោយមានឥទ្ធិពលលើដំណើរការនៃការអនុវត្ត **D** |

**ការចាប់អារម្មណ៍**

# ការធានាសុវត្ថិភាពសេដ្ឋកិច្ច សង្គមក្នុងការអនុវត្ត REDD

## សេចក្តីផ្តើម៖

ការអនុវត្តរេដបូកត្រូវឆ្លើយតបនឹងគោលការណ៍ធានាសុវត្ថិភាព ដូចនេះប្រទេសនីមួយអាចបញ្ចៀសនូវ ផលប៉ះពាល់ជាអវិជ្ជមានដល់សេដ្ឋកិច្ច និងសង្គម តែក៏ត្រូវធានានូវផលប្រយោជន៍ចំរុះផងដែរ។ គោលការណ៍ធានាសុវត្ថិភាពទាំង៧ដែលមានក្នុងកិច្ចព្រមព្រៀងទីក្រុងកាន់គូន បានរួមបញ្ចូលនូវការធានាសុវត្ថិភាពផ្នែកសេដ្ឋកិច្ច និងសង្គមរួចហើយ។ គោរពគោលការណ៍ទាំងនេះជាកត្តាចាំបាច់ក្នុងការទទួលបានការទូទាត់សំណងទាំងតាមរយៈទីផ្សារកាបោន និងគម្រោង។

១. ហេតុអ្វីការធានាសុវត្ថិភាពរេដបូកសំខាន់?

ការធានាសុវត្ថិភាពរេដបូកមានន័យថាការធានានូវគោលការណ៍ខាងក្រោម៖

ផលប៉ះពាល់សង្គម៖ នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ប្រជាសហគមន៍ និងជនជាតិដើមភាគតិចជាច្រើនពឹងអាស្រ័យលើធនធានព្រៃឈើសម្រាប់ការចិញ្ចឹមជីវិត (World bank, 2012)។ តែសិទ្ធិប្រើប្រាស់និងគ្រប់គ្រងរបស់ពួកគេមិនសូវបានរំលេចក្នុងគោលការណ៍ច្បាប់របស់ប្រទេសទាំងនោះទេ។ ដូចនេះវាអាចមានហានិភ័យ**ផ្នែកសង្គម**ដែលរេដបូកអាចបង្កជាឥទ្ធិពលអវិជ្ជមានដល់ការពឹងអាស្រ័យល់ព្រៃឈើសម្រាប់ចិញ្ចឹមជីវិតរបស់ពួកគេដូចតទៅ៖

- ហានិភ័យផ្នែកសង្គមទី១៖ ផលប៉ះពាល់អវិជ្ជមានដល់សហគមន៍មូលដ្ឋាន និងជនជាតិដើម
    - ការហាមឃាត់មិនឲ្យដកហូតធនធានព្រៃឈើដែលពួកគេកំពុងប្រើប្រាស់។ រេដបូកអាចនាំមកនូវបទបញ្ញា និងគោលការណ៍គ្រប់គ្រងព្រៃឈើដើម្បីធានាការស្រូបកាបោន ហើយដែលគោលការណ៍ ទាំងនេះអាចកាត់បន្ថយការប្រើប្រាស់ធនធានព្រៃឈើរបស់សហគមន៍មូលដ្ឋាន និងជនជាតិដើមទាំងនោះ។
    - ការជន្លៀសសហគមន៍ និងជនជាតិដើមពីតំបន់ព្រៃដោយពួកគេមិនស្ម័គ្រចិត្ត។ ក្នុងករណីខ្លះពួកគេអាចបាត់បង់ដីកេរ្តិ៍ដំណែល និងត្រូវបានបង្ខំឲ្យចេញពីតំបន់ព្រៃដែលពួកគេកំពុងរស់នៅ។
- ហានិភ័យផ្នែកសង្គមទី២៖ ការមិនរាប់បញ្ចូល និងការដកចេញសហគមន៍មូលដ្ឋាន ជាពិសេស) និងជនជាតិដើមភាគតិច (រងគ្រោះក្រុមដែលងាយធ្វើពីការសម្រេចចិត្ត និងការបែងចែកសេចក្តីផលប្រយោជន៍
    - រេដបូកអាចដកចេញជនជាតិដើម និងសហគមន៍មូលដ្ឋានពីការសម្រេចចិត្ត និងការបែងចែកផលប្រយោជន៍។ ទោះបីជាពួកគេបានចូលរួមក្នុងការសម្រេចចិត្ត និងការបែងចែកផលប្រយោជន៍ក៏អាចមានការទាញយកផលប្រយោជន៍ពីក្រុមមានអំណាចក្នុងសហគមន៍ពួកគេដែលមានឥទ្ធិពលលើការសម្រេចិត្ត និងការបែងចែកផល។ ជាលទ្ធផល

រេដបូកអាចរិតតែធ្វើឲ្យក្រុមងាយរងគ្រោះដូចជា អ្នកក្របំផុតក្នុងចំណោមអ្នកក្រអ្នកមាន ,
និងស្ត្រី បាត់បង់ឱកាសទទួល ផលប្រយោជន៍។ ,ឋានៈទាបក្នុងសហគមន៍

ផលប៉ះពាល់បរិស្ថាន៖ ព្រៃឈើបានផ្តល់នូវសេវាកម្មបរិស្ថានជាច្រើនដូចជា ការផ្តល់ប្ភពទឹកស្អាត ការពារការហូរច្រោះដី និងការពារជីវចំរុះ (Mi l l e nni um E c o s y s t e m As s e s s me n t , 2003) ។ ហានិភ័យលើ បរិស្ថានមាន៖

- ហានិភ័យទី១៖ ការផ្ទេរព្រៃធម្មជាតិ
    - រេដបូកអាចបង្កឲ្យមានការផ្លាស់ប្តូរពីព្រៃធម្មជាតិទៅជាចំការព្រៃដាំឯកភេទ ដែលមានឥទ្ធិពលអាក្រក់ ដលើប្រព័ន្ធអេកូស៊ីស្ទែម និងជីវចំរុះដែលមានស្រាប់
- ហានិភ័យទី២៖ ការភ្លាស់ប្តូរពីតំបន់មួយទីមួយ សំពាធនៃការបាត់បង់ និងរិចរិលព្រៃឈើនៅក្រៅ) (អនុវត្តន៍រេដបូកតំបន់
    - កិច្ចប្រឹងប្រែងក្នុងការកាត់បន្ថយការបាត់បង់ និងរិចរិលព្រៃឈើនៅតំបន់មួយអាចធ្វើឲ្យសំពាធនៃការបាត់បង់នេះកើតឡើងនៅក្រៅតំបន់អនុវត្តន៍រេដបូក។ ឧទាហរណ៍ប្រសិនបើតំបន់ព្រៃមួយដែលអនុវត្តន៍រេដបូកត្រូវបានការពារ អ្នកដែលធ្លាប់ដកហូតផលពីព្រៃតំបន់នោះនឹងប្តូរទីតាំងទៅតំបន់ផ្សេង ដោយសារពួកគេត្រូវការចិញ្ចឹមជីវិត។
- ហានិភ័យទី៣៖ ការប្រែក្រឡាស់
    - ហានិភ័យទាក់ទងនឹងការប្រែក្រឡាស់សំដៅលើការបាត់បង់ និងរិចរិលព្រៃឈើ នៅតំបន់អនុវត្តន៍រេដបូក បន្ទាប់ពីទទួលបានការទូទាត់សំណងរួច។ ហានិភ័យទាក់ទងនឹងអចិន្ត្រៃយភាព។ ឧការធានាថាកម្រិត ស្តុកកាប .ោនត្រូវបានរក្សាឲ្យនៅកម្រិតដដែលជាអចិន្ត្រៃយ៍បន្ទាប់ពីការទូទាត់សំណងរួចក៏ដោយ។

២. តើគោលការណ៍ធានាសុត្តិភាពរេដបូកចង់សម្រេចបានអ្វី?

ដើម្បីដោះស្រាយហានិភ័យផ្នែកសង្គម និងសេដ្ឋកិច្ចក្នុងដំណើរការរេដបូក គោលការណ៍ធានាសុវត្ថិភាពរេដបូកត្រូវបានបង្កើតឡើងក្នុងគោលបំណងពីរ៖

- ហារនិភ័យ ដោយអនុវត្តន៍ដោយមិនបង្កគ្រោះថ្នាក់ (F C M, 20១2)៖ ការធានាសុវត្ថិភាពត្រូវបានរំពឹងថាជួយបញ្ចៀស និងកាត់បន្ថយផលប៉ះពាល់បរិស្ថាន និងសង្គមពីរេដបូក។
- លទ្ធផល អនុវត្តល្អ )F C M, 2012)៖ បន្ថែមពីលើគោលដៅខាងលើ ការធានាសុវត្ថិភាពរំពឹងថារេដបូកនឹងផ្តល់ជាផលប្រយោជន៍ចំរុះ។ ផលប្រយោជន៍ចំរុះសំដៅលើផលប្រយោជន៍បន្ថែមដូចជា ការពង្រឹងអភិបាលកិច្ចព្រៃឈើ ធានាសិទ្ធិសហគមន៍មូលដ្ឋានដែលពឹងអាស្រ័យលើព្រៃឈើ ការបង្កើតឱកាសការងារ និងការលើកកំពស់ប្រព័ន្ធអេកូឡូស៊ី និងជីវចំរុះ។

៣. គោលការណ៍ U N F C C C

បច្ចុប្បន្ននេះមានគោលការណ៍ពីរសំខាន់គឺ កិច្ចព្រមព្រៀងទីក្រុងកានគូន និងក្រមប្រតិបត្តិទីក្រុងឌូបេន ដែលបានផ្តល់ជាលក្ខណៈវិនិច្ឆ័យ និងនីតិវិធីដល់ប្រទេសនានាក្នុងការអនុវត្តគោលនយោបាយរេដបូក។ ការធានាសុវត្ថិភាពទាំងនេះត្រូវគ្នានឹងហានិភ័យសង្គម និងបរិស្ថានដែលយើងបានរៀបរាប់ពីខាងលើ។

កិច្ចព្រមព្រៀងទីក្រុងកាន់គូន ដែលបានធ្វើឡើងនៅឆ្នាំ២០១០ ក្នុង COP16 នៅប្រទេសមិចស៊ិច បានរៀបរាប់សេចក្តីសម្រេចអំពីប្រព័ន្ធគោលការណ៍ធានាសុវត្ថិភាព៖

តារាងទី១៖ កិច្ចព្រមព្រៀងទីក្រុងកាន់គូន ដែលបានធ្វើឡើងនៅឆ្នាំ២០១០

| |
|---|
| *នៅពេលអនុវត្តន៍សកម្មភាពដែលមានចែងក្នុងវគ្គទី៧០ នៃសេចក្តីសម្រេចនេះ គោលការណ៍ធានាសុវត្ថិភាព ខាងក្រោមត្រូវតែគោរព៖* |
| ក. សកម្មភាពត្រូវតែរួមចំណែកដល់ និងឆ្លើយតបនឹងគោលបំណង នៃកម្មវិធីពញរៃឈើជាតិ ក៏ដូចជាកត្តិការសញ្ញា និងកិច្ចព្រមព្រៀងអន្តរជាតិនានា |
| ខ. រចនាសម្ព័ន្ធអភិបាលកិច្ចព្រៃឈើដែលមានតម្លាភាព និងមានប្រសិទ្ធិភាព ដែលសមស្របតាមបទបដ្ឋានច្បាប់នៃប្រទេសនីមួយៗ |
| គ. គោរពនិងឲ្យតំលៃចំណេះដឹងសហគមន៍មូលដ្ឋាន និងជនជាតើដើមភាគតិច នឹងគិតគូពីកិច្ចព្រមព្រៀងអន្តរជាតិ ច្បាប់ និងបរិបទរបស់ប្រទេសសាមី ព្រមទាំងកត់សំគាល់ថាធម្មនុញអង្គការសហប្រជាជាតិបានអនុម័តកត្តិការសញ្ញា សហប្រជាជាតិស្តីពីសិទ្ធិជនជាតិដើមភាគតិច។ |
| ឃ. ការចូលរួមពេញលេញ និងមានប្រសិទ្ធិភាពរបស់ភាគីពាកព័ន្ធទាំងអស់ ជាពិសេសជនជាតិដើមភាគតិច និងសហគមន៍មូលដ្ឋាន នៅក្នុងសកម្មភាពដែលមានចែងក្នុងវគ្គទី៧០ និង៧២ នៃសេចក្តីសម្រេចនេះ |
| ង. សកម្មភាពទាំងអស់ត្រូវរួមចំណែកដល់ការអភិរក្សព្រៃធម្មជាតិ និងជីវចំរុះ ដោយធានាថាសកម្មភាពដែលមានចែង ក្នុងវគ្គទី៧០ នៃសេចក្តីសម្រេចនេះមិនត្រូវបានប្រើប្រាស់សម្រាប់ផ្ទេរព្រៃធម្មជាតិទេ តែបានរួមចំណែកការពារ និងអភិរក្សព្រៃឈើ និងប្រព័ន្ធអេកូស៊ីស្ទែម ព្រមទាំងលើកកំពស់ផលប្រយោជន៍សង្គម និងបរិស្ថាន។ |
| ច. សកម្មភាពត្រូវគិតគូដល់ហានិភ័យនៃការប្រែប្រួលក្រឡាស់ |
| ឆ. សកម្មភាពត្រូវតែជៀសវាង និងកាត់បន្ថយការជន្លៀសចេញពីទីតាំងរស់នៅ |

ក្រុមប្រតិបត្តិទីក្រុងឌូបេននៅឆ្នាំ២០១១ COP17 លើកឡើងពីនីតិវិធីក្នុងការផ្តល់ព័ត៌មានពីការគោរពគោលការណ៍ធានាសុវត្ថិភាពដែលប្រទេសនីមួយៗត្រូវប្រតិបត្តិ (តារាងទី២)

តារាងទី២៖ ក្រុមប្រតិបត្តិទីក្រុងឌូបេននៅឆ្នាំ២០១១ COP17

| |
|---|
| *សេចក្តីសម្រេចក្នុង 12/CP.17 បានយល់ព្រមថាប្រព័ន្ធផ្តល់ព័ត៌មានពីការគោរពគោលការណ៍ធានាសុវត្ថិភាព ដែលមានក្នុងឧបសម្ព័ន្ធទី១ នៃសេចក្តីសម្រេច 1/CP.16 នឹងត្រូវគោរពតាម ផ្អែកលើសមត្ថភាព និងលក្ខខ័ណ្ឌនៃប្រទេសសាមី ព្រមទាំងស្របតាមច្បាប់នៃប្រទេសសាមី ក៏ដូចជាកិច្ចព្រមព្រៀង និងសន្ធិសញ្ញាអន្តរជាតិនានា ព្រមទាំង ការគិតគូពីកត្តាយេនឌ័រ៖* |
| ក. សមស្របតាមគោលការណ៍ដែលមានចែងក្នុងឧបសម្ព័ន្ធទី១នៃ សេចក្តីសម្រេច 1/CP.16 |
| ខ. ផ្តល់ព័ត៌មានត្រឹមត្រូវ និងមានតម្លាភាព ហើយអាចទទួលយកបានពីគ្រប់ភាគីពាក់ព័ន្ធ |
| គ. មានតម្លាភាព និងអាចបតើបែនបានដើម្បីធានាឲ្យមានការកែលំអប្រព័ន្ធនោះ |
| ឃ. ផ្តល់ព័ត៌មានពីការគោរព និងធនុវត្តគោលការណ៍ធានាសុវត្ថិភាព |
| ង. សមស្របតាមបរិបទប្រទេសនីមួយៗ ហើយអនុវត្តន៍នៅក្នុងកម្រិតជាតិ |
| ច. ប្រើប្រាស់ប្រព័ន្ធដែលមានស្រាប់ក្នុងប្រទេសនោះ ប្រសិនបើអាច |

កិច្ចព្រមព្រៀងទីក្រុងកាន់គូនក៏បានដាក់បញ្ចូលនូវគោលការណ៍មួយចំនួន ដោយរេដបូកគួរតែ៖

ក. រួមចំណែកសម្រេចគោលបំណងដែលមានចែងក្នុងមាត្រាទី២ នៃសន្ធិសញ្ញា

ខ. រួមចំណែកអនុវត្តន៍ខ្លឹមសារវគ្គទី៣ នៃមាត្រាទី៤ នៃសន្ធិសញ្ញា

គ. សមស្របតាមបរិបទនៃប្រទេសនីមួយ និងគិតគូពីជម្រើសដែលប្រទេសអាចធ្វើបាន

ឃ. ឆ្លើយតបនឹងគោលបំណងការពារបរិស្ថាន ព្រមទាំងគិតគូរពីមុខងារចំរុះនៃព្រៃឈើ និងជីវចំរុះ

ង. ឆ្លើយតបនឹងអាទិភាពអភិវឌ្ឍន៍ គោលបំណង បរិបទ និងសមត្ថភាព របស់ប្រទេសនីមួយៗ ដោយទទួល ស្គាល់នូវអធិបតេយ្យភាពរបស់ប្រទេសសាមី

ច. ឆ្លើយតបនឹងគោលដៅអភិវឌ្ឍដោយនិរន្តភាពរបស់ប្រទេសសាមី

ឆ. អនុវត្តន៍ក្នុងបរិបទនៃការអភិវឌ្ឍដោយនិរន្តភាព ការកាត់បន្ថយភាពក្រីក្រ និងការឆ្លើយតបនឹងការ ប្រែប្រួលអាកាសធាតុ

ជ. សមស្របនឹងតម្រូវការបន្សាំនឹងការប្រែប្រួលអាកាសធាតុរបស់ប្រទេសសាមី

ឈ. ទទួលបានការគាំទ្រទាំងផ្នែកហិរញ្ញវត្ថុ និងបច្ចេកទេស ដោយរួមទាំងការកសាងសមត្ថភាព

ញ. បែរឆ្ពោះទៅរកលទ្ធផល

មានការគោរពគោលការណ៍រេដបូក មិនទាមទារឲ្យមានការរាយការណ៍ដូចជាការធានាសុវត្ថិភាពនោះទេ តែការគោរពគោលការណ៍នេះនៅតែសំខាន់ក្នុងការអនុវត្ត។

៤. បច្ចេកទេសប៉ាន់ប្រមាណផលប៉ះពាល់

រេដបូកអាចរួមបញ្ចូលនូវការប៉ាន់ប្រមាណផលប៉ះពាល់បរិស្ថាន និងសង្គមដែលអាចអនុវត្តន៍តាមវិធីសាស្ត្រខុសៗគ្នា។ ដ្យាក្រាមខាងក្រោមបង្ហាញពីវិធីសាស្ត្រមួយក្នុងចំណោមនោះ។




ដ្យាក្រាម ១៖ ការប៉ាន់ប្រមាណផលប៉ះពាល់លើទិដ្ឋភាពសង្គម និងបរិស្ថានដោយ REDD+ (កែសម្រួលពី FCPF)

**៥. ឱកាសចូលរួមរបស់សហគន៍មូលដ្ឋានដែលពឹងអាស្រ័យលើព្រៃឈើ និងអ្នកពាក់ព័ន្ធផ្សេងៗ**

នៅពេលអនុវត្តន៍រេដបូក ការប្រើប្រាស់ព្រៃឈើរបស់សហគមន៍មូលដ្ឋានដែលកំពុងពឹងអាស្រ័យលើធនធានត្រូវតែធានា។ គួរតែមានវិធានការធានាសិទ្ធិប្រពៃណីរបស់សហគមន៍ដែលពឹងផ្អែកលើធនធានព្រៃឈើ។ ក្នុងកំឡុងពេលនៃការអនុវត្តរេដបូក សហគមន៍គួរតែអាចបន្តប្រើប្រាស់ធនធានព្រៃឈើ ដែលពួកគេកំពុងប្រើប្រាស់ជាលក្ខណៈប្រពៃណី។ ការគ្រប់គ្រងព្រៃឈើដោយនិរន្តភាព ការបង្កើនស្តុក កាបោន ការការពារព្រៃឈើ គឺផ្អែកលើការកាត់បន្ថយការបាត់បង់ និងរិចរិលព្រៃឈើ។ ការចូលរួមដោយពេញលេញ និងមានប្រសិទ្ធិភាពពីសហគមន៍មូលដ្ឋានដែលពឹងអាស្រ័យលើធនធានព្រៃឈើ ក្នុងការសម្រេចចិត្តលើការគ្រប់គ្រងព្រៃឈើ និងការអនុវត្តការបែងចែកផលប្រយោជន៍ជាផ្នែកមួយនៃការធានាសុវត្ថិភាព។